សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# វិវាទសមុទ្រចិនខាងត្បូងក្នុងបរិបទថ្មី នៃសតវត្សទី២១រវាងភាគីចិន និង ហ្វីលីពីន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

រៀបរៀងដោយ

និស្សិតឈ្មោះ: **លោក. វិសិដ្ឋ មង្គល**

**កញ្ញា. អ៊ូ សៀវនាង**

សាស្ត្រាចារ្យណែនាំ

**លោក តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ទិសិដ្ឋ មង្គល** និងនាងខ្ញុំ **អ៊ូ សៀវនាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានចូលសិក្សាក្នុងឆ្នាំ ២០១៣ នឹងបញ្ចប់នៅឆ្នាំ ២០១៧ មានសេចក្តីជ្រះថ្លាជាអនេក និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណនិងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់គ្នាដូចតទៅនេះ៖

ជាដំបូងកូនសូមថ្លែង និងសំដែងការដឹងគុណជាអនេកប្បការដល់លោកអ្នកមានគុណទាំងពីរដែលមាន លោកឪពុក និងអ្នកម្តាយនិងក្រុមគ្រួសារទាំងមូល ដែលលោកឪពុក និងអ្នកម្តាយបានផ្តល់កំណើតអោយកូនម្នាក់នេះជាមួយនឹងភាពស្រស់ស្អាត និងសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅចាប់តាំងពីលោកអ្នកបានផ្តល់កំណើតអោយកូនទាំងពីរនេះមក គឺលោកបានខិតខំប្រឹងប្រែងដោយគ្មានការនឿយហត់ ទាំងដែលញើសលោកស្រក់ស្ទើរតែដូចទឹកទន្លេ ប៉ុន្តែលោកនៅតែខិតខំប្រឹងប្រែងដើម្បីចិញ្ចឹមបីបាច់កូនទាំងពីរអោយធំដឹងក្តី ប្រកបដោយព្រហ្មវិហារធម៌ទាំងបួន។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំយកចិត្តទុកដាក់ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការផ្ទេរនូវចំណេះដឹង បង្ហាត់បង្រៀនប្រៀនប្រដៅ និងផ្តល់បទពិសោធន៍ជីវិតល្អៗមួយចំនួនដល់ពួកខ្ញុំផងដែរ។

ជាពិសេសលោកសាស្ត្រាចារ្យ **តា សុទ្ធា** ដែលជាសាស្ត្រាចារ្យប្រកដដោយសមត្ថភាព គុណធម៌ និងមានចំណេះដឹងយ៉ាងទូលំទូលាយដែលបានផ្តល់កិត្តិយសធ្វើជាគ្រូណែនាំ ផ្តល់យោបល់ឯកសារ រួមទាំងកែប្រែកំហុស និងជួយសម្រួល ការសរសេរសារណារបស់ពួកយើងអោយបានសម្រេចជោគជ័យចេញជាសមិទ្ធផលមួយយ៉ាងរលូនផងដែរ ។

ជាទីបញ្ចប់យើងសូមផ្គងអញ្ជលីដើម្បីថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្តាយ ក្រុមគ្រួសារ ឯកឧត្តមសាកលវិទ្យាធិការ លោក លោកស្រីដែលជាថ្នាក់ដឹកនាំទាំងអស់ និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ និងជាពិសេសលោកសាស្ត្រាចារ្យ **តា សុទ្ធា** ដែលបានបង្ហាត់បង្រៀននិងណែនាំយើងខ្ញុំអោយកិច្ចការមួយនេះបានសម្រេចចេញជារូបរាង នឹងធ្វើជាប្រទីបដើម្បីជាប្រយោជន៍ដល់អ្នកដែលចង់ចេះចង់ដឹងដែលទាក់ទងទៅនឹងប្រធានបទមួយនេះ សូមអោយជួបតែសេចក្តីសុខ សុខភាពល្អ សុភមង្គល ជោគជ័យគ្រប់ភារកិច្ច រួមទាំងពុទ្ធពរទាំងបីប្រការគឺសុខ: ពល: និងបដិភាន: កុំបីឃ្លៀងឃ្លាត ឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច យើងខ្ញុំមានសេចក្តីសោមនស្សជាពន់ពេកដែល បានបញ្ចប់ការសិក្សាក្នុងរយៈពេលបីឆ្នាំកន្លងមកដោយលទ្ធផលល្អ ហើយនៅក្នុងឆ្នាំទីបួននេះក៏ត្រូវបានជ្រើសរើសអោយក្លាយជានិស្សិត ដែលសរសេរសារណាដើម្បីបញ្ចប់ការសិក្សាទៀតផង ដោយយោងតាមលក្ខខណ្ឌកំណត់ខាងលើនេះ ពួកខ្ញុំក៏បានសម្រេចចិត្តជ្រើសរើសយកប្រធានបទណាមួយ ដែលមានអត្ថប្រយោជន៍ដើម្បីសរសេរជាតឹកតាង និងជាស្នាដៃមួយដែលបន្សល់ទុកបន្ទាប់ពីពួកខ្ញុំបានបញ្ចប់ការសិក្សាទៅ នៅក្នុងនោះពួកយើងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ ហើយពួកខ្ញុំក៏សម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងមុខវិជ្ជាមួយនេះផងដែរ។

ជាអាទិ៍ពួកយើងបានជ្រើសរើសប្រធានបទមួយដែលមានចំណងជើងថា "វិវាទសមុទ្រចិនខាងត្បូងក្នុងបរិបទថ្មីនៃសតវត្សទី២១រវាងភាគីចិន និង ហ្វីលីពីន" ដែលពួកខ្ញុំគិតថាមិនទាន់មានសិស្ស និស្សិត ឬក៏បញ្ញវ័ន្តណាដកស្រង់យកប្រធានបទមួយនេះមកចងក្រងនោះឡើយ ដូច្នេះពេលដែលខ្ញុំចង់ចេះចង់ដឹង ពីបញ្ហានេះធ្វើអោយយើងមានការលំបាកនៅក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធជាភាសាខ្មែរ។ ម្យ៉ាងវិញទៀតនោះ ជម្លោះនេះគឺមានប្រទេសដែលស្ថិតនៅក្នុងសមាគមន៍ជាមួយនឹងយើងជាភាគីពាក់ព័ន្ធច្រើនផងដែរ ប៉ុន្តែដោយសារតែមើលឃើញថាជម្លោះនេះកកើតមកយូររួចហើយ ហើយភាគីបានកំពុងទាមទារ និងអះអាង និងការផ្សះផ្សាក៏មានច្រើន ដូច្នេះពួកខ្ញុំមិនអាចធ្វើការស្រាវជ្រាវគ្រប់ភាគីទាំងអស់ ហើយចងក្រងដាក់នៅក្នុងសារណាមួយនេះឡើយ ដោយសារពេលស្រាវជ្រាវយើងមានកំណត់ ទំហំនៃសៀវភៅក៏មិនអាចធំហួសហេតុ ដូចនេះទើបពួកយើង សម្រេចកាត់យកតែជម្លោះរវាងភាគីហ្វីលីពីន និងចិន យកមកធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយ ដោយមើលឃើញថាវិវាទរវាងប្រទេសទាំងពីរពិតជាគួរអោយចាប់អារម្មណ៍ពោលគឺអាចនិយាយបានថា មិនមែនត្រឹមជាជម្លោះរវាងភាគីចិន និង ហ្វីលីពីន ប៉ុន្តែវាជាការប្រឈមមុខគ្នានូវមនោគមន៍វិជ្ជាកុំម្មុយនីស្តដែលមានភាគីចិនជាតួអង្គសំខាន់ និងមនោគមន៍វិជ្ជាសេរីដែលមានភាគីហ្វីលីពីន ក៏ដូចជាសម្ព័ន្ធមិត្ត ដែលជាបិតាមនោគមន៍វិជ្ជាសេរីគឺសហរដ្ឋអាមេរិកផងដែរ។ ដូច្នេះយើងឃើញថាប្រធានបទមួយនេះពិតជាគួរអោយចាប់អារម្មណ៍ដែលមិនគួរមើលរំលងនោះឡើយ។

ជាចុងក្រោយ យើងសូមធ្វើការសូមអភ័យទោសរាល់កំហុសឆ្គងទាំងឡាយណាដែលកើតមានឡើងដោយអចេតនាដោយសារចំណេះដឹងពួកយើងនៅមានកម្រិត ហើយណាមួយឯកសារសុទ្ធតែបកប្រែពីភាសាអង់គ្លេស អាស្រ័យហេតុនេះហើយបើមានឃ្លាឃ្លោងសំនួនវាចារគ្រង់ណាមិនពិរោះក៏សូមមេត្តាខន្តីអភ័យទោសផង ហើយយើងខ្ញុំក៏សូមស្វាគមន៍រាល់ការរិះគន់បែបស្ថាបនាពីសំណាក់អស់លោក សាស្រ្តាចារ្យ និស្សិត មិត្តអ្នកអាន និង បងប្អូនទាំងអស់គ្នាដោយសេចក្តីគោរព និងសោមនស្សរីករាយ។

# មាតិកា

**តារាងអក្សរកាត់**......iii

**សេចក្តីផ្តើម**...... **១**

១. លំនាំបញ្ហា ......១

២. ចំណោទបញ្ហា......២

៣. គោលបំណងនៃការស្រាវជ្រាវ ......២

៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ......២

៥. ទំហំ និងដែនកំណត់......៣

៦. វិធីសាស្ត្រស្រាវជ្រាវ......៣

៧. រចនាសម្ព័ន្ធស្រាវជ្រាវ ......៣

**ជំពូកទី១**

**បុព្វហេតុនៃជម្លោះដែនសមុទ្រចិនខាងត្បូងរវាង ភាគីចិន និង ហ្វីលីពីន**

ផ្នែកទី១៖ សញ្ញាណទូទៅជុំវិញសមុទ្រចិនខាងត្បូង......៤

១. ទីតាំងភូមិសាស្ត្រ ......៤

២. អត្ថប្រយោជន៍នៃសមុទ្រចិនខាងត្បូង......៥

៣. ការអះអាងអំពីអធិបតេយ្យរបស់ភាគីវិវាទ ......៧

ផ្នែកទី២៖ ទំនាក់ទំនង និង យុទ្ធសាស្ត្ររបស់ភាគីជម្លោះដែលបង្កើតឲ្យមានភាពតានតឹងក្នុងដែនសមុទ្រចិនខាងត្បូង ......៧

១. សកម្មភាព និង ប្រតិកម្មរបស់ភាគីជម្លោះ ......៧

១.១.សកម្មភាព និងប្រតិកម្មរបស់ភាគី ហ្វីលីពីន ......៧

១.២.សកម្មភាព និងប្រតិកម្មរបស់ភាគី ភាគីចិន ......៩

២. គោលនយោបាយរបស់ភាគីជម្លោះ......១៤

២.១.គោលនយោបាយរបស់ភាគីចិនក្នុងបញ្ហាជម្រោះ ......១៤

២.២.គោលនយោបាយរបស់ភាគីហ្វីលីពីន ......១៩

៣. ភាពតានតឹងនៅក្នុងដែនសមុទ្រចិនខាងត្បូង......២០

**ជំពូកទី២**

**ភាពធូរស្រាល និងការឈានទៅរកដំណោះស្រាយដើម្បីបញ្ចប់ជម្លោះ**

ផ្នែកទី១៖ អន្តរគមន៍របស់អង្គការអន្តរជាតិលើបញ្ហាសមុទ្រចិនខាងត្បូង ......២៤

១.អន្តរាគមន៍របស់អាស៊ាន......២៥
២. សេចក្តីថ្លែងការណ៍របស់អង្គការអន្តរជាតិនានា......២៦
២.១. សេចក្តីថ្លែងការណ៍របស់សហគមន៍អឺរ៉ុប......២៦
២.២ សេចក្តីថ្លែងការរបស់ G៧......២៦
២.៣. សេចក្តីថ្លែងការណ៍របស់អង្គការNATO......២៨
២.៤. សេចក្តីថ្លែងការណ៍របស់អង្គការសហប្រតិបត្តិការស៊ាងហៃ......២៨
ផ្នែកទី២៖ សេចក្តីសម្រេចរបស់ PCA......២៩
១.ការទាមទាររបស់ហ្វីលីពីន......៣០
២.ការទាមទាររបស់ចិន......៣២
៣. ការសម្របសម្រួល និងអនុសាសន៍របស់ PCA ទៅលើបញ្ហាសមុទ្រចិនខាងត្បូង......៣៥
ផ្នែកទី៣៖ការបញ្ចប់ និងភាពស្ងប់ស្ងាត់លើសមុទ្រចិនខាងត្បូង......៤១
១.ការចរចារ និងការឯកភាព......៤១
២. ការផ្លាស់ប្តូរគោលនយោបាយរបស់ហ្វីលីពីន......៤១
២.១ ទំនាក់ទំនងរវាង អតីតប្រធានាធិបតីហ្វីលីពីន និងអតីតប្រធានាធិបតីនៃសហរដ្ឋអាមេរិក Barack Obama......៤១
២.២ ទំនាក់ទំនងរវាងហ្វីលីពីន និងសហរដ្ឋអាមេរិកក្នុងអាណត្តិលោកRodrigo Duterte អំពីបញ្ហាសមុទ្រចិនខាងត្បូង......៤២
**សេចក្តីសន្និដ្ឋាន......៤៥**
**ការផ្តល់អនុសាសន៍......៤៧**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងអក្សរកាត់

| ល.រ | អក្សរកាត់ | ពាក្យពេញជាភាសាអង់គ្លេស |
|---|---|---|
| ០១ | ASEAN | Association of Southeast Asian Nations |
| ០២ | UNCLOS | United Nations Convention on the Law of the Sea |
| ០៣ | UN | The United Nations |
| ០៤ | ICJ | The International Court of Justice |
| ០៥ | PCA | The Permanent Court of Arbitration |
| ០៦ | US | The United State of America |
| ០៧ | EEZ | An Exclusive Economic Zone |
| ០៨ | DOE | Department of Energy |
| ០៩ | AFP | The Armed Forces of The Philippines |
| ១០ | FLEC | Fishery Law Enforcement Command |
| ១១ | ISR | Intelligence, Surveillance, and reconnaissance |
| ១២ | ADIZ | An Air Defense Identification Zone |
| ១៣ | DOC | Declaration on the Conduct of Parties in the South China Sea |
| ១៤ | COC | Code of Conduct |
| ១៥ | PLA | The People´s Liberation Army Navy |
| ១៦ | AWACS | Airborne Warning and Control System |

| | | |
|---|---|---|
| ១៧ | MND | Ministry of National Defense |
| ១៨ | SAMs | Surface to Air Missile |
| ១៩ | DFA | The Department of Foreign Affairs |
| ២០ | ASCMs | Anti-Ship Cruise Missiles |
| ២១ | EU | The European Union |

## ឯកតារង្វាស់ប្រវែង និងខ្នាត

| |
|---|
| ១ Million = $១ \times ១០^{៦}$ |
| ១ Billion = $១ \times ១០^{៩}$ |
| ១ Trillions = $១ \times ១០^{១២}$ |
| ១ Feet = ០.០០០៣ គម<br>= ០.៣០៥ ម |
| ១ Nautical Mile (១ Mile) = ១.៨៥២ គម |

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

បណ្តារដ្ឋនៅលើពិភពលោកយើងនេះ ភាគច្រើនគឺសុទ្ធតែមានលំហដែនដី ដែនអាកាស និងដែនសមុទ្រ ប៉ុន្តែមិនសុទ្ធតែដូចគ្នាទាំងអស់នោះទេ រដ្ឋខ្លះក៏មានទាំងលំហអាកាស ដែនដី និងដែនសមុទ្រ ជាក់ស្តែងដូចជាប្រទេស កម្ពុជាយើងជាដើម ដែលមានទាំងដែនដី ដែនអាកាស និងដែនសមុទ្រដែលគ្របដណ្តប់ភាគខ្លះនៃខេត្តទាំងបួនរបស់យើងដែលរួមមាន ខេត្តកំពត កែប ព្រះសីហនុ កោះកុង។ យើងក្រឡេកមកមើលរដ្ឋដែលគ្មានដែនសមុទ្រវិញគឺ ប្រទេសឡាវដែលរដ្ឋនេះ មានតែដែនដី និងដែនអាកាស ហើយផ្លូវទឹកដែលសំខាន់ សម្រាប់នាវាចរណ៍នោះគឺ ទន្លេមេគង្គនោះឯង។ ដែនសមុទ្រអាចជាប្រភពធនធានយ៉ាងសំខាន់ ពោលគឺនៅលើដែនដីយើងអាច ប្រកបរបរផ្សេងៗដូចជាកសិកម្ម ឧស្សាហកម្ម រួមទាំងអាចជាផ្លូវគមនាគមន៍សម្រាប់ធ្វើការទំនាក់ទំនងយ៉ាងសំខាន់ ចំណែកឯដែនទឹកវិញ ក៏ជាផ្លូវគមនាគមន៍ និងជាប្រភពនៃធនធានដ៏ធំធេងផងដែរក្រៅពីការនេសាទយក មច្ឆា និងសត្វសមុទ្រផ្សេងទៀតក៏នៅមានដូចជា រ៉ែប្រេងកាតនៅក្រោមបាតសមុទ្រយ៉ាងសំខាន់ ដែលជាប្រភពធនធានកម្រដែលប្រៀបប្រដូចជាវត្ថុទិព្វដែលមានតម្លៃនរណាៗក៏ប្រាថ្នាចង់បាន ដូច្នោះហើយទើបមានជម្លោះកើតឡើងដែលភាគច្រើនគឺកើតឡើងនៅ តំបន់ដែនសមុទ្រដែលមានទ្រព្យកំណប់មួយ ចំនួនបានកើតឡើងហើយដោះស្រាយមិនបានជាដុំកំភួន ប៉ុន្តែនៅក្នុងបរិបទនេះយើងខ្ញុំសូមលើកយក "តំបន់ដែនសមុទ្រចិនខាងត្បូង" ដែលជាតំបន់ជម្លោះយ៉ាងក្តៅគគុករវាងភាគីជម្លោះនានា ដែលមានសមាជិក អាស៊ាន និងភាគីមហាអំណាចចិន ដែលនៅក្នុងនោះបញ្ហាដែលតានតឹងបំផុតនោះគឺ ភាគីហ្វីលីពីន ជាមួយនឹងភាគីចិនដែលយើងនិងលើកយកមកពិភាក្សា និងស្រាវជ្រាវ។

យើងឃើញថាតំបន់ជម្លោះរវាងចិន និងហ្វីលីពីនជាតំបន់ដែលសម្បូរទៅដោយធនធានមហាសាល ដែលធ្វើអោយភាគីនីមួយៗទាមទារតាមអ្វីដែលខ្លួនចង់បានបើទោះបីជាមានការសម្រេច ឬអន្តរាគមន៍ពីភាគីទីបី ឬស្ថាប័នអន្តរជាតិក៏ដោយ។ បញ្ហាដែលចម្បងនោះគឺភាគីមិនព្រមទទួលស្គាល់អ្វីជាការពិត ថ្វីត្បិតមានការចង់បាននូវអ្វីទៅតាមចំណង់ដែលខ្លួនទាមទារ កត្តាទាំងនោះហើយទើបធ្វើឲ្យមានការប្រឆាំងគ្នាទៅវិញទៅមក រកចំណុចរួមដែលអាចអោយមានឥទ្ធិពលក្នុងការបញ្ចប់ជម្លោះទាំងស្រុងមិនបាន បានត្រឹមតែទប់ស្កាត់មិនអោយមានការផ្ទុះអាវុធជាលក្ខណៈទ្រង់ទ្រាយធំកើតឡើងប៉ុណ្ណោះ ។

## ២. ចំណោទបញ្ហា

ការអនុម័តនូវសេចក្តីសម្រេចមួយចំនួនដែល ធ្វើឡើងដើម្បីរកដំណោះស្រាយនិងរក្សាសុខសន្តិភាព ស្ថេរភាព ដូចជា DOC ជាដើមក៏បានធ្វើអោយកម្តៅនៃជម្លោះដែនសមុទ្រចិនខាងត្បូងថមថយបានខ្លះផងដែរ។ បូកផ្សំនិងយន្តការរបស់អង្គការសហប្រជាជាតិ ដែលបានបង្ហាញជារូបភាពទៅតាមនីតិសមុទ្ររបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៨២ ក៏បានលើកជាគោលការណ៍ចំបងដើម្បីធ្វើជាយន្តការរួមនៃការដោះស្រាយនិងទទួលយកដោយមាន ការព្រមព្រៀងគ្នារបស់ភាគីទាំងពីរផងដែរមុននឹងដាក់បញ្ចូល។ ដោយយោងទៅតាមតថភាពជាក់ស្តែងធ្វើអោយយើងមានចំណោទបញ្ហាដែលត្រូវតែចោទសួរឡើងដូចជា៖

១. តើអ្វីទៅជាវិវាទសមុទ្រចិនខាងត្បូង?

២. មូលហេតុអ្វីដែលបណ្តាលអោយមានវិវាទនៅសមុទ្រចិនខាងត្បូង?

៣. មូលហេតុអ្វីបានជាវិវាទនេះពិបាកក្នុងការរកដំណោះស្រាយ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទ "វិវាទសមុទ្រចិនខាងត្បូងក្នុងបរិបទថ្មីនៃស.វទី២១ រវាងភាគីចិន និងហ្វីលីពីន" មានគោលបំណងដូចតទៅ៖

- ស្វែងយល់ពីប្រភពបញ្ហាដែលធ្វើអោយមានភាពតានតឹងនៅតំបន់ជម្លោះ
- មូលហេតុដែលបណ្តាលអោយកើតមានជម្លោះរយៈពេលវែង
- មូលហេតុដែលធ្វើអោយជម្លោះមិនអាចរកដំណោះស្រាយ
- យន្តការនៃការដោះស្រាយ
- ការសម្រេចរបស់ PCA
- បង្ហាញដំណោះស្រាយ តាមរយៈអនុសាសន៍សម្រាប់ដំណោះស្រាយបញ្ហាដែលកំពុងប្រឈម

## ៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺធ្វើអោយមានការបើកបង្ហាញយ៉ាងលម្អិតអំពីបញ្ហាដែលពាក់ព័ន្ធជាពិសេសគឺមូលហេតុដែលធ្វើអោយជម្លោះដែលកើតឡើង មកជាយូរមកហើយនេះចេះតែបន្តមិនឈប់ឈរតាំងពីស.វ ទី១៩ រហូតមកដល់ស.វទី២១ នេះនៅតែមិនមានដំណោះស្រាយមួយដែលមានប្រសិទ្ធិភាព ប៉ុន្តែបែរជាកាន់តែធ្វើអោយបញ្ហាតានតឹងទៅវិញ ។ ឯកសារនេះផងដែរក៏ជាជំនួយក្នុងគន្លឹះនៃ ការរកផ្លូវដោះស្រាយជម្លោះនេះបានមួយចំនួនផងដែរដែល ស្តែងឡើងតាមរយៈការផ្តល់ជាអនុសាសន៍ ហើយឯកសារនេះផងដែរក៏អាចជាជំនួយដល់អ្នកដែលចង់ដឹងចង់យល់ពីបញ្ហានេះធ្វើជាឯកសារយោងបានផងដែរ។

## ៥. ទំហំ និងដែនកំណត់

កិច្ចការស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើតែបញ្ហាជម្លោះដែលកើតមានឡើងរវាង ភាគីចិន និង ហ្វីលីពីននៅក្នុងស.វទី២១នេះប៉ុណ្ណោះមិនមែនគ្របដណ្តប់លើបញ្ហាជម្លោះលើគ្រប់ភាគីទាំងអស់នៃជម្លោះនេះទេ។ ហើយឯកសារដែលពាក់ព័ន្ធនឹងបង្ហាញតែក្នុងរង្វង់ប្រធានបទប៉ុណ្ណោះ មិនបង្ហាញជារួមនោះឡើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏វាជាឯកសារមួយដែលមានវិសាលភាពនៅក្នុងការបង្ហាញអំពីដែនជម្លោះរវាងភាគីមួយចំនួននៅក្នុងជម្លោះមួយនេះដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីចងក្រងឯកសារមួយនេះឡើងយើងបានធ្វើការស្រាវជ្រាវពីអ៊ិនធឺណេតជាចំបង ដោយធ្វើការបកប្រែមកជាភាសាជាតិ នូវឯកសារមួយចំនួនដែលពាក់ព័ន្ធជាជាង សម្រង់តាមឯកសារជាភាសាជាតិស្រាប់ ដោយហេតុថាយើងមានការលំបាកខ្លះៗដែលស្វែងរកប្រភពឯកសារជាភាសាជាតិ ដោយបញ្ហាទាំងអស់នេះមិនសូវជាមានសរសេរលម្អិតរវាងភាគីណាមួយ និងភាគីណាមួយនោះឡើយ ពោលគឺភាគច្រើនមានតែសរសេរជាលក្ខណៈជារួម នៃជម្លោះមួយនេះតែម្តង ហើយមួយវិញទៀតយើងចង់អោយការស្រាវជ្រាវមួយនេះជាឯកសារដែលសរសេរចុងក្រោយអំពីរឿងរ៉ាវដែលទើបកើតមាន និងវិវត្តន៍ថ្មីៗនាពេលបច្ចុប្បន្ននេះ។

ចំពោះការប្រមូលទិន្និន័យវិញ ពួកយើងធ្វើការស្រង់យកពីវែបសាយណាដែលអាចទុកចិត្តបានប៉ុណ្ណោះ ឬក៏គេហទំព័រទាំងឡាយណាដែលអាចជឿទុកចិត្តបានតាមរយៈការទទួលស្គាល់ពីអ្នកអានទូទាំងសកលលោក។ ចំណែកឯឯកសារមួយចំនួនទៀតពួកយើងស្រង់យកមកពីសៀវភៅ និងបណ្ណាសារពត៌មានក្នុងស្រុកផងដែរ។

## ៧. រចនាសម្ព័ន្ធស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធានបទថា "វិវាទសមុទ្រចិនខាងត្បូងក្នុងបរិបទថ្មីនៃស.វទី២១ រវាងភាគីចិន និងហ្វីលីពីន" ត្រូវបានបែងចែកជាបួនផ្នែកធំៗដូចខាងក្រោម:

- សេចក្តីផ្តើម៖ គឺជាផ្នែកដំបូងគេបង្អស់ដែលអធិប្បាយអំពី លំនាំបញ្ហា ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ រួមទាំងវិធីសាស្ត្រនៃការស្រាវជ្រាវផងដែរ។
- ជំពូកទី១
- ជំពូកទី២
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី១

# មូលហេតុនៃជម្លោះដែនសមុទ្រចិនខាងត្បូងរវាង ភាគីចិន និង ហ្វីលីពីន

## ផ្នែកទី១៖ សញ្ញាណទូទៅជុំវិញសមុទ្រចិនខាងត្បូង

វិវាទដែនសមុទ្រចិនខាងត្បូងសំដៅលើជម្លោះដែនដី និង ដែនអធិបតេយ្យនៅប្រជុំកោះ Paracels និង Spratlys។

### ១. ទីតាំងភូមិសាស្ត្រ

សមុទ្រចិនខាងត្បូងមានវិសាលភាពប្រមាណ ៣.៥០០.០០គម$^2$ ជាតំបន់សមុទ្រមួយ ដែលមានសណ្ឋានធំលំដាប់ទី៤ និង ជាចំណែកមួយរបស់មហាសមុទ្រប៉ាស៊ីហ្វិក។

តំបន់សមុទ្រចិនខាងត្បូងនេះសំបូរទៅដោយកោះដែលបង្កើតបានជាប្រជុំកោះបួនគឺPartas Islands, Scarborough Reef and Macclesfield Bank, Paracel Islands និង Spratlys Islands។

- កោះ Pratas Islands* លាតសន្ធឹងជាង២០០ម៉ែល៍ស្ថិតនៅភាគពាយ័ព្យនៃទីក្រុងហុងកុង ហើយកោះនេះត្រូវបានទាមទារសិទ្ធិកាន់កាប់ដោយចិន(ដីគោក) និង កោះតៃវ៉ាន់។
- កោះ Scarborough Reef* និង Macclesfield Bank* ស្ថិតនៅភាគខាងជើងនៃសមុទ្រចិនខាងត្បូងដែលនៅចន្លោះប្រទេសហ្វីលីពីន និង ប្រជុំកោះ Paracels Islands*។ Scarborough Reef និង Macclesfield Bank ត្រូវបានទាមទារដោយ ចិន (ដីគោក) ហ្វីលីពីន និង តៃវ៉ាន់។ Scarborough Reef មានទីតាំងស្ថិតនៅប្រវែង ១៣០ម៉ែល៍ ពីកោះ Luzon របស់ប្រទេសហ្វីលីពីន។ រីឯ Macclesfield Bank វិញស្ថិតនៅចន្លោះប្រជុំកោះ Scarborough Reef និង Paracels។ Scarborough Reef និង Macclesfield Bank ជាប្រភពនៃភាពតានតឹងរវាង ប្រទេសចិន និង ប្រទេស ហ្វីលីពីន។
- កោះ Paracel Islands មានទីតាំងស្ថិតនៅភាគខាងជើងនៃសមុទ្រចិនខាងត្បូងហើយ មានចម្ងាយស្មើគ្នាពីឆ្នេរសមុទ្រវៀតណាម និង ឆ្នេរភាគខាងត្បូងនៃប្រទេសចិន (Hainan)។ កោះ Paracel Islands ត្រូវបានទាមទារដោយ ប្រទេសចិន ប្រទេសវៀតណាម និង តៃវ៉ាន់។ នៅមុនសតវត្សទី ២១ ប្រទេសវៀតណាមធ្លាប់កាន់កាប់កោះនោះ តែប្រទេសចិន បានបណ្តេញកងទ័ពវៀតណាមខាងត្បូង ចេញពីកោះ Paracel Islands ក្នុងឆ្នាំ១៩៧៤ ហើយនាពេលបច្ចុប្បន្ននេះ កោះ Paracel Islands ត្រូវបានកាន់កាប់ដោយប្រទេសចិន។ វាក៏ជាប្រភពនៃភាពតានតឹងរវាង ប្រទេស ចិន និង ប្រទេស វៀតណាមផងដែរ។

* សម្គាល់៖ សូមមើលឧបសម្ព័ន្ធទី ០១

- កោះ Spartlys Islands* គឺជាប្រភពនៃភាពតាងតឹងដ៏ខ្លាំងបំផុតនៃជម្លោះក្នុងតំបន់សមុទ្រចិនខាងត្បូងនេះ។ កោះនេះមានទីតាំងស្ថិតនៅចំកណ្ដាលនៃសមុទ្រចិនខាងត្បូង តែម្ដង។ ភាគខាងជើងនៃកោះនេះស្ថិតនៅជិតកោះ Borneo របស់ប្រទេស ប្រ៊ុយណេ រីឯ ភាគខាងកើតឈាងខាងជើងស្ថិតនៅជិតក្រុង Sarawak និង ក្រុងSabah របស់ ប្រទេសម៉ាឡេស៊ី។ ភាគខាងកើតនៃកោះ Spartlys ស្ថិតនៅជិតប្រទេសវៀតណាម ឯភាគ ខាងលិចគឺ នៅជាប់និងប្រទេស ហ្វីលីពីន និង ភាគខាងត្បូងស្ថិតនៅជិតប្រទេសចិន (Hainan)។ កោះនេះត្រូវបានទាមទារដោយ ប្រទេសជាច្រើនដូចជា ប្រទេសចិន តៃវ៉ាន់ ប្រ៊ុយណេ ហ្វីលីពីន វៀតណាម និង ម៉ាឡេស៊ី ដោយសារតែ សណ្ឋានដីនៃភាគខ្លះរបស់កោះ នេះ នៅជាប់ព្រំដែននៃប្រទេសទាំងនោះ[1]។

### ២. អត្ថប្រយោជន៍នៃសមុទ្រចិនខាងត្បូង

ក្រៅពីទីតាំងភូមិសាស្ត្រដែលអំណោយផលហើយនោះ បញ្ហាផ្សេងទៀតដែលបណ្ដាលឲ្យមានការទាមទារតំបន់ជម្លោះ សមុទ្រចិនខាងត្បូងនេះក៏ដោយសារតែវាជាប្រភពនៃធនធានធម្មជាតិដែលផ្ដល់អត្ថប្រយោជន៍ជាច្រើនដល់ភាគីជម្លោះផងដែរ។

ការសិក្សាស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រនានាដែលបង្ហាញពីអត្ថប្រយោជន៍នៃតំបន់ សមុទ្រនេះដូចជា៖ ជាទីតាំងដែលមានធនធានធម្មជាតិច្រើន ជាផ្លូវនាវាចរណ៍ដ៏សំខាន់ ជាមូលដ្ឋានក្នុងការនេសាទ និងជាមូលដ្ឋាននៃនាវាចរក្នុងការត្រួតពិនិត្យមើលសន្តិសុខនៃដែនសមុទ្រ។

ខាងក្រោមនេះ ជាសេចក្ដីអត្ថាធិប្បាយនៃធនធានធម្មជាតិជាច្រើននៃតំបន់សមុទ្រចិន ខាងត្បូងដោយយោងតាមការសិក្សាស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រនិងគ្រឹះស្ថាននានា។

- ➢ រ៉ែប្រេងកាត(Oil resource)៖
  - យោងតាមការសិក្សាស្រាវជ្រាវរបស់ប្រទេសចិនបានបញ្ជាក់ថានៅតំបន់សមុទ្រចិនខាងត្បូងគឺមានរ៉ែប្រេងកាតចំនួន២០០ ពាន់លានធុង (Barrels)។ ចំណែកឯយោងតាមការសិក្សាស្រាវ ជ្រាវរបស់សហរដ្ឋអាមេរិកវិញបានបញ្ជាក់ថារ៉ែប្រេងកាតនៅតំបន់សមុទ្រចិនខាងត្បូងមានចំនួន១១ ពាន់លានធុង (Barrels)។
- ➢ ឧស្ម័នធម្មជាតិ(Natural Gas)
  - ការសិក្សាស្រាវជ្រាវរបស់ប្រទេសចិនបានបញ្ជាក់ថាឧស្ម័ន ធម្មជាតិនៅដែនសមុទ្រមាន

*សម្គាល់សូមមើលឧបសម្ព័ន្ធទី០២

[1] www.bbc.com/news/world-asia-pacific-១៣៧៤៨៣៤៩

ជម្លោះគឺមានចំនួន ៧៥០ trillion Cubic feet រីឯតាមការស្រាវជ្រាវរបស់សហរដ្ឋអាមេរិកវិញបាន បញ្ជាក់ថាក្នុងបរិវេណដែនជម្លោះបានរកឃើញថាបរិមាណរបស់ឧស្ម័នធម្មជាតិមានចំនួន១៩០ trillion Cubic feet[2]។

ក្រាហ្វិកទី១៖ ទិន្នន័យរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិ នៅដែនសមុទ្រចិនខាងត្បូង




ក្រៅពីធនធានធម្មជាតិទាំងនេះហើយ សមុទ្រចិនខាងត្បូងក៏មានអត្ថប្រយោជន៍យ៉ាងខ្លាំង ផងដែរចំពោះនាវា។ សមុទ្រចិនខាងត្បូងជាផ្លូវទឹកដ៏សំខាន់សម្រាប់នាវាចរក្នុងការធ្វើ ជំនួញ។ ដោយសារតែសមុទ្រចិនខាងត្បូងជាតំបន់សមុទ្រមួយដែលមានទំហំធំលំដាប់ ទីបួន ដូចនេះវាជាតំបន់សមុទ្រមួយដែលធ្វើជំនួញយ៉ាងមមាញឹកពីភាគខាងកើតនៃទ្វីបអាស៊ីទៅ មជ្ឈិមបូព៌ា។លើសពីនេះទៅទៀត សមុទ្រចិនខាងត្បូងនេះផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ការ នេសាទដោយ ១២ ភាគរយនៃការផ្គត់ផ្គង់ត្រីក្នុងពិភពលោកគឺយកមកពីសមុទ្រចិនខាងត្បូង។ប្រទេសចិនបានសន្មត់ថាការផ្គត់ផ្គង់គ្រឿងសមុទ្រ ២៥ ភាគរយ ក្នុងពិភពលោកគឺបានមកពី តំបន់សមុទ្រចិនខាងត្បូង[3]។

កត្តាសំខាន់មួយទៀត ដែលប្រទេសជាច្រើនធ្វើការទាមទារយ៉ាងខ្លាំងលើតំបន់សមុទ្រចិន ខាងត្បូងនោះគឺ ការធ្វើនាវាចរណ៍ដោយសេរីលើផ្ទៃទឹកដែលវាជាអត្ថប្រយោជន៍យ៉ាងខ្លាំងលើ បញ្ហាសន្តិសុខ។

[2] https://www.eia.gov/todayinenergy/images/ 2013 04 03/estimated
[3] http://theconversation.com/why-is-the-south-china-sea-so-important-to-the-us-71477

### ៣. ការអះអាងអំពីអធិបតេយ្យរបស់ភាគីវិវាទ

ប្រាកដណាស់និយាយចំពោះភាគីជម្លោះនីមួយៗត្រូវតែលើកអំណោះអំណាងអ្វីមួយជាភស្តុតាងដល់សាធារណៈនិងភាគីរបស់ខ្លួនទើបអាចបញ្ជាក់ថាខ្លួនមានសិទ្ធិ ឬ លទ្ធភាពក្នុងការទាមទារនោះ។ ដូចនេះ ក្នុងបញ្ហាសមុទ្រចិនខាងត្បូងក៏មិនខុសគ្នាដែរ ភាគីទាំងពីរទាំងចិន និង ហ្វីលីពីនក៏បាន បង្ហាញពីសំអាងរបស់ខ្លួនដើម្បីមានសិទ្ធិក្នុងការទាមទារផងដែរ។

ភាគីចិនបានអះអាងចំនែកមួយភាគធំនៃដែនទឹកជម្លោះ តាមរយៈផែនទីនៃខ្សែបន្ទាត់ទីប្រាំបួន(Nine dash line) ដែលត្រូវបានបង្កើតឡើងជាផ្លូវការដោយ សាធារណរដ្ឋចិន (The Republic of China) ក្នុងឆ្នាំ១៩៤៧។ ផែនទីនេះកំណត់ថាខ្សែបន្ទាត់ទីប្រាំបួនលាតសន្ធឹងជាងរាប់រយម៉ែល៍ពីភាគខាងត្បូង នៃខេត្តHainanរបស់ខ្លួន។ ប៉េកាំងនិយាយថាខ្លួនមានសិទ្ធិលើតំបន់ទាំងនេះចាប់តាំងពី២០០០ឆ្នាំមុននៃប្រវត្តិសាស្ត្រមកម្ល៉េះដែលកោះ Paracels* និង Spratlys Islands និងតំបន់ជុំវិញចាត់ទុកថាតំបន់ទាំង នេះជាផ្នែកមួយនៃប្រទេសចិន។

រីឯភាគីហ្វីលីពីនបានអះអាងលើតំបន់ជម្លោះដោយផ្អែកលើទីតាំងភូមិសាស្ត្រនៃប្រទេសរបស់ខ្លួននៅជិតនិងប្រជុំកោះSpratlys Islands។ មួយវិញទៀតទាំងភាគីចិននិងហ្វីលីពីនបានទាមទារតំបន់ Scarborough Shoal ផងដែរដែលតំបន់នេះមានចំងាយជាង១០០ម៉ែល៍ពីហ្វីលីពីនហើយ មានចម្ងាយ៥០០ម៉ែល៍ពីប្រទេសចិនដោយធ្វើការសំអាងផ្អែកតាមភស្តុតាងដូចតំបន់ផ្សេងៗទៀត។

## ផ្នែកទី២៖ ទំនាក់ទំនង និង យុទ្ធសាស្ត្ររបស់ភាគីជម្លោះដែលបង្កើតឲ្យមានភាពតានតឹងក្នុងដែនសមុទ្រចិនខាងត្បូង

### ១. សកម្មភាព និង ប្រតិកម្មរបស់ភាគីជម្លោះ

#### ១.១. សកម្មភាព នឹងប្រតិកម្មរបស់ភាគីហ្វីលីពីន

នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ នាវាល្បាតរបស់ចិនពីរគ្រឿងបានវាយប្រហារនាវាសង្កេតការណ៍ដែលគ្រប់គ្រងដោយ Philippine Department of Energy (DoE) របស់ហ្វីលីពីន ដើម្បីទាញយកធនធានប្រេងនៅ តំបន់ Reed Bank (បច្ចុប្បន្នហៅថាតំបន់ recto Bank នៅប្រទេសហ្វីលីពីន)។ តំបន់ reed Bank លាតសន្ធឹងប្រហែល ៩៥ ម៉ែល៍ ភាគខាងកើតកោះ Spratlys និង ១៥០ ម៉ែល៍ភាគខាងលិចនៃកោះ Palawan ប្រទេសហ្វីលីពីន។ ដោយមានព្រំប្រទល់ដែនទឹកធំជួបគ្នានេះហើយវាបានកើតឡើងនិងប៉ះពាល់ដល់នៅក្នុងតំបន់ EEZ របស់ប្រទេសហ្វីលីពីន ទើបរដ្ឋាភិបាលលោក Aquino III បានប្ដឹងតវ៉ាលើសកម្មភាពនេះទៅកាន់ស្ថានទូតចិននៅក្រុង Manila។ អ្នកនាំពាក្យក្រសួងការបរទេសម្នាក់បានចេញ សេចក្ដីថ្លែងការណ៍ថា ហ្វីលីពីនគ្រាន់តែចង់ឲ្យ មានការពន្យល់ច្បាស់

*សម្គាល់សូមមើលឧបសម្ព័ន្ធទី០២

លាស់ពីមូលហេតុនៃការបង្ករបស់ចិនប៉ុណ្ណោះ។ ស្ថានទូតចិនបានច្រានចោលការលើកឡើងរបស់ហ្វីលីពីនហើយបញ្ជាក់ថាចិនមានអធិបតេយ្យនៅលើទឹកដីនៅកោះ Spratlys និងដែនទឹកនៅជិតតំបន់នោះ។ Beijing បានបន្តឲ្យ Manila សុំការអនុញ្ញាតចិនមុននឹងទាញយកធនធានប្រេងទោះបីនៅក្នុងតំបន់ EEZ របស់ប្រទេសហ្វីលីពីនក៏ដោយ។ លើសពីនេះទៅទៀតចិនបានទទូចឲ្យ Philippines និង ភាគីដែលទាមទារផ្សេងទៀតឲ្យទទួលស្គាល់ការទាមទារដែនទឹករបស់ចិននៅសមុទ្រចិនខាងត្បូង[4]។ អាកប្បកិរិយារបស់ចិននិងសេចក្ដីប្រកាសបដិសេធនឹង ហ្វីលីពីន និង វៀតណាមនៅឆ្នាំ ២០១១ បានធ្វើឲ្យជម្លោះដែនទឹកកាន់តែតានតឹងឡើង។ ដូច្នេះហើយទើប Aquino III មើលឃើញថាហ្វីលីពីនមិនបានបង្កើតនូវកំហុសណាមួយដែលធ្វើអោយមានការប៉ះទង្គិចដោយផ្ទាល់ជាមួយនឹងចិននៅក្នុងបញ្ហាសមុទ្រចិនខាងត្បូងនោះទេ។ ជាមួយនឹងឧបទ្វហេតុដែលបង្កដោយចិនរដ្ឋាភិបាលលោក Aquino III បានប្រញាប់បង្កើនកម្លាំងការការពារដែនទឹករបស់ខ្លួន (The Armed Forces of the Philippines)។ នៅខែ មិថុនា ឆ្នាំ២០១១ ដំណើរការប្រតិបត្តិរបស់រដ្ឋាភិបាលហ្វីលីពីន និង AFP បានព្រមព្រៀងលើការចំណាយ និងការបង្កើនកម្លាំងទ័ពការពារក្នុងរយពេលយូរនិងការចំណាយទ្រង់ទ្រាយធំ។ នៅក្នុងខែតុលា ឆ្នាំ ២០១១ រដ្ឋលេខាធិការក្រសួងការពារជាតិលោក Voltaire Gazmin បានចេញគម្រោងសម្រាប់ ឆ្នាំ ២០១៣ ដល់ ២០១៨ ដែលផ្តោតទៅលើការរៀបចំឡើងវិញនូវកម្លាំងទ័ពឲ្យបានគ្រប់គ្រាន់ដើម្បីប្រឈមមុខតទល់នឹងបញ្ហាបូរណភាពទឹកដី និងសន្តិសុខដែនទឹករបស់ប្រទេស។ គោលដៅការពារដែនដីភ្លាមៗរបស់ហ្វីលីពីនគឺបង្កើតកម្មវិធីការពារព្រំដែនឲ្យបានទូលំទូលាយប៉ុន្តែ "ទូលំទូលាយ" ដែលមានយុត្តិធម៌សម្រាប់ការឃ្លាំមើលការទប់ស្កាត់និងល្បាតព្រំដែនរបស់កងកម្លាំងទ័ពអាកាស និង កងនាវាចរ និង ឆ្មាំឆ្នេរសមុទ្រហ្វីលីពីន ការតាមដាននិងសមត្ថភាពនៃការវាយតម្លៃកម្លាំងតិចតួចនេះលាតសន្ធឹងពីដែនសមុទ្ររបស់ប្រទេសទៅតំបន់ជាប់គ្នានិងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ នេះជាគោលដៅរយៈពេលវែងបើយោងតាមAFPឆ្នាំ២០១១ថាគោលបំណងយុទ្ធសាស្ត្រនេះគឺដើម្បីអភិវឌ្ឍរចនាសម្ព័ន្ធកម្លាំងនិងសមត្ថភាពដែលមានសារៈសំខាន់ក្នុងការរក្សាជំហររារាំងនឹងការឈ្លានពានបរទេសឬការឈ្លានពានពីខាងក្រៅនិងសកម្មភាពខុសច្បាប់ដទៃទៀតខណៈពេលដែលការណែនាំស្តីពីផែនការការពារថ្មី ចែងថាការការពារបូរណភាពទឹកដីនិងដែនអធិបតេយ្យភាពរបស់ប្រទេសជាពិសេសនៅសមុទ្រហ្វីលីពីនខាងលិចបង្កឲ្យមានបញ្ហាប្រឈមផ្នែកសន្តិសុខខ្លាំងបំផុត។ ហេតុដូច្នេះគោលបំណងចុងបញ្ចប់នៃ

[4]"China wants Philippines to Seek Permission before Sprtalys Oil Serch," BBC Monitoring Asia-Pacific,June , 10 2011.

នាយកដ្ឋានគឺដើម្បីបង្កើតនូវកងការពារអប្បបរមាសម្រាប់ការពារដែនដីនិងសន្តិសុខដែនសមុទ្រ។ នេះតម្រូវឲ្យAFPធ្វើការអភិវឌ្ឍន៍នូវកម្លាំងដ៏មានប្រសិទ្ធភាពនៅក្នុងតំបន់ដែលបង្ហាញសមត្ថភាពក្នុងការការពារទឹកដីនិងការឃ្លាំមើលកាន់តែខ្លាំងដើម្បីធានាដល់កោះរបស់ហ្វីលីពីននិងការពារកោះដែលមិនទាន់មានការកាន់កាប់ពីភាគីជម្លោះផ្សេងទៀត។

### ១.២. សកម្មភាព និង ប្រតិកម្មរបស់ភាគីចិន

ចំណោទបញ្ហាដ៏ធំ និងបញ្ហាមិនដាច់ស្រេចនៅក្នុងសមុទ្រចិនខាងត្បូងក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះគឺជាការបំរែបំរួលពន្លិច រឺពាក់កណ្ដាលពន្លិចថ្មនិងថ្មប៉ប្រះទឹករបស់ចិនចូលទៅក្នុងកោះសិប្បនិម្មិត។ ចាប់តាំងពីខែមករាឆ្នាំ ២០១៤ នាវាចិនបានបូមខ្សាច់សចាក់លើផ្កាថ្មនៅចំណុច ៧ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចិននៅលើកោះដែលមានជម្លោះ Spratlys ដូចជា ថ្មប៉ប្រះទឹក Fiery Cross ថ្មប៉ប្រះទឹក Mischief ថ្មប៉ប្រះទឹកSubi ថ្មប៉ប្រះទឹក South Johnson ថ្មប៉ប្រះទឹក Gaven ថ្មប៉ប្រះទឹក Cuarteron និងថ្មប៉ប្រះទឹក Hughes ។ បន្ទាប់ពីការសាងសង់កោះត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរ ប្រទេសចិនកំពុងចាប់ផ្តើមតម្លើងអាគារ ដាក់ពង្រាយកងទ័ព សាងសង់កំពង់ផែអាកាសយានដ្ឋាន តម្លើងប្រព័ន្ធរ៉ាដា និងប្រព័ន្ធឃ្លាំមើលលើកោះនោះ។ការរីកដុះដាលនៃសំណង់អាគារទាំងនេះបានធ្វើឲ្យមានការព្រួយបារម្ភទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការព្រួយបារម្ភភាគច្រើនគឺដោយសារតែការភ័យខ្លាចអំពីគោលបំណងរបស់ប្រទេសចិនក្នុងការប្រើកោះនិងហេដ្ឋារចនាសម្ព័ន្ធថ្មីៗដែលមិនច្បាស់លាស់មកសំអាង។ បញ្ហានេះកាន់តែធ្ងន់ធ្ងរដោយសារតែទីក្រុងប៉េកាំងមិនទាន់បានបញ្ជាក់ពីលក្ខណៈនៃការទាមទារទឹកដីនិងយុត្តាធិការរបស់ខ្លួននៅក្នុងខ្សែបន្ទាត់ទីប្រាំបួនរបស់ខ្លួនដែលគ្របដណ្តប់ជាង ៦០ ភាគរយនៃដែនទឹកនៅក្នុងសមុទ្រចិនខាងត្បូង។អត្ថបទនេះចាប់ផ្តើមដោយធ្វើការសង្ខេបសេចក្តីថ្លែងការអំពីគោលបំណងរបស់ចិនទាក់ទងនឹងកោះសិប្បនិម្មិតដែលចិនកំពុងបង្កើត។

យើងសង្កេតឃើញថាភាគីចិនចេះតែបន្តសកម្មភាពរបស់ខ្លួនឥតឈប់ឈរនៅក្នុងតំបន់កំពុងមានជម្លោះ ជាក់ស្តែងដូចជាការបង្កើតកោះសិប្បនិម្មិត ការនេសាទនៅតំបន់ជម្លោះ ការរុករកថាមពលផ្សេងៗរួមទាំងការបង្កើនសក្តានុពលយោធារបស់ខ្លួនក្នុងតំបន់ជម្លោះទៀតផង។

ខាងក្រោមនេះគឺជាសេចក្តីពន្យល់របស់ចិនទាក់ទងនឹងគោលបំណងនៃការសាងសង់កោះរបស់ខ្លួន៖

នៅពាក់កណ្តាលខែមេសាឆ្នាំ ២០១៥ ក្រសួងការបរទេសចិនបានផ្តល់ការបកស្រាយជាលើកដំបូងអំពីការសាងសង់កោះដ៏ធំរបស់ខ្លួននៅក្នុងសមុទ្រចិនខាងត្បូង។ អ្នកនាំពាក្យ លោក

ស្រី Hua Chunying បានអះអាងថា ការការពារ និងការសាងសង់របស់ប្រទេសចិននៅលើទីតាំងជួរមុខរបស់ខ្លួននៅលើកោះ Spratlys គឺក្នុងគោលបំណងបង្កើនតួនាទីរបស់ខ្លួន ធ្វើឲ្យប្រសើរឡើងនូវការរស់នៅ និងលក្ខខណ្ឌការងាររបស់បុគ្គលិកនៅទីនោះ ការពារអធិបតេយ្យដែនដីនិងផលប្រយោជន៍ដែនទឹក ក៏ដូចជា អនុវត្តការទទួលខុសត្រូវនិងកាតព្វកិច្ចអន្តរជាតិរបស់ចិនក្នុងការស្វែងរកនិងសង្គ្រោះតាមសមុទ្រ ការការពារគ្រោះមហន្តរាយវិទ្យាសាស្ត្រសមុទ្រនិងការស្រាវជ្រាវការសង្កេតឧតុនិយម ការការពារបរិស្ថានសុវត្ថិភាពនាវាចរណ៍ សេវាផលិតផលនេសាទនិងតំបន់ផ្សេងៗទៀត។ នៅពេលបញ្ចប់ការសាងសង់ លោកស្រី Hua បានអះអាងថា "កោះនិងថ្មប៉ប្រះទឹកនឹងអាចផ្តល់សេវាកម្មបានគ្រប់ជ្រុងជ្រោយ និងទូលំទូលាយដើម្បីបំពេញតាមការទាមទារពីផ្នែកស៊ីវិលផ្សេងៗ" ។ ក្នុងពេលជាមួយគ្នានេះដែរ លោកស្រីបានទទួលស្គាល់ថាកោះទាំងនោះនឹង "បំពេញតម្រូវការការចាំបាច់ផ្នែកយោធា" ផងដែរ។

នៅក្នុងកិច្ចពិភាក្សា Shangri-La នៅប្រទេសសិង្ហបុរីនាចុងខែឧសភាឆ្នាំ២០១៥ ឧត្តមនាវីឯក Sun Jianguo តំណាងប្រទេសចិនបានធ្វើសេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យក្រសួងការបរទេសម្តងហើយម្តងទៀតអំពីតួនាទីរបស់កោះនិងថ្មប៉ប្រះទឹកនៅសមុទ្រចិនខាងត្បូង។ លោកបានបន្ថែមថា ស្ថានីយ៍សង្កេតមហាសមុទ្រមួយសម្រាប់អង្គការសហប្រជាជាតិត្រូវបានសាងសង់លើថ្មប៉ប្រះទឹក Yongshu Jiao (Fiery Cross Reef)* និងភ្លើងហ្វា(Lighthouses)*ដែលកំពុងត្រូវបានសាងសង់នៅលើតំបន់ Huayang Jiao (ថ្មប៉ប្រះទឹក Cuarteron Reef) និង Chigua Jiao (South Johnson Reef)* គឺក្នុងគោលបំណងផ្តល់សារប្រយោជន៍ជាលក្ខណៈអន្តរជាតិ។ លោកឧត្តមនាវី Sun បានកត់សម្គាល់ថាប្រទេសចិនមានបំណងប្រើប្រាស់កោះដែលទើបបង្កើតថ្មីនោះដើម្បីបំពេញតម្រូវការការពារចាំបាច់ ប៉ុន្តែលោកមិនបានបញ្ជាក់ច្បាស់ថាតើតម្រូវការទាំងនោះមានអ្វីខ្លះនោះទេ។ ប្រទេសចិនទំនងជាមិនចង់បរិយាយអំពីគោលបំណងដែលខ្លួនគ្រោងនឹងយកប្រជុំកោះSpratlysមកប្រើដើម្បីធ្វើជាមូលដ្ឋាននៃកងកម្លាំងរបស់ខ្លួននោះទេ។

- មូលហេតុដែលអាចកើតមានឡើងរួមមាន:
  - ប្រទេសចិនចង់បំបិទពត៌មាននេះនាពេលនោះ
  - ការសម្រេចចិត្តចុងក្រោយមិនទាន់បានធ្វើឡើងនៅឡើយ
  - ឬវាអាចជាហេតុផលទាំងពីរខាងលើនេះផងដែរ។

ការដំណើរការសាងសង់របស់ចិននៅលើកោះសិប្បនិម្មិត សកម្មភាពមុនៗរបស់ខ្លួននៅក្នុងសមុទ្រចិនខាងត្បូង និងយោបល់របស់ក្រុមអ្នកជំនាញការយោធាចិន ផ្តល់នូវសង្ខិត្តន័យមួយចំនួន

អំពីគោលបំណងដែលមានសក្តានុពលមិនមែនយោធា សម្រាប់ប៉ុស្តិ៍មុខដែលអាចនឹងយកមកប្រើប្រាស់ដូចជាការនេសាទនៅក្នុងតំបន់ទឹកដែលមានជម្លោះ៖

ចំពោះប្រទេសចិន យុទ្ធសាស្ត្រសេដ្ឋកិច្ចនិងភូមិសាស្ត្រនយោបាយគឺមានភាពប្រទាក់ប្រទិនគ្នា ខណៈដែលការការពារកងនាវានេសាទរបស់ចិនកំពុងនាវាចរឆ្ងាយពីទីដែនដែលជាមូលដ្ឋាននៃការទាមទារអធិបតេយ្យ និងជាវិធីមួយដើម្បីអះអាងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើតំបន់នោះដោយការបដិសេធការចូលធ្វើសកម្មភាពរបស់ជនស៊ីវិលនៃប្រទេសដទៃទៀត។ កងនាវានេសាទចិន ដែលជាផ្នែកមួយនៃឧស្សាហកម្មនេសាទត្រីធំបំផុតនៅក្នុងតំបន់ បានចាកចេញឆ្ងាយពីតំបន់ឆ្នេរសមុទ្រដែលមានការនេសាទហួសកម្រិត និងមានការបំពុលរបស់ប្រទេសចិន ហើយក៏កំពុងនាវាចរលើដែនទឹកដែលធ្លាប់ត្រូវបានធ្វើការនេសាទដោយកងនាវារបស់ប្រទេសដទៃដែលបច្ចុប្បន្ននេះត្រូវបានហាមឃាត់ជាញឹកញាប់ពីការចូលដោយកងកម្លាំងអនុវត្តច្បាប់និងនាវាយោធារបស់ចិន។

ការបង្កើតកោះសិប្បនិម្មិតនៅដែនទឹកសម្បូរត្រីនៅប្រជុំកោះSpratlys ដែលចំណាយពេលត្រឹមប៉ុន្មានថ្ងៃពីកំពង់ផែដីគោកមក នឹងអនុញ្ញាតឲ្យកងនាវានេសាទរបស់ប្រទេសចិនចុះចតសម្រាកនិងចាក់ប្រេង ពង្រឹងបន្ថែមឥទ្ធិពលសេដ្ឋកិច្ចរបស់ប្រទេសចិន និងបន្ថែមសិទ្ធិរបស់ខ្លួនទៅនឹងធនធានជាក់ស្តែងរបស់តំបន់នោះ។ បើសិនជាកងនាវានេសាទបរទេសចូលចតនៅលើកោះដែលទើបបង្កើតថ្មីនេះ នោះវានឹងពង្រឹងបន្ថែមបណ្តឹងទាមទារដែនអធិបតេយ្យរបស់ចិន។ ចំពោះប្រជាជាតិអ្នកទាមទារ ចាត់ទុកជនបរទេសដែលនេសាទនៅដែនទឹករបស់ពួកគេថាជាការបង្កឲ្យមានបញ្ហាប្រឈមចំពោះដែនអធិបតេយ្យ ហើយភាពតានតឹងនៃជាតិនិយមបានជំរុញឲ្យមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរសម្រាប់ការចាប់បានជនបរទេសនេសាទខុសច្បាប់ក៏ដូចជាការដាក់សម្ពាធលើរដ្ឋនានាឲ្យការពារអ្នកនេសាទរបស់ខ្លួន។ចិនបង្កើនការល្បាតតាមដែនសមុទ្រពីមូលដ្ឋានដែលទើបសាងសង់ថ្មីទាំងនេះឆ្ងាយពីឆ្នេរសមុទ្រចិន ជាពិសេសកងនាវាចរកងទ័ពរំដោះប្រជាជន (PLAN) ពី "មូលដ្ឋានកងទ័ពជើងទឹក" នៅឯថ្មប៉ប្រះទឹក Mischief Reef ដែលជាមូលដ្ឋានសម្រាប់រដ្ឋបាលជលផលសាធារណរដ្ឋចិន មានន័យថានាវារបស់រដ្ឋាភិបាលជាច្រើនកំពុងស្ថិតទីនោះដើម្បីបំភិតបំភ័យក្រុមនាវានេសាទរបស់ប្រទេសដទៃ និងធ្វើអន្តរាគមន៍នៅពេលនាវារបស់រដ្ឋាភិបាលដទៃទៀតព្យាយាមចាប់អ្នកនេសាទចិន។ ជាឧទាហរណ៍ការអន្តរាគមន៍របស់ចិនត្រូវបានគេឃើញនៅក្នុងឧប្បត្តិហេតុ Scarborough Shoal ក្នុងឆ្នាំ ២០១២ ដែលជាកន្លែងដែលច្បាប់ស្តីពីការអនុវត្តច្បាប់ជលផល (FLEC) របស់ចិនបានរារាំងការចាប់ខ្លួនអ្នកនេសាទចិនដែលត្រូវបានប្រទះឃើញដោយយន្តហោះស៊ើបការណ៍តាមសមុទ្ររបស់ហ្វីលីពីននិងបានរកឃើញដោយឆ្មាំសមុទ្រហ្វីលីពីន ដែលបាន

ប្រមូលផលត្រីសមុទ្រនោះ ហ្វីលីពីនបានប្រកាសថាខុសច្បាប់។ នាវា FLEC ដែលប្រចាំការនៅតំបន់Scarborough Shoal ត្រូវបានបញ្ជូនមកកាន់ទីក្រុងម៉ានីលវិញ បន្ទាប់ពីចិនបានចូលកាន់កាប់តំបន់នោះ ។ បន្ថែមពីការប៉ះទង្គិចគ្នារបស់ភាគីចិនជាមួយហ្វីលីពីន សេណារីយ៉ូស្រដៀងគ្នាមួយបានកើតមានឡើងពាក់ព័ន្ធនឹងនាវានេសាទចិននៅក្នុងដែនទឹកដែលអះអាងដោយឥណ្ឌូណេស៊ីដែលមិនមែនជារដ្ឋទាមទារចំពោះ ដែនជម្លោះនៅក្នុងសមុទ្រចិនខាងត្បូង។

ប្រទេសឥណ្ឌូណេស៊ីបានឃាត់ខ្លួនទូកនេសាទចិនជាច្រើនលើកនៅក្នុងដែនទឹករបស់ក្រុមកោះ Natuna ស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសឥណ្ឌូណេស៊ីដែលមានចម្ងាយជាង ១០០០ម៉ែល៍ពីចិនដីគោក។ ទូកនេសាទចិននៅក្រោមការការពាររបស់នាវា FLEC បានចូលទៅក្នុងទឹក Natuna ជាច្រើនដងហើយត្រូវបានឃុំខ្លួនដោយនាវាឥណ្ឌូនេស៊ីសម្រាប់ការនេសាទខុសច្បាប់។ ក្នុងឆ្នាំ ២០១០ នាវានេសាទរបស់ឥណ្ឌូណេស៊ីបានឃុំខ្លួនទូកនេសាទចិនចំនួន ១០ គ្រឿងដោយចាត់ទុកការចូលទៅក្នុងដែនទឹកឥណ្ឌូនេស៊ីគឺជាចេតនា បន្ទាប់មកប្រទេសទាំងពីរបានធ្វើការសម្របសម្រួលគ្នា។ កងនាវាប្រដាប់អាវុធ FLEC អាចចូលអន្តរាគមន៍ដល់ទូកនេសាទចិនរយៈពេលប្រហែលជាងមួយម៉ោងក្រោយប៉ុណ្ណោះ ដើម្បីអោយមានការដោះលែងទូកនេសាទពីនាវារបស់ឥណ្ឌូណេស៊ី។ កងនាវារដ្ឋាភិបាលចិនមានសមត្ថភាពដើម្បីមកជួយដល់ទូកនេសាទនៅតាមតំបន់ដាច់ស្រយាលនៃសមុទ្រចិនខាងត្បូងបានយ៉ាងឆាប់រហ័ស។ ហេតុដូច្នេះហើយអ្នកនេសាទចិនមិនត្រឹមតែទទួលបានការអនុញ្ញាតពីរដ្ឋាភិបាលក្នុងការចូលទៅក្នុងដែនទឹកឆ្ងាយៗ នោះទេប៉ុន្តែថែមទាំងមានការការលើកទឹកចិត្តនិងឧបត្ថម្ភប្រេងឥន្ធនៈទៀតផង។

ភាពប៉ិនប្រសប់ ជាងនាវាយោធាឬរដ្ឋាភិបាលទៀតនោះគឺ នាវានេសាទរីករាយនឹងអ្នកដើរតួរមិនមែនជាយោធា ប៉ុន្តែបង្ហាញពីវត្តមានរបស់ជាតិ។ ដោយមានការគាំទ្រនិងការលើកទឹកចិត្តជាផ្លូវការ កងនាវានេសាទរបស់ចិនបានក្លាយទៅជា "កងជីវពលលើដែនសមុទ្រ" ឬ "កងទ័ពជើងទឹកជំនួស" ដោយភ្ជាប់ជាមួយទូកនេសាទរបស់ប្រទេសជាគូប្រជែងដែលជាផ្នែកមួយនៃឃ្លាំងវាយលុកឈ្លានពានតាមសមុទ្រ។ ឧត្តមសេនីយ៍ឯក Zhang Zhaozhong នៃកងទ័ពរំដោះប្រជាជនចិនបានផ្សព្វផ្សាយយុទ្ធសាស្រ្តស្ពៃក្តោបជុំវិញតំបន់ដែលមានជម្លោះជាមួយនាវាជាច្រើនប្រភេទពីទូកនេសាទទៅនាវាគ្រប់គ្រងនេសាទទៅនាវាស៊ើបការណ៍សមុទ្រ និងនាវាចម្បាំងកងនាវាចរដើម្បីឲ្យកោះនេះត្រូវបានរុំដោយស្រទាប់ដូចជាស្ពៃក្តោប។ "

ក្រៅពីនេះប្រទេសចិនបានបន្តសកម្មភាពរបស់ខ្លួនបន្ថែមទៀតនៅតំបន់ជម្លោះតាមរយៈការរុករកថាមពលផ្សេងៗនៅជុំវិញដែនកោះមានវិវាទ។

ជាក់ស្តែង វត្តមានរបស់ចិនកាន់តែច្រើនឡើងនៅ ភាគខាងកើតនិងខាងត្បូងនៃសមុទ្រចិនខាងត្បូងនឹងអនុញ្ញាតឲ្យមានការរំខានជាញឹកញាប់ និងទូលំទូលាយជាងមុនចំពោះការរុករកថាមពលនិងការខួងអណ្តូងរ៉ែដែលធ្វើឡើងដោយអ្នកទាមទារសំណាងនៅកន្លែងដែលប្រទេសចិនចាត់ទុកថាជាតំបន់ទឹកដែលមានជម្លោះ។ ការអនុវត្តច្បាប់នាវាបន្ថែមទៀត នៅស្ថានីយ៍ប្រេង ក្នុងទឹកដីប្រទេសសឹង្ហបូរី ប្រទេសចិននឹងមានសមត្ថភាពបន្ថែមទៀតដើម្បីជ្រៀតជ្រែកជាមួយប្រតិបត្តិការទាំងនោះ។ នៅក្នុងឆ្នាំ ២០១១ នាវាចម្បាំងនាវាចរចិនបានកាត់ផ្តាច់ឧបករណ៍រាវរកខ្សែកាបនៃនាវាស្ទង់មតិដែលចុះកិច្ចសន្យាដោយក្រុមហ៊ុនប្រេង Petro Vietnam ។ នៅក្នុងខែមីនាឆ្នាំ ២០១៥ ក្រសួងថាមពលហ្វីលីពីនបានបញ្ជាឲ្យក្រុមហ៊ុនថាមពលផ្អាកការងារលើកិច្ចសន្យានាពេលបច្ចុប្បន្នដោយរងចាំដំណោះស្រាយជម្លោះដែនដីជាមួយប្រទេសចិន។

ទន្ទឹមនឹងនេះប្រទេសចិនបានបង្កើនសក្តានុពលរបស់ខ្លួនលើដែនជម្លោះដោយបង្កើនការយល់ដឹងអំពីដែនសមុទ្រនិងISRរួមទាំងបង្កើតADIZនិងមូលដ្ឋានទ័ពអាកាសនៅក្នុងតំបន់ជម្លោះទៀតផងដើម្បីប្រាកដពីការទទួចទាមទារដែនអធិបតេយ្យលើប្រជុំកោះមានជម្លោះ។

ប៉ុស្ត៍សន្តិសុខរបស់ចិននៅលើកោះ Spratlys នឹងបំពាក់ដោយឧបករណ៍រ៉ាដានិងអេឡិចត្រូនិកដែលនឹងបង្កើនសមត្ថភាពស៊ើបការណ៍សម្ងាត់ និងឈ្លបយកការណ៍ (ISR) របស់ប្រទេសចិននិងសមត្ថភាពនៃការយល់ដឹងអំពីដែនសមុទ្រនៅសមុទ្រចិនខាងត្បូង។ ផ្លូវរត់ថ្មីដែលសាងសង់លើថ្មប៉ប្រះទឹក Fiery Cross នឹងអនុញ្ញាតអោយប្រទេសចិនធ្វើប្រតិបត្តិការយាមល្បាតតាមសមុទ្រនិងយន្តហោះព្រមាននិងត្រួតពិនិត្យអាកាស (AWACS) ប្រសិនបើវាជ្រើសរើសធ្វើ។ ដោយសារវាប្រើនូវបច្ចេកវិទ្យាទំនើបដែលត្រូវបានគេដាក់ពង្រាយនៅលើតំបន់ទាំងនេះប្រទេសចិនអាចមានលទ្ធភាពត្រួតពិនិត្យស្ទើរតែគ្រប់ផ្នែកនៃសមុទ្រចិនខាងត្បូងតាមមូលដ្ឋាននានាបាន ២៤ ម៉ោង ។ សមត្ថភាពទាំងនេះនឹងផ្តល់ឲ្យប្រទេសចិននូវគុណសម្បត្តិជាងប្រទេសជិតខាងដែលខ្សោយជាងខ្លួនហើយបង្កបញ្ហាប្រឈមដល់សកម្មភាពយោធារបស់សហរដ្ឋអាមេរិកនៅក្នុងតំបន់ទៀតផង។

ជាការពិតណាស់ ប្រទេសចិនអាចដាក់ពង្រាយឧបករណ៍បរិក្ខារអាវុធនុយក្លេអ៊ែរ នៅឧបទ្វីបជាច្រើននៅលើកោះសិប្បនិម្មិតរបស់ខ្លួនរួមមាន រ៉ាដា ឧបករណ៍អេឡិចត្រូនិចក្នុងការស្តាប់ មីស៊ីលបាញ់ពីដីទៅអាកាស មីស៊ីលប្រឆាំងនាវា និងយន្តហោះគ្មានមនុស្សបើក។ លើសពីនេះទៀតផែនការនេះអាចដាក់កងនាវាចម្បាំងមួយចំនួននៅលើមូលដ្ឋានទ័ពនៅទីនោះ។

បន្ទាប់ពីបានធ្វើការអង្កេតលើយុត្តិសាស្ត្ររបស់ចិនក្នុងការបង្កើនសក្តានុពលរបស់ខ្លួនតាមរយៈការយល់ដឹងពីដែនសមុទ្រនិងISRហើយនោះ យើងក្រលេកមកមើលសកម្មភាពមួយចំនួនទៀត

របស់ភាគីចិនដូចជាការបង្កើតADIZនិងមូលដ្ឋានទ័ពអាកាសដែលបញ្ជេះភាពតានតឹងកាន់តែខ្លាំងនៅតំបន់មានជម្លោះ។

ខាងក្រោមនេះគឺជាការអធិប្បាយដែលពាក់ពន្ធ័នឹងគម្រោងការបង្កើតADIZនិងមូលដ្ឋានទ័ពអាកាសរបស់ចិន។

នៅខែវិច្ឆិកាឆ្នាំ ២០១៣ ប្រទេសចិនបានបង្កើត ADIZ ជាឯកតោភាគីនៅក្នុងដែនទឹកមានជម្លោះនៅក្នុងសមុទ្រចិនខាងកើត។ នៅពេលនោះឧត្តមសេនីយ៍ឯកនៃ PLA បានបញ្ជាក់ថាយោធាចិនមានផែនការបង្កើត ADIZ មួយនៅក្នុងសមុទ្រនៅជិតសមុទ្ររួមមានសមុទ្រចិនខាងកើត សមុទ្រលឿងនិងសមុទ្រចិនខាងត្បូង។ លោកឧត្តមនាវី Samuel Locklear មេបញ្ជាការបញ្ជាការដ្ឋានសហរដ្ឋអាមេ រិកប្រចាំតំបន់ប៉ាស៊ីហ្វិកបានថ្លែងនៅខែមេសាឆ្នាំ ២០១៥ ថាការទាមទារនៅតំបន់ Spratlys អនុញ្ញាតឲ្យប្រទេសចិន«មានឥទ្ធិពលលើតំបន់ដែលកំពុងចរចារគ្នា»។ ហើយវាអាចជាវេទិកាមួយប្រសិនបើពួកគេចង់បង្កើត ADIZ។ ADIZ នឹងតម្រូវឲ្យយន្តហោះចម្បាំងហោះហើរក្នុងតំបន់ដើម្បីគោរពតាមច្បាប់ដែលកំណត់ដោយចិនរួមទាំងការកំណត់អត្តសញ្ញាណការហោះហើរដោយវត្តមាននៃប្រដាប់បំពងសំឡេងនិងទំនាក់ទំនងតាមវិទ្យុពីអាជ្ញាធរចិន។ នៅពេលដែលចិនប្រកាសអំពី ADIZ នៅ សមុទ្រចិនខាងកើត ក្រសួងការពារជាតិចិនក៏បានប្រកាសថាខ្លួននឹងអនុម័តវិធានការការពារបន្ទាន់ដើម្បីឆ្លើយតបចំពោះយន្តហោះដែលបដិសេធមិនគោរពតាមវិធានរបស់ខ្លួន។ ពេលសួរថាតើប្រទេសចិនមានផែនការបង្កើតការការពារដែនអាកាសកាន់តែច្រើនដែរឬទេ? ឧទាហរណ៍នៅតំបន់សមុទ្រចិនខាងត្បូងអ្នកនាំពាក្យក្រសួងការពារជាតិបានឆ្លើយតបថា "បន្ទាប់ពីការរៀបចំរួចរាល់ប្រទេសចិននឹងបង្កើតADIZផ្សេងទៀតក្នុងពេលសមរម្យណាមួយ" ។

## ២. គោលនយោបាយរបស់ភាគីជម្លោះ

### ២.១. គោលនយោបាយរបស់ភាគីចិនក្នុងបញ្ហាជម្លោះ

ដើម្បីទទួលបានអត្ថប្រយោជន៍ចំពោះបញ្ហាសមុទ្រចិនខាងត្បូង ប្រទេសចិនព្យាយាមបង្កើតគោលនយោបាយមួយចំនួនមកលើតំបន់អាស៊ីអាគ្នេយ៍ ដោយប្រទេសចិនព្យាយាមរឹតបន្តឹងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសមួយចំនួនក្នុងអាស៊ីអាគ្នេយ៍ក៏ដូចជាព្យាយាមពង្រឹងទំនាក់ទំនងឬកិច្ចសហប្រតិបត្តិការជាមួយអាស៊ានច្រើនជាងមុន។ ជាក់ស្តែង ការរឹតចំណងទំនាក់ទំនងដោយសហការជាមួយប្រទេសមួយចំនួនដូចជា ប្រទេសថៃ ប្រទេសកម្ពុជា ប្រទេសឡាវប្រទេសមីយ៉ាន់ម៉ា និង សមាគមន៍អាស៊ាន ផ្ទាល់។

- **ទំនាក់ទំនងចិន និង ប្រទេសថៃ**

ប្រទេសថៃដើមឡើយគឺជាសម្ព័ន្ធមិត្តយ៉ាងស្អិតរមួតមួយរបស់សហរដ្ឋអាមេរិកនៅអាស៊ីអាគ្នេយ៍។ ប្រទេសទាំងពីរមានទំនាក់ទំនងល្អនឹងគ្នាទាំងផ្នែកសេដ្ឋកិច្ច និង យោធា។ ដោយសារ

ទំនាក់ ទំនងល្អជាមួយនឹងអាមេរិកបានធ្វើឲ្យសេដ្ឋកិច្ចប្រទេសមានភាពរីកចំរើនរហូតដល់ក្លាយជាកូនខ្លានៅអាស៊ី[5]។ រីឯផ្នែកការពារជាតិវិញ ប្រទេសទាំងពីរមានទំនាក់ទំនងយ៉ាងល្អហើយបានបង្កើតជា កិច្ចព្រមព្រៀងយោធាមួយឈ្មោះថា Cobra Gold ដែលមានឥទ្ធិពលយ៉ាងខ្លាំងលើបញ្ហាយោធារវាងប្រទេស ទាំងពីរ។ ប៉ុន្តែដោយសារជួបវិបត្តិនយោបាយក្នុងប្រទេស ដោយការធ្វើរដ្ឋប្រហារពីរដងដោយ ទម្លាក់នាយករដ្ឋមន្ត្រីពីររូបគឺ លោកThaksin Shinawatra ក្នុងឆ្នាំ២០០៦ និង អ្នកស្រី Yingluch Shinawatra ក្នុងឆ្នាំ២០១៤ បានធ្វើឲ្យមានភាពប្រែប្រួលក្នុងប្រទេស[6]។ សកម្មភាពនេះបានធ្វើឲ្យប្រទេសជួបនឹងវិបត្តិធ្ងន់ធ្ងរ ចំពោះបញ្ហាសន្តិសុខនិងនយោបាយ។ បន្ទាប់ពីទម្លាក់អតីតនាយករដ្ឋមន្ត្រីនៅឆ្នាំ២០១៤ ប្រទេសថៃត្រូវបានគ្រប់គ្រងដោយ លោក Prayuth Chan-Ocha ដែលចេញពីក្រុមយោធា។ ការកាន់កាប់អំណាចរបស់លោក Prayuth Chan-Ocha បាននាំមកនូវវិបត្តិយ៉ាងច្រើនជាពិសេសគឺទំនាក់ទំនងសម្ព័ន្ធមិត្តជាមួយអាមេរិក។ សហរដ្ឋអាមេរិក គឺជាប្រទេសប្រកាន់ភ្ជាប់ទៅនឹងរបបប្រជាធិតេយ្យ ហើយប្រទេសថៃអាចក្លាយជាដៃគូរឬអាចក្លាយ ជាសម្ព័ន្ធមិត្តជាមួយសហរដ្ឋអាមេរិកបាន ដោយសារតែប្រទេសថៃជាប្រទេសប្រកាន់របបប្រជាធិបតេយ្យ ដែរ[7]។ តែនៅពេលធ្វើរដ្ឋប្រហារទម្លាក់អតីតនាយករដ្ឋមន្ត្រីទាំងពីរដោយជំនួសមកវិញនូវរដ្ឋាភិបាល យោធាដែលឡើងកាន់អំណាចដោយមិនគោរពតាមគោលការណ៍ប្រជាធិបតេយ្យ នោះបានធ្វើឲ្យ ទំនាក់ទំនងប្រទេសថៃនិងរដ្ឋាភិបាលលោកខាងលិចមានការប្រេះឆា។ លើសពីនេះ ប្រទេសនៅ សហភាពអឺរ៉ុបមួយចំនួនបានដាក់សម្ពាធខាងសេដ្ឋកិច្ចមកលើប្រទេសថៃដើម្បីប្រឆាំងនឹងរដ្ឋាភិបាលយោធាថៃ។ មួយវិញទៀត ដោយសារមូលហេតុនេះផងដែរដែលធ្វើឲ្យសហរដ្ឋអាមេរិកចាប់ផ្តើម ពិចារណាឡើងវិញចំពោះទំនាក់ទំនងនៃប្រទេសទាំងពីរ។ ដោយការមិនពេញចិត្តនឹងរបបយោធានៃ សម្ព័ន្ធមិត្តរបស់ខ្លួន សហរដ្ឋអាមេរិកចាប់ផ្តើមទម្លាក់តម្លៃនៃកិច្ចព្រមព្រៀងយោធា (Cobra Gold) រីឯ ផ្នែកសេដ្ឋកិច្ចនិងជំនួយផ្សេងៗវិញក៏មានការប្រែប្រួលដែរ។ ទង្វើនេះធ្វើឲ្យភាគីថៃមានការមិនពេញ ចិត្តនិងសហរដ្ឋអាមេរិកយ៉ាងខ្លាំង ហើយជាការឆ្លើយតបនិងសហរដ្ឋអាមេរិក ថៃបានព្យាយាមរឹតបន្តឹង ទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសចិន។ កាលៈទេសៈនេះធ្វើឲ្យប្រទេសចិនចាប់ផ្តើមមានឥទ្ធិពល មកលើប្រទេសថៃ ចិនព្យាយាមរឹតបន្តឹងទំនាក់ទំនងយ៉ាងល្អជាមួយថៃតាមរយៈការផ្តល់ជំនួយផ្សេងៗ និង ការអញ្ជើញទស្សនៈកិច្ចជាផ្លូវការរួមទាំងបានបង្កើតកិច្ចព្រមព្រៀងយោធានិងសេដ្ឋកិច្ចជាមួយថៃ[8]។ យុទ្ធសាស្ត្រពីរយ៉ាងដែលចិនប្រើដើម្បីរក្សាទំនាក់ទំនងល្អជាមួយប្រទេសថៃគឺ ចិនមិនរិះគន់ឬជ្រៀត ជ្រែកចំពោះការដឹកនាំឬរបបនយោបាយក្នុងប្រទេសថៃឡើយ ទោះបីជារដ្ឋាភិបាលយោធា

[5] https://www.state.gov/r/pa/ei/bgn/2814.htm
[6] https://fas.org/sgp/crs/row/RL32593.pdf
[7] http://asiafoundation.org/2016/3/30/the-curious-case-of-thai-chinese-relations-best-friends-forever/
[8]http://www.japantimes.co.jp/opinion/2015/08/13/commentary/world-commentary/thailand-china-build-ties-convenience/#.WTdnurxiib-

ថៃឬ គណបក្សណាមួយឡើងកាន់អំណាចក៏ដោយក៏ប្រទេសចិននៅតែរក្សាទំនាក់ទំនងល្អនិងទទួលស្វាគមន៍ជានិច្ច។ម្យ៉ាងទៀតដើម្បីរក្សាទំនាក់ទំនងល្អ ចិនតែងតែអញ្ជើញថ្នាក់ដឹកនាំថៃរួមទាំងរាជវង្សានុវង្ស មកទស្សនកិច្ចនៅប្រទេសចិនជាញឹកញាប់[9]។

- **ទំនាក់ទំនងចិន និង ប្រទេសកម្ពុជា**

ចិនជាប្រទេសអាស៊ីដែលមានទំនាក់ទំនងខ្លាំងក្លាជាងគេជាមួយកម្ពុជាបើគិតត្រឹមឆ្នាំ ២០១៦កន្លងទៅ។ ទោះបីជាកម្ពុជា និងចិន មិនមានព្រំដែនជាប់គ្នាក៏ដោយក៏ប្រទេសចិនមានទំនាក់ទំនងវប្បធម៌និងពាណិជ្ជកម្ម ប្រវត្តិសាស្ត្រជាមួយកម្ពុជាមកតាំងពីយូរលង់ណាស់មកហើយ។

ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីចិនលោកWen Jiabao ចាប់ពីថ្ងៃទី ៧មេសាដល់ថ្ងៃទី ៨ ខែមេសាឆ្នាំ ២០០៦ ប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីមួយចំនួននិងសន្ធិសញ្ញានៃភាពជាដៃគូរគ្រប់ជ្រុងជ្រោយនៃកិច្ចសហប្រតិបត្តិការរវាងគ្នា និងគ្នា[10]។ ប្រទេសចិនបានធ្វើពិពិធភណ្ឌជំនួយនិងការវិនិយោគរបស់ខ្លួននៅក្នុងប្រទេសកម្ពុជានិងបានសន្យាផ្តល់ប្រាក់ ៦០០ លានដុល្លារជាប្រាក់កម្ចីនិងជំនួយឥតសំណង[11,12]។ ប្រទេសចិនបានលុបចោលបំណុលជាច្រើនរបស់ប្រទេសកម្ពុជានិងបានផ្តល់ប្រាក់កម្ចីថ្មីចំនួន ១២,៨ លានដុល្លារអាមេរិកសម្រាប់ការសាងសង់អាគារទីស្តីការគណៈរដ្ឋមន្ត្រី និង ការជួសជុលប្រាសាទនិងតំបន់បេតិកភណ្ឌប្រាសាទអង្គរ[13] និង ប្រហែល ២០០ លានដុល្លារអាមេរិកត្រូវបានគេចាត់ទុកជាកម្ចីការប្រាក់ទាបសម្រាប់ការសាងសង់ស្ពានដែលគ្របដណ្តប់លើទន្លេមេគង្គនិងទន្លេសាប។ ប្រទេសចិនបានបង្កើនចំណងមិត្តភាពយ៉ាងរឹងមាំជាមួយកម្ពុជាដោយ ទទួលបានច្រកសមុទ្រដែលអាចអនុញ្ញាតឲ្យប្រទេសចិនធ្វើអាជីវកម្មប្រេងកាតនៅឈូងសមុទ្រគុងកឹង។ ក្នុងអំឡុងពេលទស្សនកិច្ចនេះនាយករដ្ឋមន្ត្រីកម្ពុជា សម្តេចតេជោ ហ៊ុនសែន បានចាត់ទុកប្រទេសចិនថាជា "មិត្តគួរឲ្យទុកចិត្តបំផុត" របស់កម្ពុជា។ ប្រទេសចិនក៏បានបង្កើនទំនាក់ទំនងយោធាផងដែរ។ ចំណែកឯការធ្វើពាណិជ្ជកម្មរវាងកម្ពុជាចិនវិញត្រូវបានគេប៉ាន់ប្រមាណថាមានប្រហែល ៧៣២ លានដុល្លានៅក្នុងឆ្នាំ២០០៦។ ទោះបីជាយ៉ាងណាក៏ដោយប្រទេសកម្ពុជាមានឱនភាពពាណិជ្ជកម្មគួរឲ្យកត់សំគាល់គឺ ៦៣២ លានដុល្លារជាមួយប្រទេសចិនព្រោះ ៦០ភាគរយ នៃផលិតផលនៅក្នុងទីផ្សារកម្ពុជាគឺជាផលិតរបស់ប្រទេសចិន។ គិតត្រឹមឆ្នាំ ២០០៤ ១៦,៥ ភាគរយ នៃការនាំចូលរបស់កម្ពុជាដែលមានតម្លៃ ៥២៧

[9] http://asiafoundation.org/2016/03/30/the-curious-case-of-thai-chinese-relations-best-friends-forever/

[10]https://web.archive.org/web/2007061604520/http://www.jamestown.org/publications_details.php?volume_id=415&issue_id=37040&article_id=230314

[11]https://web.archive.org/web/2007061604152/http://www.jamestown.org/publications_details.php?volume_id=415&issue_id=3704&article_id=2371023

[12] http://news.bbc.co.uk/2/hi/asia-pacific/4890400.stm

[13] http://news.bbc.co.uk/2/hi/asia-pacific/4890400.stm

លានដុល្លារបានមកពីប្រទេសចិនដោយមិនរាប់បញ្ចូលជិត ២០ភាគរយ នៃការនាំចូលដែលបានមកពីហុងកុងដែលមានតម្លៃប្រមាណ ៦១៥ លានដុល្លារ។ សាជីវកម្មថាមពល ចិនបានចាប់ផ្តើមគម្រោង ២៨០លានដុល្លារដើម្បីសាងសង់ស្ថានីយ៍វារីអគ្គិសនីកំចាយដែលមានកម្លាំង ១៩៣ មេកាវ៉ាត់ដែលត្រូវបានគេរាយការណ៍ថាជាគម្រោងវិនិយោគបរទេសធំបំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ រាជរដ្ឋាភិបាលនិងធុរកិច្ចរបស់ចិនបានវិនិយោគទុនរហូតដល់ ២៥៣ គម្រោងដែលមានតម្លៃ ៩២៥ លានដុល្លារនៅក្នុង វិស័យកសិកម្ម រ៉ែ រ៉ែប្រេងកាតលោហៈរថពាសដែកកំពង់ផែសម្លៀកបំពាក់និងទេសចរណ៍។ ដោយសារតែយុទ្ធសាស្ត្ររបស់ចិនក្នុងការពង្រឹងទំនាក់ទំនងដ៏ស្អិតរមួតនៃប្រទេសទាំងពីរទើបធ្វើឲ្យចិនកាន់តែទទួលបានការគាំទ្រនៅក្នុងបញ្ហាជម្លោះដែនសមុទ្រចិនខាងត្បូង ជាក់ស្តែងយោងតាមរបាយការណ៍ក្រសួងការបរទេសចេញផ្សាយបានបញ្ជាក់ថាទំនាក់ទំនងកម្ពុជាចិនបានស្ទុះដល់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកាលពីឆ្នាំ២០១០ហើយតាមរយៈទំនាក់ទំនងដ៏មហិមានេះលោកប្រធានាធិបតីXi JinBing បានមកបំពេញទស្សនៈកិច្ចនៅប្រទេសកម្ពុជាកាលពីខែតុលាឆ្នាំ២០១៦ហើយតាមរយៈទស្សនៈកិច្ចនេះបានបើកផ្លូវឲ្យប្រទេសទាំងពីរចុះកិច្ចព្រមព្រៀងជាមួយគ្នាលើ វិស័យសាធារណៈនិងឯកជនប្រមាណ៣០កិច្ចព្រមព្រៀង[14]។ នេះសរបញ្ជាក់ឲ្យឃើញថាភាគីចិនមានចេតនាពង្រឹងទំនាក់ទំនងជាមួយប្រទេសកម្ពុជាតាំងពីឆ្នាំ២០១០ដើម្បីទទួលបានការគាំទ្រនៅក្នុងអាស៊ាន ដោយសារតែកម្ពុជាគឺជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំកំពូលអាស៊ានក្នុងឆ្នាំ២០១២។

- **ទំនាក់ទំនងចិន និង ប្រទេសឡាវ**

ទំនាក់ទំនង ចិន ឡាវ សំដៅលើទំនាក់ទំនងបច្ចុប្បន្ននិងប្រវត្តិសាស្ត្ររវាងឡាវនិងចិន។ ទំនាក់ទំនងនៃប្រទេសទាំងពីររួមមានពាណិជ្ជកម្ម និង ជំនួយភាគច្រើនក្នុងការស្ថាបនាផ្លូវថ្នល់នៅតាមបណ្តាខេត្តភាគខាងជើងនៃប្រទេសឡាវដោយមិនមាន ការប្រកួតប្រជែងដោយផ្ទាល់ទៅលើផលប្រយោជន៍របស់ថៃឬវៀតណាមនៅក្នុងតំបន់កណ្តាលនិងខាងត្បូង។ ទំនាក់ទំនងរវាងឡាវ និងចិនបានធ្លាក់មកដុនដាបខ្លាំង នៅឆ្នាំ ១៩៧៩ ដោយមានរបាយការណ៍អំពីជំនួយចិននិងការបណ្តុះបណ្តាលកងកម្លាំង តស៊ូរបស់ជនជាតិម៉ុងនៅក្រោមឧត្តមសេនីយ៍Wen Bao នៅខេត្តយូណាននៃប្រទេសចិន ។ ទំនាក់ទំនងអរិយភាពកាន់តែទន់ទៅបន្តិចម្តងៗហើយក្នុងឆ្នាំ ១៩៨៩ លោកនាយករដ្ឋមន្ត្រី Kaysone Phomvihane បានធ្វើទស្សនកិច្ចនៅរដ្ឋធានីប៉េកាំង។ នៅឆ្នាំ ១៩៩១ Kasisun បានសម្រេចចិត្តចំណាយពេលវិស្សមកាលរបស់គាត់នៅក្នុង ប្រទេសចិនជាជាងធ្វើទស្សនកិច្ចតាមប្រពៃណីរបស់គាត់ទៅកាន់សហភាពសូវៀត។ ទំនាក់ទំនងការទូតនិងភាគីត្រូវបានធ្វើឲ្យមានលក្ខ

[14] www.mekongjournal.com

ណៈធម្មតាក្នុងឆ្នាំ ១៩៨៩ ។ ពាណិជ្ជកម្មបានពង្រីកពីការលក់ទំនិញប្រើប្រាស់ក្នុងស្រុកទៅជាការផ្តល់អាជ្ញាប័ណ្ណវិនិយោគទុនចំនួន ១១ នៅក្នុងឆ្នាំ ១៩៩១ រួមទាំងរោងចក្រតម្លើងរថយន្ត។ បន្ទាប់ពីការបង្កើតគណៈកម្មាធិការព្រំដែនរួមរបស់ឡាវចិននៅឆ្នាំ ១៩៩១ កិច្ចប្រជុំដែលបានធ្វើឡើងក្នុងកំឡុងឆ្នាំ ១៩៩២ បាននាំឲ្យមានកិច្ចព្រមព្រៀងមួយដែលកំណត់ព្រំដែនរួមរបស់ពួកគេ។ ការវិនិយោគពាណិជ្ជកម្មនិងពាណិជ្ជកម្មរបស់ប្រទេសចិនជាមួយប្រទេសឡាវមានលក្ខណៈស្ងៀមស្ងាត់ដោយមិនមានអ្វីដែលគួរឲ្យកត់សម្គាល់នោះទេក្នុងឆ្នាំ ១៩៩៣ និង ១៩៩៤ ។ លោក Xi Jinping បានធ្វើកិច្ចចរចាជាមួយប្រធានាធិបតីBounn Hang Vorachith នៅឆ្នាំ ២០១៦ ដើម្បីស្វែងរកការសម្របសម្រួលបន្ថែមទៀតលើកិច្ចការអន្តរជាតិ។

- **ទំនាក់ទំនងចិន និង ប្រទេសមីយ៉ាន់ម៉ា**

ជាច្រើនឆ្នាំកន្លងទៅ ប្រទេសមីយ៉ាន់ម៉ាជួបនឹងវិបត្តិនយោបាយយ៉ាងធ្ងន់ធ្ងរក្នុងប្រទេស។ ប្រទេសនៃសហភាពអឺរ៉ុបជាច្រើនបានព្យាយាមដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើមីយ៉ាន់ម៉ានៅក្នុងអំឡុងពេលដែលរដ្ឋាភិបាលយោធាមីយ៉ាន់ម៉ាកាន់អំណាច។ ស្ថានភាពនេះបានធ្វើឲ្យប្រទេសចិនឆ្លៀតឱកាស ក្នុងការពង្រឹងទំនាក់ទំនងរបស់ខ្លួននិងប្រទេសមីយ៉ាន់ម៉ាដូចនេះទំនាក់ទំនងចិននិងមីយ៉ាន់ម៉ាចាប់ផ្តើមមានភាពស្និតរមួតនៅក្នុងរបបរដ្ឋាភិបាលយោធាកាន់អំណាច។ ប្រទេសចិនព្យាយាមជួយសេដ្ឋកិច្ច មីយ៉ាន់ម៉ាដោយប្រឆាំងនិងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចរបស់ប្រទេសលោកខាងលិចដូចនេះសេដ្ឋ កិច្ចរបស់មីយ៉ាន់ម៉ាចាប់ផ្តើមងើបឡើងវិញដោយសារជំនួយរបស់ប្រទេសចិនតាមរយៈជំនួយខាងផ្នែកសេដ្ឋកិច្ចរបស់ចិនមីយ៉ាន់ម៉ាទទួលបានផលប្រយោជន៍យ៉ាងច្រើនដូចជាការទាក់ទាញវិនិយោគទុនក្រៅប្រទេសនិងការនាំចេញនាំចូលផលិតផលក្នុងស្រុកជាដើម។ មីយ៉ាន់ម៉ានិងចិនតែងតែមានទំនាក់ទំនង ទ្វេរភាគីជាមួយគ្នាយ៉ាងញឹកញាប់ ហើយក្នុងពេលបច្ចុប្បន្នចិនបានក្លាយទៅជាប្រទេសដែលផ្គត់ផ្គង់ធំ បំផុតរបស់មីយ៉ាន់ម៉ា ជាពិសេសតាមរយៈ ជំនួញតាមព្រំដែនរបស់ចិននិងមីយ៉ាន់ម៉ាដែលបានកើនឡើងរហូត ដល់ជាង ៣០ ពាន់លានដុល្លាសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៦[15]។ ក្រៅពីនេះ ប្រទេសចិនក៏បានផ្តល់កិច្ចសហប្រតិបត្តិការខាងផ្នែកវិស័យសាធារណៈដូចជាការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។មួយវិញទៀត កិច្ចសហប្រតិបត្តិការខាងវិស័យយោធារវាងប្រទេសទាំង២ក៏ជាផ្នែកមួយដែលចងភ្ជាប់ ទំនាក់ទំនងប្រទេសទាំងពីរឲ្យប្រសើរជាងមុនផងដែរ។ ដោយសារតែមូលហេតុទាំងអស់នេះហើយទើបធ្វើ ឲ្យប្រទេសចិនមានឥទ្ធិពលលើប្រទេសមីយ៉ាន់ម៉ាក៏ដូចជាមានប្រៀបក្នុងបញ្ហាសមុទ្រចិនខាងត្បូងផងដែរ[16]។

[15] http://press-files.anu.edu.au/downloads/press/p102436/mobile/ch06.html#ftn.d0e5036
[16] http://www.myanmarinsider.com/south-china-sea-conflict-threatens-aseans-growth-and-stability/

ដោយសារតែយុទ្ធសាស្ត្រនិងគោលនយោបាយនៃ ការពង្រឹងទំនាក់ទំនងជាមួយប្រទេសមួយចំនួន ដែលជាសមាជិកអាស៊ាននេះហើយទើបធ្វើឲ្យចិនទទួលបានអត្ថប្រយោជន៍យ៉ាងធំក្នុងបញ្ហា សមុទ្រ ចិនខាងត្បូង។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១២នៅពេលដែលអាស៊ានព្យាយាមចង់បង្កើតកិច្ចព្រមព្រៀង ថ្មីមួយទៀតគឺ COC ក្នុងគោលដៅដើម្បីជាដំណោះស្រាយក្នុងជម្លោះនៅសមុទ្រចិនខាងត្បូងត្រូវបានបដិសេធនិងមិនអាចបង្កើតបានដោយភាគីមួយចំនួនក្នុងអាស៊ាន។ មួយវិញទៀតអាស៊ានមិនអាចប្រកាសពីគោលជំហររបស់ខ្លួនក្នុងបញ្ហាសមុទ្រចិនខាងត្បូង នៅក្នុងកិច្ចប្រជុំកំពូលដែលប្រព្រឹត្តនៅកាលពីថ្ងៃទី០៩ដល់ទី១៣ កក្កដា ឆ្នាំ២០១២ឡើយ ដោយសារតែសមាជិកនីមួយៗមានគោលជំហរ រៀងៗខ្លួនខុសប្លែកពីចិន ចំណែកឯការដោះស្រាយវិញគឺសង្កត់ធ្ងន់ទៅលើការដោះស្រាយបញ្ហាដោយភាគីត្រូវតែ ប្រតិបត្តិគោលការណ៍ដែលបានចែងក្នុងកិច្ចព្រមព្រៀង។ ដោយឡែកភាគីជម្លោះទាំងអស់មិនចុះ សម្រុងនិងគ្នាដោយសារតែចង់រកដំណោះស្រាយតាមការចរចារផ្សេងៗគ្នា។ ភាគី ហ្វីលីពីន វៀតណាម ម៉ាឡេស៊ី ប្រ៊ុយណេគឺចង់រកដំណោះស្រាយតាមរយៈការចរចារដោយពហុភាគីនិងបើកចំហជា មួយចិន ប៉ុន្តែភាគីចិនវិញបែរជាចង់រកដំណោះស្រាយតាមរយៈការចរចារជាលក្ខណៈទ្វេភាគីនិងមិន បើកចំហរ ដោយលើកឡើងថាបញ្ហាជម្លោះទឹកដីគួរតែដោះស្រាយតាមរយៈការពិភាក្សាឬចរចារជា លក្ខណៈទ្វេភាគី ម៉្យាងទៀតចិនមិនចង់ដោះស្រាយបញ្ហាដោយគោរពតាមទម្រង់ឬគោលការណ៍របស់ UNCLOSឡើយ។ ការលើកឡើងទីទៃរបស់ភាគីបានបង្កើតជាបញ្ហាចំរុងចម្រាស់ជាថ្មីក្នុងកិច្ចប្រជុំ កំពូលអាស៊ានជាថ្មីក្នុងឆ្នាំ២០១២[17] ។ ដោយឡែកវិបត្តិមួយទៀតដែលធ្វើឲ្យអាស៊ានមិនអាចប្រកាសពីគោលជំហរនិងដំណោះស្រាយសមស្របណាមួយបាន។ យើងដឹងហើយថាក្នុងការសម្រេចអ្វីគោលការណ៍ឬយុទ្ធ សាស្ត្រអ្វីមួយគឺតម្រូវឲ្យរដ្ឋជាសមាជិកទាំងអស់ឯកភាពគ្នា តែក្នុងបញ្ហាសមុទ្រចិនខាងត្បូងវិញរដ្ឋជាសមាជិកទាំងអស់គឺ ប្រកាន់ពីគោលជំហរប្រទេសរៀងៗខ្លួនដោយចង់រក្សាទំនាក់ទំនងល្អជាប្រទេសចិនដូចនេះទើបអាស៊ានជួបវិបត្តិដោយមិនអាចទទួលបានការឯកភាពរួមគ្នាពីសមាជិកទាំង១០របស់ខ្លួនរហូតដល់មិនអាចសម្រេចជាយុទ្ធសាស្ត្រឬគោលការណ៍អ្វីថ្មីទៀតបាន។

### ២.២. គោលនយោបាយរបស់ភាគីហ្វីលីពីន

ដោយសារតែសកម្មភាពនិងការឈ្លានពានមិនចេះចប់ មិនចេះហើយរបស់ភាគីចិនទៅលើប្រជុំកោះមានវិវាទបានធ្វើភាគីហ្វីលីពីន ចាប់ផ្តើមសម្រេចចិត្តជាថ្មីដើម្បីតទល់ និងចិន ។ កន្លងទៅយើងឃើញថាភាគីចិនហាក់បីដូចជា អាងអំណាចរបស់ខ្លួនដោយគាបសង្កត់លើភាគីជម្លោះផ្សេងៗទៀតដោយសារតែភាគីផ្សេងទៀតជាប្រទេសតូចជាងខ្លួន។ ជាក់ស្តែងក្នុងរយៈពេលកន្លងទៅនៅ

[17] http://www.ide.go.jp/English/Research/Region/Asia/201209_suzuki.html

ក្នុងឆ្នាំ ២០១១ ២០១២ ២០១៣ ភាគីចិនបានបញ្ចេញសកម្មភាពជាច្រើនដែលវាយប្រហារទៅលើភាគីជម្លោះដូចជា ហ្វីលីពីននៅលើកោះ Spratlys និង Scarborough ដូចជាការទាមទារដែនដីជម្លោះម្តងហើយម្តងទៀត ការបំផ្លាញប្រភពធនធានដែលនៅក្នុងដែនជម្លោះ ការធ្វើទារុណកម្មទៅលើអ្នកនេសាទហ្វីលីពីនជាដើម ដោយសារមូលហេតុទាំងអស់នេះហើយធ្វើឲ្យភាគីជម្លោះដែលជាប្រទេសតូចៗ ដូចជាហ្វីលីពីនចាប់ផ្តើមមានប្រតិកម្មតបមកលើចិនវិញ ដោយបង្កើតយុទ្ធសាស្ត្រគោលនយោបាយមួយចំនួនដូចជា ការដាក់ពាក្យបណ្តឹងទៅ PCAក្នុងឆ្នាំ២០១៣។ នៅក្នុងនីតិវិធីនៃបណ្តឹងភាគីហ្វីលីពីនបានបង្ហាញភស្តុតាងផ្សេងៗដើម្បីបញ្ជាក់ពីការទាមទាររបស់ខ្លួន។ លើសពីនេះអ្វីដែលហ្វីលីពីនបានបង្ហាញអំពីភាពមិនពេញចិត្តរបស់ខ្លួនទៅលើសកម្មភាពរំលោភបំពានរបស់ចិនលើដែនអធិបតេយ្យក្នុងតំបន់ជម្លោះ បន្ទាប់មកហ្វីលីពីនស្នើសុំឲ្យPCA រកដំណោះស្រាយនិងយុត្តិធម៌សារជាថ្មី បន្ទាប់ពីរងការគាបសង្កត់ពីភាគីចិន ជាលទ្ធផលភាគីហ្វីលីពីនទទួលបានជ័យជំនះ ទៅលើការទាមទាររបស់ខ្លួនក្នុងតំបន់ជម្លោះ ប៉ុន្តែដោយសារតែសេចក្តីសម្រេចរបស់ PCA ជាសេចក្តីសម្រេចដោយមិនមានវិសាលភាពគតិយុត្តិទៅដល់គូភាគី ដូចនេះទើបធ្វើឲ្យបញ្ហាជម្លោះនៅតែមានភាពតានតឹងដដែល។ ទោះបីជាភាពតានតឹងនៅតែបន្តទៀតក៏ដោយក៏ហ្វីលីពីន នូវតែព្យាយាមរកដំណោះស្រាយផ្សេងៗដើម្បីការពារដែនអធិបតេយ្យរបស់ខ្លួននៅតំបន់ដែនជម្លោះផងដែរ។ យុទ្ធសាស្ត្រ និងគោលនយោបាយដែលហ្វីលីពីនប្រើលើកនេះគឺព្យាយាមពង្រឹងទំនាក់ទំនងជាមួយភាគីជម្លោះផ្សេងទៀតដូចជា វៀតណាម ម៉ាឡេស៊ី ដើម្បីទទួលបានការគាំទ្រពីគ្នា និងរួមសហការគ្នាដើម្បីមានតុល្យភាព និងចិនមានន័យថាហ្វីលីពីនជាប្រទេសតូចជាងចិន ដូចនេះតែងទទួលរងការគាបសង្កត់ពីចិន រីឯភាគីជម្លោះផ្សេងៗគឺជាប្រទេសតូចដែលជាភាគីជម្លោះនោះ រួមសហការគ្នាជាថ្លុងមួយនោះ ពួកគេអាចនិងមានលទ្ធភាពគ្រប់គ្រងដើម្បីតតាំងនិងចិន។

### ៣. ភាពតានតឹងនៅក្នុងដែនសមុទ្រចិនខាងត្បូង

ក្រៅពីការប្រើប្រាស់ទំនាក់ទំនង និង គោលនយោបាយដែលធ្វើឲ្យស្ថានភាពជម្លោះកាន់តែមានការពិបាកក្នុងការរកដំណោះស្រាយហើយនោះ ស្ថានភាពមួយចំនួនទៀតបានបង្កើតជាភាពតានតឹងដល់ គូភាគីផងដែរ។

ស្ថានភាពនោះគឺកើតឡើងដោយសារតែ ការជ្រៀតជ្រែករបស់ភាគីទីបីដូចជា សហរដ្ឋអាមេរិក ជប៉ុន និង អាស៊ាន។

- ការជ្រៀតជ្រែករបស់សហរដ្ឋអាមេរិកទៅលើបញ្ហាសមុទ្រចិនខាងត្បូង

ប្រទេសចិនទាមទារកោះជាង៨០ភាគរយនៃសមុទ្រចិនខាងត្បូង ប៉ុន្តែចិនមិនត្រួតត្រា ឬ គ្រប់គ្រងលើផ្ទៃដីកោះ Spratlys Islands និង ផ្ទៃទឹកដែលនៅជុំវិញនោះទាំងស្រុងបានទេព្រោះតំបន់ដទៃទៀតត្រូវបានកាន់កាប់ដោយភាគីជម្លោះផ្សេងទៀត។ សញ្ញាណដែលគួរឲ្យកត់សំគាល់មួយទៀត នោះគឺដោយសារការជ្រៀតចូលរបស់សហរដ្ឋអាមេរិក និង ប្រទេសជប៉ុននៅក្នុងដែនដីជម្លោះក៏ជាកត្តា ដែលជំរុញឲ្យចិនមិនអាចគ្រប់គ្រងដែនកោះទាំងមូលបាន[18]។ ការជ្រៀតចូលរបស់អាមេរិកគឺដោយសារ ប្រទេសចិនរំលោភបំពានទៅលើភាគីជម្លោះផ្សេងៗទៀតដែលជាប្រទេសតូចជាងខ្លួន។ តាមរយៈទង្វើនិង សកម្មភាពទាំងនោះ សហរដ្ឋអាមេរិក សន្មត់ថាការប្រើប្រាស់កម្លាំងទ័ពរបស់ចិនដើម្បីប្រឆាំង និង ភាគីជម្លោះដូចជា វៀតណាម និង ហ្វីលីពីនដែលជាសម្ព័ន្ធមិត្តរបស់ខ្លួនគឺជាការប្រកួតប្រជែង ឬ បង្កជម្លោះជាមួយ និង ឧត្តមភាពខាងយោធារបស់អាមេរិកនិងចំណងការទូតរបស់ខ្លួនដែលមានឥទ្ធិពលក្នុងអាស៊ីអាគ្នេយ៍។

ចំពោះសហរដ្ឋអាមេរិកអ្វីដែលជាសញ្ញាណចំបងនៅក្នុងបញ្ហាសមុទ្រចិនខាងត្បូងគឺការប្រកួត ប្រជែងឥទ្ធិពលរបស់របស់ខ្លួននិងចិននៅក្នុងWestern Pacific។ ដូចនេះការចល័តនាវាដោយសេរីនៅលើផ្ទៃទឹកក្នុងតំបន់សមុទ្រចិនខាងត្បូងក្លាយជាកត្តាចំបងចំពោះការប្រកួតប្រជែងរវាងមហាអំណាចចិន និង អាមេរិក។

ចិនបានអះអាងថាខ្លួននឹងគោរពតាមគោលការណ៍ចល័តនាវា និង យន្តហោះដោយសេរីនៅក្នុងតំបន់ នោះ លុះត្រាភាគីត្រូវគោរពតាមលក្ខខណ្ឌដូចជាមិនដាក់ពង្រាយកងទ័ពនៅតំបន់ជម្លោះដើម្បីស៊ើបការឬក៏ធ្វើសកម្មភាពយោធាផ្សេងៗ។ ចំណែកឯសហរដ្ឋអាមេរិកវិញ ចចេសថាផ្លូវទឹកនៅសមុទ្រចិនខាងត្បូងជាផ្លូវទឹកអន្តរ ជាតិដែលជាកម្មវត្ថុដែលអនុញ្ញាតឲ្យចល័តនាវាដោយសេរីហើយយោងតាមនីតិអន្តរជាតិដាក់ពង្រាយកងទ័ពដើម្បីស៊ើបការ ឬ ក៏អាចធ្វើសកម្មភាពខាងផ្នែកយោធាបាន។ ដូចនេះប្រសិនបើ សហរដ្ឋ អាមេរិកយល់ស្របតាមដោយមិនចល័តនាវារបស់ខ្លួននោះទេ Washington នឹងបាត់បង់ជំហររបស់ខ្លួនក្នុងWestern Pacific។ ការអះអាងរបស់ប្រទេសចិនទៅលើអធិបតេយ្យតាមរយៈប្រវត្តិសាស្ត្របានប្រឆាំងនិងការលើកឡើងរបស់សហរដ្ឋអាមេរិកចំពោះការចល័តនាវាដោយសេរីនិងអនុញ្ញាតឲ្យស៊ើបការនិងធ្វើសកម្មភាពណាមួយដែលជាប្រយោជន៍ដល់យោធានៅទីនោះ។ ដោយមានការ គាំទ្រពីប្រទេសមួយចំនួនក្នុងតំបន់ដូចជា ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី និង ប្រទេសឥណ្ឌា បង្កើតឲ្យមានការប្រកួតប្រជែងរវាងអាមេរិកនិងចិនលើផ្ទៃទឹកផ្សេងៗ។ ចិនបានចោទប្រកាន់សហរដ្ឋអាមេរិកថាមានចេតនាលាក់បាំងនិងបំផ្លើសចំពោះការ

[18] Scott,"Conflict Irresolution in the South China Sea,"1041.

អនុញ្ញាតឲ្យចល័តនាវាដោយសេរីដែលបង្កជាបញ្ហាដើម្បី រួបរួមគ្នាជាមួយភាគីជម្លោះផ្សេងទៀតដើម្បីប្រឆាំងនឹងចិន។ ក្រៅពីនេះ នៅក្នុងឆ្នាំ២០១០ សហរដ្ឋអាមេរិកបានប្រកាសថាខ្លួនមានការរំពឹងទៅលើបញ្ហា សមុទ្រចិនខាង ត្បូងដោយសង្ឃឹមថាភាគីជម្លោះនិងដោះស្រាយដោយសន្តិវិធីតាមរយៈការចរចារដោយពហុភាគី រួមទាំងគោរពតាមគោលការណ៍នីតិអន្តរជាតិ[19]។

ក្រៅពីសហរដ្ឋអាមេរិក ប្រទេសជប៉ុនបានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនផងដែរទៅលើបញ្ហាសមុទ្រចិនខាងត្បូង ដោយសារតែកត្តាយុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងរវាងប្រទេសចិន និងសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍ ជប៉ុនបានព្យាយាមជួយភាគីជម្លោះក្នុងការពង្រឹង សមត្ថភាពកងទ័ពរបស់ខ្លួនដើម្បីឲ្យមានតុល្យភាពក្នុងការដោះស្រាយជម្លោះ។ យើងសង្កេតឃើញថាប្រទេសជប៉ុនពុំមែនជាភាគីជម្លោះនោះទេ ហើយក៏មិនមែនជាសម្ព័ន្ធមិត្ត និងភាគីជម្លោះដូចសហរដ្ឋអាមេរិកដែរ ចុះហេតុអ្វីបានជាជប៉ុនចូលរួមក្នុងបញ្ហាសមុទ្រចិនខាងត្បូងដែរ។ នៅក្នុងឆ្នាំ២០១០ លោក Katsuya Okada អតីតរដ្ឋមន្ត្រីការបរទេសមានប្រសាសន៍ថាបញ្ហាចម្រូងចម្រាសនៅក្នុងសមុទ្រចិនខាងត្បូងបានបង្កជាឧបសគ្គចំពោះជំនួញជប៉ុននិងបង្កជាហានិភ័យដល់សន្តិសុខក្នុងតំបន់។ លើសពីនេះនៅក្នុងឆ្នាំ ២០១២ NIDS នៅទីក្រុងតូក្យូ គេបានសង្កេតឃើញថានៅក្នុងសេចក្តីរាយការណ៍ដែលទាក់ទង និង បញ្ហាសមុទ្រចិនខាងត្បូងផ្ទាល់គឺជម្លោះជាមួយប្រទេសជប៉ុន ត្រូវតែយកចិត្តទុកដាក់ចំពោះសកម្មភាពចិន នៅក្នុងជម្លោះសមុទ្រចិនខាងត្បូង។ មូលហេតុចំបងពីរទៀតដែលបញ្ហាសមុទ្រចិនខាងត្បូងបង្កឲ្យមាន ការព្រួយបារម្ភចំពោះភាគីជម្លោះដែលនៅក្បែរសមុទ្រនោះចិនអាចនិងប្រើយុទ្ធសាស្ត្រដូចគ្នា ទៅលើសមុទ្រចិនខាងកើតដែលកំពុងមានជម្លោះជាមួយជប៉ុន។ មួយវិញទៀតការត្រួតត្រា ឬគ្រប់គ្រងសមុទ្រចិនខាងត្បូង និងខាងកើតគឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ចិន។

ដំណោះស្រាយក៏ជាផ្នែកមួយនៃភាពតានតឹងនៃជម្លោះផងដែរ។ ដំណោះស្រាយអាចមានច្រើនប្រភេទទាំងការចរចារ រកអាជ្ញាកណ្តាល ឬប្រើនីតិអន្តរជាតិមកជួយនោះទេ គឺសុទ្ធតែអាចយកមកប្រើដើម្បីដោះស្រាយជម្លោះបាន។ ប៉ុន្តែក្នុងបរិបទជម្លោះនៅសមុទ្រចិនខាងត្បូងវិញដំណោះស្រាយទាំងនោះបែរជាធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងទៅវិញ។ ចំពោះភាគីចិនបានបដិសេធក្នុងការសម្របសម្រួលបញ្ហាតាមរយៈការដោះស្រាយដោយចរចារជាលក្ខណៈពហុភាគី ដោយបារម្ភថាការសម្របសម្រួលតាមវិធីនេះនិងធ្វើឲ្យខ្លួនបាត់បង់ផលប្រយោជន៍។ ផ្ទុយទៅវិញចំពោះភាគីជម្លោះផ្សេងទៀតបានប្តេជ្ញាថាខ្លួន និងសហការជាមួយគ្នានឹងទៅចរចារជាមួយចិន។ ខណៈពេលដែល

[19] Contemporary Southeast Asia, 33(3) 2011, p 282.

ភាគីចិន មានប្រៀបជាងភាគីជម្លោះនៅអាស៊ីអាគ្នេយ៍ប្រសិនបើ អាស៊ានមិនអាចរួមគ្នាបង្កើតឲ្យមានគោលជំហរតែមួយ។

ក្រៅពីភាពចម្រូងចម្រាស ក្នុងការដោះស្រាយដោយការចរចារជាលក្ខណៈពហុភាគី ឬទ្វេរភាគីហើយនោះការដោះស្រាយពឹងផ្អែកលើនីតិអន្តរជាតិរឹតតែធ្វើឲ្យ បង្កជម្លោះនិងមានភាពតានតឹងកាន់តែខ្លាំង។ នីតិសមុទ្រអន្តរជាតិមិនបានទទួលស្គាល់ចំពោះការអះអាងអធិបតេយ្យរបស់ចិនតាមរយៈប្រវត្តិសាស្ត្រនោះទេ។ ដូចនេះចិនមិនអាចយកសំអាងហេតុនេះជាមូលដ្ឋានក្នុងការវិនិច្ឆ័យឬការកាត់សេចក្តីក្នុងបញ្ហាជម្លោះនេះឡើយ។

# ជំពូកទី២

# ភាពចុះសម្រុង និងការឈានទៅរកដំណោះស្រាយដើម្បីបញ្ចប់ជម្លោះ

## ផ្នែកទី១៖ អន្តរាគមន៍របស់អង្គការអន្តរជាតិលើបញ្ហាសមុទ្រចិនខាងត្បូង

### ១. អន្តរាគមន៍របស់អាស៊ាន

សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថា អាស៊ាន ជាសមាគមន៍មួយដែលបង្កើតឡើងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ ១៩៦៧ ដែលមានសមាជិកចំនួន ១០ប្រទេស ហើយបាន អនុម័តធម្មនុញ្ញរបស់ខ្លួននៅថ្ងៃ១៦ ខែធ្នូ ឆ្នាំ២០០៨។ សមាគមនេះបង្កើតឡើងក្នុង គោលបំណងលើកកម្ពស់សេដ្ឋកិច្ច សន្តិភាព និងស្ថេរភាពនៅក្នុងតំបន់។ អាស៊ានក៏បាន ជួយអន្តរាគមន៍នៅក្នុង ជម្លោះសមុទ្រចិនខាងត្បូងផងដែរ។ ក៏ប៉ុន្តែដោយសារតែមានភាពតានតឹង នៅតែបន្តនៅតំបន់ជម្លោះ កម្តៅនៅតែមិនមានការថមថយចុះរវាងភាគីវិវាទទាំងអស់ ទើបមានការព្រមព្រៀងជារួមមួយដើម្បីបង្កើតនូវ DOC ឡើងក្នុងគោលបំណងរកដំណោះស្រាយរួមរបស់ភាគីវិវាទ និងបង្កលក្ខណៈងាយស្រួលក្នុងការដោះស្រាយរបស់ភាគីក្នុងគោលបំណងបញ្ចៀស ការដោះស្រាយដោយកម្លាំងអាវុធ មកជាការរកដំណោះស្រាយដោយសន្តិវិធីវិញ ដោយមើលឃើញយ៉ាងច្បាស់ពីមហាវិនាសកម្មប្រសិនបើមានការផ្ទុះអាវុធកើតឡើង ដូចនេះហើយទើបបណ្តារដ្ឋជាសមាជិកនៃសមាគមន៍អាស៊ានទាំងអស់ និងភាគីចិនបានសម្រេចបង្កើតនូវសេចក្តីប្រកាសមួយនេះឡើង ដោយយកធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងនីតិសមុទ្រឆ្នាំ១៩៨២ ធ្វើជាគោលការណ៍រួម។ ហើយសេចក្តីប្រកាសនេះបានក្លាយជាគោលការណ៍រួមដែលអោយភាគីទាំងអស់ប្រតិបត្តិតាមផងដែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចមួយចំនួនដែលធ្វើអោយភាគីមានការលំបាក និងខាតបង់ប្រយោជន៍ស្របច្បាប់នៅពេលអនុវត្ត ដោយមើលឃើញបែបនោះហើយទើបគេសម្រេចផ្លាស់ប្តូរ និងវិសោធនកម្មត្រង់ចំណុចខ្លះនៃ DOC អោយទៅជា COC វិញ ប៉ុន្តែមិនទាន់បានសម្រេចជាលទ្ធផលផ្លូវការណាមួយនោះឡើយដោយមានការបដិសេធពីភាគីចិន។ ដោយខ្លឹមសារនៃសេចក្តីរបស់ DOC ដែលនឹងបញ្ជាក់ទៅកាន់ភាគីជាសមាជិកមានដូចតទៅនេះ៖

១. គ្រប់ភាគីទាំងអស់បានបញ្ជាក់ជាថ្មីម្តងទៀតថាពួកគេគោរព និងប្តេជ្ញាចិត្តដើម្បីសេរីភាពនៃការរុករក និងហោះហើរលើដែនសមុទ្រចិនខាងត្បូងត្រូវបានផ្តល់ជាលក្ខណៈសកលដែល

បានទទួលស្គាល់ដោយគោលការណ៍នៃច្បាប់អន្តរជាតិ ដែលរួមមានទាំងនីតិសមុទ្រឆ្នាំ១៩៨២ផងដែរ។

២. គ្រប់ភាគីត្រូវពិចារណាលើការអនុវត្តលើការដោះស្រាយទៅលើជម្លោះនៃ ដែនដីរបស់ខ្លួនដោយយុត្តាធិការនៃជម្លោះដោយស្របតាមអត្ថន័យនៃពាក្យថា សន្តិភាព ដោយគ្មានការគំរាមកំហែង ឬការប្រើប្រាស់នូវកម្លាំងប្រដាប់អាវុធផ្សេងៗ ដោយងាកមកធ្វើការចរចារកដំណោះស្រាយ និងពិភាក្សាជាលក្ខណៈមិត្តភាពរវាងគ្នានិងគ្នា និងចរចារដោយអធិបតេយ្យនៃរដ្ឋនីមួយៗ ដោយផ្ទាល់នឹងមិនមានការគាបសង្កត់ ដោយអនុលោមទៅតាមគោលការណ៍នៃច្បាប់អន្តរជាតិ ដែលរួមមាននីតិសមុទ្រឆ្នាំ១៩៨២ផងដែរ។

៣. គ្រប់ភាគីទាំងអស់អាចធ្វើការរុករក ឬក៏អាចធ្វើការសហប្រតិបត្តិការរវាងគ្នាដើម្បីរុករកនៅក្នុងដែនទឹក ដែលរួមមានដូចជាការរុករក ជួយសង្គ្រោះ ការស្រាវជ្រាវដែលមានលក្ខណៈជាវិទ្យាសាស្ត្រ ការការពារបរិស្ថាន និងការទប់ស្កាត់ប្រឆាំងឧក្រិដ្ឋកម្មតាមដែនសមុទ្រ។

៤. គ្រប់ភាគីទាំងអស់អាចលើកទឹកចិត្តរដ្ឋដទៃទៀតឲ្យចូលរួមគោរព គោលការណ៍ដែលមាននៅក្នុង DOC បាន។

៥. គ្រប់ភាគីទាំងអស់ត្រូវអនុវត្ត នៃគោលការណ៍អនុវត្តដោយខ្លួនឯង នៅក្នុងសកម្មភាពទាំងឡាយដែលបង្កឲ្យមានភាពស្មុគ្រស្មាញ ឬក៏បន្ថែមកម្តៅដល់ជម្លោះ និងបង្កផលប៉ះពាល់ដល់សន្តិភាព ឬស្ថេរភាពរដ្ឋដទៃទៀត និងបញ្ឈប់រាល់សកម្មភាពទាំងឡាយណាដែលអាចបង្កអោយមានជម្លោះកើតឡើង។

៦. គ្រប់ភាគីទាំងអស់បានពិចារណាឡើងវិញដែលបញ្ជាក់ថាការអនុម័ត DOC នឹងជម្រុញបន្ថែមទៀត នូវសន្តិភាព និងស្ថេរភាពក្នុងតំបន់ និងយល់ព្រមធ្វើការជាមួយគ្នាជាលក្ខណៈមូលដ្ឋាននៃការមូលមតិគ្នាដើម្បីដើម្បីសម្រេចនូវគោលបំណងមួយនោះទាំងអស់គ្នា។

ទាំងនេះគឺជាខ្លឹមសារដែលមានចែងនៅក្នុង DOC ដែលសរុបមកគឺរាល់ខ្លឹមសារបញ្ជាក់បន្ថែមទាំងអស់នេះគឺមានគោលបំណងបំពេញបន្ថែមនូវខ្លឹមសារមុន និងបញ្ជាក់គ្រប់ភាគីទាំងអស់អោយធ្វើការដោយឈរលើមូលដ្ឋាន សន្តិភាព និងសន្តិភាពនៃប្រជាជាតិទាំងមូល។

ជាដំបូងប្រទេសចិនបានយល់ព្រមនៅក្នុងការចុះហត្ថលេខាទៅលើ DOC ដើម្បីក្លាយខ្លួនជាប្រទេសហត្ថលេខីនៃកតិកាសញ្ញានោះ ហើយថែមទាំងជាភាគីដ៏សំខាន់នៃDOC ដែលបានធ្វើឡើងបន្ទាប់ពីរដ្ឋមន្ត្រីការបរទេសនៃភាគីនីមួយៗបានជួបប្រជុំគ្នានៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ នៅក្នុងទីក្រុងវៀងចន្ទ័នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដែលបានប្រជុំពិភាក្សាពីការបញ្ជាក់

ឡើងវិញជាថ្មីម្តងទៀតអំពីគោលបំណងនៃការបង្កើត DOC នេះឡើងថាតើវាត្រូវបានបង្កើតឡើងដើម្បីអ្វី? ការពិតណាស់ DOC គឺបានបង្កើតឡើងដើម្បីជាតំណាងអោយគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ចំពោះការប្តេជ្ញាចិត្តដើម្បីរឹតចំណងសន្តិភាព ស្ថេរភាព និងការជឿទុកចិត្តគ្នាទៅវិញទៅមករវាងជាតិសាសន៍ និងជាតិសាសន៍។ អាស៊ាន ហើយនិង ចិន គឺបានធ្វើការអនុវត្តគោលការណ៍ទាំងនោះជាថ្មីម្តងទៀត រួមទាំងខ្លឹមសារសេចក្តីដូចដែលមានចែងនៅក្នុង DOC ទាំងមូលផងដែរ។

## ២. សេចក្តីថ្លែងការណ៍របស់អង្គការអន្តរជាតិនានា

### ២.១. សេចក្តីថ្លែងការណ៍របស់សហគមន៍អឺរ៉ុប



សហភាពអ៊ឺរ៉ុបបានចាប់បដិសន្ធិដំបូងតាំងពីឆ្នាំ ១៩៥៧ មកម្លេះ ក៏ប៉ុន្តែបានវិវត្តន៍ខ្លួនមកជាលំដាប់រហូតមកដល់បច្ចុប្បន្ននេះដែលមានសមាជិកចំនួន ២៨ រដ្ឋសមាជិក ។ សហភាពអ៊ឺរ៉ុបក៏បានបង្ហាញពីជំហររបស់ខ្លួន ក្នុងការថ្លែងការណ៍ទៅនឹងដែនជម្លោះនៃសមុទ្រចិនខាងត្បូងផងដែរ។ សហភាពអ៊ឺរ៉ុប (EU) បានធ្វើការលើកទឹកចិត្តដល់គ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ព្យាយាមរក ដំណោះស្រាយប្រកបដោយសន្តិវិធីតាម រយៈកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការស្របតាមច្បាប់អន្តរជាតិជាពិសេសជាមួយនឹងសន្ធិសញ្ញា ស្តីពីនីតិសមុទ្ររបស់អង្គការសហប្រជាជាតិ[20]។

អ្នកនាំពាក្យការបរទេសរបស់ EU បានចេញសេចក្តីថ្លែងការណ៍មួយថា ទោះបីជាខ្លួនមិនបានលើកអំពីការទាមទាររបស់ភាគីណាក៏ដោយ ប៉ុន្តែ EU គឺប្រតិបត្តិនឹងគោលការណ៍របស់នីតិអន្តរជាតិ ជាពិសេសគោលការណ៍ដែលបញ្ញត្តិនៅក្នុងនីតិសមុទ្រអន្តរជាតិតែម្តង[21]។ ជាចុងក្រោយ EU បានសង្កត់ធ្ងន់ថា ចិនគួរតែគោរពសេចក្តីសម្រេចតុលាការទីក្រុងឡាអេ[22]។

### ២.២ សេចក្តីថ្លែងការរបស់ G៧

G៧ មានប្រភពដើមមកពីក្រុមប្រាំមួយ ឬក៏ G៦។ វាត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៥ ដោយមានរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងក្រុមប្រឹក្សាភិបាលមកពីប្រទេសបារាំង អាល្លឺម៉ង់ ប្រទេសអ៊ីតាលី ប្រទេសជប៉ុន ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក នៅពេលដែលលោក Giscard d'Estaing បានអញ្ជើញពួកគេឲ្យចូលរួមកិច្ចប្រជុំក្រៅផ្លូវការ Rambouillet នៅជិតទីក្រុងប៉ារីស នៅក្នុងការសម្រាក

[20] *http://www.rappler.com/nation/69293-philippines-aquino-eu-barroso-unclos*
[21] *https://www.reuters.com/article/us-southchinasea-usa-eu-idUSKCN0S022G20151031*
[22] *https://www.theguardian.com/world/2016/apr/19/south-china-sea-britain-court-arbitration-ruling-binding*

ជាលក្ខណៈឯកជនមួយ[23]។ គោលបំណងគឺ "ដើម្បីពិភាក្សាអំពីបញ្ហាពិភពលោកនាពេលបច្ចុប្បន្ន (វិបត្តិប្រេងកាត) ជាលកក្ខណៈមិនផ្លូវការ" ។ G៦ បានបើកការប្រជុំក្រៅផ្លូវការចាប់តាំងពីឆ្នាំ ១៩៧៤ នៃមន្ត្រីហិរញ្ញវត្ថុជាន់ខ្ពស់មកពីសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ខាងលិច ជប៉ុន និង បារាំង។ ពួកគេត្រូវបានគេហៅថា "Library Group" ឬ "G៥" ពីព្រោះពួកគេបានជួបគ្នាជាផ្លូវការនៅក្នុងបណ្ណាល័យនៃសេតវិមាននៅរដ្ឋវ៉ាស៊ីនតោនឌីស៊ី (ក្រុមនេះអាចច្រឡំជាមួយក្រុមបច្ចុប្បន្នប៉ុន្តែខុសគ្នាទាំងស្រុង "G៥ "ដែលជាក្រុមនៃប្រទេសកំពូលទាំង ៥ ដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើនបានបង្កើតឡើងនៅឆ្នាំ ២០០៥)[24] ។ ប្រទេសកាណាដាបានក្លាយជាសមាជិកទី ៧ ដែលបានចាប់ផ្តើមចូលរួមកិច្ចប្រជុំកំពូលក្នុងឆ្នាំ ១៩៧៦ ហើយក្រោយមកត្រូវបានគេប្រើឈ្មោះថា "G៧" ឬ "G៧ Summit" [25]។ បន្ទាប់ពីកិច្ចប្រជុំកំពូល G៧ ឆ្នាំ ១៩៩៤ នៅទីក្រុង Naples មន្ត្រីរុស្ស៊ីបានធ្វើកិច្ចប្រជុំដាច់ដោយឡែកជាមួយមេដឹកនាំក្រុមប្រទេស G៧ បន្ទាប់ពីកិច្ចប្រជុំកំពូលរបស់ក្រុមបានបញ្ចប់។ ការរៀបចំក្រៅផ្លូវការនេះត្រូវបានគេដាក់ឈ្មោះថា Political ៨ (P៨) ឬសាមញ្ញ G៧ + ១ ។ ស្របតាមការអញ្ជើញរបស់នាយករដ្ឋមន្ត្រីអង់គ្លេសលោក Tony Blair និងប្រធានាធិបតីសហរដ្ឋអាមេរិក លោកBill Clinton ប្រធានាធិបតីរុស្ស៊ីលោក Boris Yeltsin ត្រូវបានគេអញ្ជើញជាអ្នកសង្កេតការណ៍ជាលើកនិងក្រោយមកបានក្លាយជាសមាជិកពេញសិទ្ធិ។ បន្ទាប់ពីកិច្ចប្រជុំឆ្នាំ ១៩៩៧ រុស្ស៊ីត្រូវបានអញ្ជើញជាផ្លូវការទៅកិច្ចប្រជុំបន្ទាប់ហើយបានចូលរួមជាផ្លូវការនៅក្នុងក្រុមនេះក្នុងឆ្នាំ ១៩៩៨ ដែលបង្កើតឲ្យមានវេទិកានយោបាយរដ្ឋាភិបាលថ្មីមួយក្រុមប្រាំបីឬ G៨ ។ ទោះបីជាយ៉ាងណាក៏ដោយរុស្ស៊ីត្រូវបានគេច្រានចេញពីវេទិកានយោបាយ G៨ ក្នុងឆ្នាំ ២០១៤ បន្ទាប់ពីវិបត្តិគ្រីមៀ។

អង្គការនេះត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលគំនិតផ្តួចផ្តើមការធ្វើម៉ាក្រូសេដ្ឋកិច្ចរួមគ្នាដោយសមាជិករបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការដួលរលំនៃអត្រាប្តូរប្រាក់ឆ្នាំ ១៩៧១ ក្នុងកំឡុងពេលនៃ Nixon Shock វិបត្តិថាមពលឆ្នាំ ១៩៧០ និងវិបត្តិសេដ្ឋកិច្ចជាបន្តបន្ទាប់។ នៅក្នុងនោះ G៧ បានធ្វើសេចក្តីថ្លែងការណ៍ទៅលើបញ្ហាសមុទ្រចិនខាងត្បូងដូចតទៅៈ

Group of ៧ បានធ្វើសេចក្តីថ្លែងការរួមថា ប្លុកនេះគួរតែបង្ហាញនៅសញ្ញាមួយច្បាស់លាស់មួយអំពីការទាមទាររបស់ចិនចំពោះការអះអាងត្រួតស៊ីគ្នា[26]។ លោកប្រធានក្រុមប្រឹក្សាអ៊ឺរ៉ុប Donald Tusk បានថ្លែងនៅក្រៅជំនួបប្រជុំផ្លូវការមួយនៅ Ise-Shima ថាប្លុកនេះគួរតែប្រកាន់យកជំហរមួយច្បាស់លាស់និងរឹងមាំមួយចំពោះការទាមទាររបស់ចិន។

---

[23] *"Evian summit – Questions about the G8"*. Ministère des Affaires étrangères, Paris.

[24] Nicholas Bayne, Robert D. Putnam (2000). Hanging in There, Ashgate Pub Ltd, 230 pages

[25] "Evian summit – Questions about the G៨". *Ministère des Affaires étrangères, Paris.*

[26] http://www.atimes.com/article/xinhua-warns-g7-against-south-china-sea-meddling//

## ២.៣. សេចក្តីថ្លែងការណ៍របស់អង្គការNATO

NATOត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញានៅ Washington DC. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៤៩ ដែលមានរដ្ឋសមាជិកទាំងអស់ចំនួន ២៩រដ្ឋសមាជិក។

ឧត្តមសេនីយឯកបាន Petr Pavel បានថ្លែងថា NATOគ្មានអំណាចណាមួយដែលនឹងចល័តកម្លាំងចូលទៅក្នុងដែនជម្លោះនៅក្នុងសមុទ្រចិនខាងត្បូងនោះទេ ហើយNATOនឹងមិនជ្រៀតជ្រែកនៅក្នុងដែនជម្លោះនៅក្រៅតំបន់នោះទេ ប៉ុន្តែយើងនឹងតាមដានមើលដោយយកចិត្តទុកដាក់ដោយយើងមិនច្បាស់អំពីចេតនារបស់ចិននោះទេ ទោះបីជាយ៉ាងណា NATOគាំទ្រអោយមានការសម្របសម្រួលនៅក្នុងតំបន់ និងតាមរយៈការទូត លោកបានបន្ថែមថា លោកគាំទ្រឲ្យមានការដោះស្រាយដោយសន្តិវិធី និងសំណូមពរអោយគ្រប់ភាគីទាំងអស់គោរពទៅនឹងបទដ្ឋាននៃច្បាប់អន្តរជាតិដូចដែលមានជាអាទិ៍ជាក់ស្តែង ទីក្រុងប៉េកាំងបានទាមទារស្ទើរតែអស់ទៅហើយនៃដែនសមុទ្រចិនដែលធ្វើអោយមានជម្លោះដល់ភាគីដែលពាក់ព័ន្ធរួមមានដូចជា ប្រុយណេ វៀតណាម ម៉ាឡេស៊ីស៊ី តៃវ៉ាន់ និង ហ្វីលីពីនតែម្តងប៉ុន្តែសម្ព័ន្ធភាពទាំង២៨ប្រទេសដែលមានប្រទេសភាគច្រើននៅតំបន់អឺរ៉ុប និងអាមេរិកខាងជើងនៅតែមានឆន្ទៈក្នុងការគាំទ្រដល់ប្រទេសដែលនៅក្នុងតំបន់ និងមានបំណងចង់បង្កើនសមត្ថភាពការពារជាតិរបស់ខ្លួន និងការស៊ើបអង្កេត ក្នុងគោលបំណងដើម្បីការពារសន្តិសុខដែនទឹកផងដែរ ជាពិសេស គឺលោកចាប់អារម្មណ៍ និងសម្លឹងមើលកាឡានុវត្តភាពណាមួយលើការសហការគ្នារវាង អាស៊ាន និង NATO[27]។

## ២.៤. សេចក្តីថ្លែងការណ៍របស់អង្គការសហប្រតិបត្តិការស៊ាងហៃ

នៅក្នុងសេចក្តីថ្លែងការមួយរបស់អគ្គលេខាធិការ អង្គការសហប្រតិបត្តិការស៊ាងហៃលោក Rashid Olimov បានថ្លែងថារាល់សមាជិក SCO ទាំងអស់បានព្រមព្រៀងនិងយល់ព្រមគាំទ្រដល់ភាគីចិនដែលខិតខំប្រឹងប្រែងការពារសន្តិភាព និងស្ថេរភាពនៅសមុទ្រចិនខាងត្បូង ។ លោកបានបន្តទៀតថាគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់គួរតែធ្វើការដោះស្រាយបញ្ចប់ជម្លោះតាមរយៈសន្ធិសញ្ញាទ្វេរភាគី ឬក៏អនុលោមតាម DOC។ វាជម្រុញឲ្យមានការគោរពសិទ្ធិ និងអធិបតេយ្យរវាងគ្នា និងគ្នានិងសម្រេចរកវិធីដោះស្រាយដោយខ្លួនឯងជាជាងការជ្រែកចូលនៃភាគីមិនមែនជម្លោះចូលមកដោះស្រាយដែលមានបំណងចាត់ទុកបញ្ហានេះជាជម្លោះអន្តរជាតិ[28]។

[27] http://www.straitstimes.com/asia/east-asia/nato-has-no-legal-platforms-to-intervene-militarily-in-south-china-sea
[28] http://www.china.org.cn/world/2016-05/25/content_38530226.htm

**ផ្នែកទី២៖ សេចក្តីសម្រេចរបស់** PCA

ជាការពិតបើយោងតាម នីតិសមុទ្រអន្តរជាតិឆ្នាំ១៩៨២ តុលាការបានសម្រេចឲ្យហ្វីលីពីនជាអ្នកមានសិទ្ធិក្នុងការកាន់កាប់ដែនកោះជម្លោះជាឯកច្ឆ័ន្ទ ដោយយោងតាមហេតុផលថាបើផ្អែកតាមតថភាពជាក់ស្តែង និងពីប្រវត្តិសាស្ត្រហ្វីលីពីនគឺមានប្រវត្តិសាស្ត្រដែលពាក់ព័ន្ធនិងដែនជម្លោះពិតប្រាកដមែន បើតាមតឹកតាងដែលបានបន្សល់ទុកនិងត្រូវបានគេរកឃើញ។ ចំណែកឯភាគីចិនវិញយើងឃើញថាមិនមានតឹកតាងណាមួយអាចបញ្ជាក់បានតាមលក្ខណៈផ្លូវច្បាប់ ដែលបញ្ជាក់ថាកាលពីប្រវត្តិសាស្ត្រចិនបានត្រួតត្រានិងគ្រប់គ្រងនៅតំបន់នោះនៅឡើយទេទើបតុលាការសម្រេចឲ្យភាគីហ្វីលីពីនជាអ្នកកាន់កាប់ ប៉ុន្តែសេចក្តីសម្រេចមួយនោះមិនអាចអនុវត្តបានឡើយដោយហេតុថាភាគីចិនមិនព្រមទទួលយកសេចក្តីសម្រេចនោះជាដាច់ខាត។ យ៉ាងណាមិញការអនុវត្តន៍របស់តុលាការយុត្តិធម៌អន្តរជាតិ ក៏មិនអាចធ្វើទៅបានដោយសារចិនជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដូច្នេះភាគីចិនមានសិទ្ធិក្នុងការ Veto នៃសេចក្តីសម្រេចណាមួយនៃក្រុមប្រឹក្សាសន្តិសុខក្នុងការដាក់ទណ្ឌកម្មទៅលើភាគីណាមួយដែលមិនព្រមអនុវត្តនៅសេចក្តីសម្រេចណាមួយរបស់តុលាការយុត្តិធម៌អន្តរជាតិ។

រូបភាពទី១៖ ផែនទីនៃការទាមទាររបស់ភាគីនៅដែនជម្លោះសមុទ្រចិនខាងត្បូង



## ១. ការទាមទាររបស់ហ្វីលីពីន




នេះគឺជាតឹកតាងដែល ជាសំអាងរបស់ហ្វីលីពីននៅក្នុងការទាមទារនិងតវ៉ាយកដែនដីរបស់ខ្លួនស្របទៅតាមប្រវត្តិសាស្ត្រ និងឯកសារដែលបានបន្សល់ទុកមកដែលផែនទីនេះជាតឹកតាងដែលបន្សល់ទុកមកតាំងពីស.វទី ១៨ ពោលគឺនៅក្នុងឆ្នាំ ១៧៧៤។ ប្រទេសហ្វីលីពីនបានអះអាងថាការអះអាងនិងទាមទារពីលើអធិបតេយ្យរបស់ខ្លួន ទៅលើតំបន់ថ្មប៉ប្រះទឹកគឺមានមូលដ្ឋានគ្រឹះក្នុងការទាមទារមួយដែលត្រឹមត្រូវ។

ស្របទៅតាមយុត្តាធិការ និងលក្ខណៈវិនិច្ឆ័យខាងផ្លូវច្បាប់ដែលបានបង្កើតឡើងដោយច្បាប់អន្តរជាតិសាធារណៈស្តីពីវិធីសាស្ត្រស្របច្បាប់ដើម្បីទទួលបានអធិបតេយ្យ។ ក្នុងចំណោមគោលការណ៍នៃលក្ខខណ្ឌវិនិច្ឆ័យទាំងឡាយ ក្រសួងការបរទេសរបស់ប្រទេសហ្វីលីពីន (DFA) បានអះអាងថាខ្លួនមានគ្រប់គោលការណ៍ដែលស្របទៅនឹងច្បាប់នោះ ដែលជារួមមានទាំង ភស្តុតាងជាក់ស្តែង និងគោលការណ៍ច្បាប់ផងដែរដែលប្រទេសនេះបានអនុវត្តវាតាំងពីថ្ងៃទទួលបានឯករាជ្យមកម្ល៉េះ។ ដូច្នេះហ្វីលីពីនបានអះអាងបន្ថែមថាខ្លួនថែមទាំងបានដាក់ភ្លើងហ្វា និងទង់ជាតិរបស់ខ្លួនហើយក៏បានរាយការណ៍រួចជាស្រេចទៅកាន់អង្គការទទួលបន្ទុកដែនសមុទ្រអន្តរជាតិ។ មិនត្រឹមតែ

ប៉ុណ្ណោះ កងនាវាជើងទឹកអាមេរិក និងហ្វីលីពីន ក៏បានប្រើប្រាស់តំបន់នេះជាតំបន់សមយុទ្ធយោធាផងដែរ លើសពីនេះទៅទៀតមន្ទីរបរិស្ថាន និងធនធានធម្មជាតិហ្វីលីពីនក៏បានលើកឡើងបន្ថែមថា ខ្លួនថែមទាំងបានធ្វើការស្រាវជ្រាវទាំងលើដែនទឹក និងក្រោមសមុទ្រផងដែរនៅអំឡុងពេលដែលប្រជានេសាទហ្វីលីពីនតែងតែនេសាទជាប្រចាំនៅបរិវេណនោះ ហើយ និងយល់ថាទីតាំងនេះជាដែនទឹករបស់ខ្លួនតាំងពីយូរណាស់មកហើយ[29]។ DFA ក៏បានបន្ថែមទៀតថាការទាមទារទៅលើតំបន់ថ្មប៉ប្រះទឹកដែលគេហៅថា Bajo de Masinloc ក៏ជានយោបាយមួយដ៏សំខាន់ផងដែររបស់ប្រទេសហ្វីលីពីន នាខេត្ត ហ្សាំបាឡាស ដែលត្រូវបានគេស្គាល់ថា Masinloc ជាមូលដ្ឋានក្នុងការទាមទារហ្វីលីពីនក៏បានដាក់ករណីកោះ Palmas ធ្វើជាសំអាងហេតុផលផងដែរនៅក្នុងការទាមទារដែលអធិបតេយ្យនៃកោះមួយនេះត្រូវបានសម្រេចដោយតុលាការអន្តរជាតិដែលបានអោយប្រទេសហូឡង់ឈ្នះក្តី ទៅលើប្រទេសអេស្ប៉ាញទោះបីជាការអះអាងថាកោះនោះកាន់កាប់ជាប្រវត្តិសាស្រ្តដែលគ្រប់គ្រងដោយប្រទេសអេស្ប៉ាញក៏ដោយ។ ដូច្នេះហ្វីលីពីនបានអះអាងថាទោះបីជាការទាមទារជាប្រវត្តិសាស្រ្តរបស់ចិនក៏ដោយក៏កោះScarborough នៅត្រូវតែត្រូវមានការបញ្ជាក់ពីប្រវត្តិសាស្រ្ត ពីព្រោះថាការទាមទារដោយខ្លួនឯងទោះបីជាតាមប្រវត្តិសាស្រ្តក៏ដោយក៏មិនមែនជាការទទួលស្គាល់ដោយច្បាប់អន្តរជាតិនោះទេ។ ហើយក៏បានអះអាងបន្តទៀតថាក៏មិនមានការចង្អុលបង្ហាញដែលថាសហគមន៍អន្តរជាតិបានគាំទ្រ និងយល់ស្របការលើកឡើងរបស់ចិនអំពីការបង្ហាញជាប្រវត្តិសាស្រ្ត រួមនិងសកម្មភាពនេសាទជាឯកជនរបស់ជនជាតិចិន ដែលបានទាមទារនិងការចាត់បញ្ចូលជាភស្តុតាងក្នុងការទាមទារដោយសកម្មភាពទាំងនេះមិនអាចចាត់ទុក ជាសកម្មភាពនៃការគ្រប់គ្រងអធិបតេយ្យណាមួយរបស់ចិនបានឡើយ[30]។ រដ្ឋាភិបាលហ្វីលីពីនបានអះអាងថាដោយសារតែយើងមានមូលដ្ឋានស្របច្បាប់ក្នុងការទាមទារដោយផ្អែកទៅលើច្បាប់អន្តរជាតិស្តីពីអធិបតេយ្យរបស់រដ្ឋ ដែលរួមបញ្ចូលទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៅជុំវិញដែនទឹកនៃកោះ Scarborough គឺវាខុសគ្នាពីអធិបតេយ្យហ្វីលីពីនដែលទាមទារនៅតំបន់ថ្មប៉ប្រះទឹក[31,32]។ រដ្ឋាភិបាលហ្វីលីពីនបានស្នើសុំអោយមានការដោះស្រាយជម្លោះនេះទៅកាន់តុលាការអន្តរជាតិដែលយកនីតិសមុទ្រ មកធ្វើជាមូលដ្ឋាននៅក្នុងការដោះស្រាយដូចដែលមានចែងនៅក្នុងផ្នែក ១៥ នៃសន្ធិសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិដែលស្តីពីនីតិសមុទ្រ ប៉ុន្តែខាងភាគីចិនបានធ្វើការច្រានចោលសំណើរនេះជាច្រើនដង ដោយលើកឡើងអោយមានការពិភាក្សាជាលក្ខណៈទ្វេរភាគីវិញ[33] [34] [35]។

---

[29] Philippine Position on Bajo de Masinloc and the Waters Within its Vicinity (18 April 2012), The Department of Foreign Affairs of the Republic of the Philippines.

[30] Philippine Position on Bajo de Masinloc and the Waters Within its Vicinity. April 18, 2012.

[31] PH sovereignty based on Unclos, principles of international law (20 April 2012), The Department of Foreign Affairs of the Republic of the Philippines (as reported by globalnation.inquirer.net).

[32] Philippine Position on Bajo de Masinloc and the Waters Within its Vicinity (18 April 2012), The Department of Foreign Affairs of the Republic of the Philippines

[33] China deploys gunboat. Philippine Daily Inquirer. April 20, 2012

ហ្វីលីពីនបានបន្តថាចាប់តាំងពីដើមអាណានិគមនៃប្រទេសអេស្ប៉ាញ ប្រជានេសាទហ្វីលីពីនក៏បានធ្វើការប្រកបរបរនេះនៅតំបន់នេះរួចជាស្រេចមកហើយ ដែលប្រើប្រាស់តំបន់នេសាទនេះជាតំបន់នេសាទជាលក្ខណៈប្រពៃណី រួមទាំងជាទីជម្រកផងដែរបើទោះបីជាអាកាសធាតុមិនល្អក៏ដោយ[36]។

## ២. ការទាមទាររបស់ចិន

រូបភាព៖ ផែនទីនៃការទាមទាររបស់ចិន




34 Fr. Joaquin G. Bernas S. J. (April 22, 2012). "Scarborough Shoal". Philippine Daily Inquirer

35 PART XV : SETTLEMENT OF DISPUTES, UNITED NATIONS CONVENTION ON THE LAW OF THE SEA : AGREEMENT RELATING TO THE IMPLEMENTATION OF PART XI OF THE CONVENTION, The United Nations.

36 Zou2005, pp. 64-65

រូបភាព៖ ផែនទីនៃការទាមទាររបស់ចិនឆ្នាំ ២០០៩



## ៣. ការសម្របសម្រួល និងអនុសាសន៍របស់ PCA នៅលើបញ្ហាសមុទ្រចិនខាងត្បូង

ពាក្យថា PCA មកពីពាក្យពេញថា Permanent Court of Arbitration គឺជាស្ថាប័នមួយដែលមានទីតាំងនៅក្នុងទីក្រុងឡាអេ ប្រទេសហូឡង់ ដែលមានអគារឈ្មោះថា PEACE PALCAE ដែលកសាងឡើងចាប់ពីឆ្នាំ ១៩០៧ ដល់ឆ្នាំ ១៩១៣ សម្រាប់ធ្វើជាទីស្នាក់ការ។ ស្ថាប័ននេះមិនមែនជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិនោះទេ ប៉ុន្តែវាជាស្ថាប័នមួយដែលជាអ្នកសង្កេតការផ្លូវការរបស់អង្គការសហប្រជាជាតិ ហើយស្ថាប័ននេះបង្កើតឡើងដោយសន្ធិសញ្ញាបីរួមបញ្ចូលគ្នាតែមួយ ហើយគិតមកដល់សព្វថ្ងៃនេះ PCA មានសមាជិកទាំងអស់ចំនួន ១២១រដ្ឋសមាជិកហើយស្ថាប័នខាងលើមានតួនាទីជាអាជ្ញាកណ្តាលដើម្បីធ្វើការសម្របសម្រួលរវាងភាគីវិវាទដោយព្យាយាមរកដំណោះស្រាយល្អ និងផ្សះផ្សារដដើម្បីស្វែងរកនៅចំណុចរួមមួយដើម្បីដោះស្រាយឲ្យភាគីទាំងពីរប្រកបដោយប្រសិទ្ធិភាពខ្ពស់។ PCA ក៏បានទទួល និងសម្រេចរឿងក្តីជាច្រើនមកហើយដូចដែលមាននៅក្នុងតារាងខាងក្រោមនេះ

តារាងពីការទទួលរឿងក្តីរបស់ PCA

| កាលបរិច្ឆេទ | ភាគីវិវាទ និងរឿងក្តី |
|---|---|
| ១៩០២ | សហរដ្ឋអាមេរិក និងម៉ិចស៊ិចកូ (PIOUS Fund of the Californias) |
| ១៩១១ | បារាំង ជាមួយនិងចក្រភពអង់គ្លេស (SAVAKAR Case) |
| ១៩២៨ | សហរដ្ឋអាមេរិក និងហូល្លង់ (ISLAND of PALMAS Case) |
| ១៩៩៩ | អ៊ីរីទ្រា និងយេមែន (HANISH ISLAND CONFLICT) |
| ២០០៥ | ប៊ែលហ្ស៊ិក និងហូល្លង់ (IRON RHINE CASE) |
| ២០១៧ | ក្រូអាត និងស្លូវ៉ានៀ |
| ២០០៦ | ប៉ាប៉ាដូស និងតូបាហ្គ |
| ២០១៤ | បង់ក្លាដេស និងឥណ្ឌា (BAY of BENGAL MARITIME BOUNDARY) |
| ២០១៥ | ម៉ូរីតូស និងចក្រភពអង់គ្លេស (CHAGO MARINE PROTECTED AREA) |
| ២០១៦ | ហ្វីលីពីន និងចិន (SOUTH CHINA SEA) |

| ជម្លោះរវាងក្រុមហ៊ុនវិនិយោគ និងរដ្ឋ | |
|---|---|
| ២០១៥ | HULLEY Enterprise limited (CYPRUS), Yukos Universal Limited Veteren Petroleum Limited (CYPRUS) និង សហព័ន្ធរុស្ស៊ី |

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ PCA បានចេញសេចក្ដីសម្រេចចុងក្រោយដោយPCAបានសម្រេចដែលស្របទៅនឹងសន្ធិសញ្ញាអន្តរជាតិ ដែលសេចក្ដីសម្រេចនោះមានដូចតទៅនេះ[37] [38]៖

➢ សេចក្ដីសម្រេចត្រូវរាប់បញ្ចូលទាំងខ្សែរបន្ទាត់ទី៩ រួមទាំងការទាមទាររបស់ចិននៅដែនសមុទ្រចិនភាគខាងត្បូង[39]។

- សន្ធិសញ្ញាស្ដីពីសមុទ្ររបស់អង្គការសហប្រជាជាតិបានកំណត់អំពីសិទ្ធិទទួលបានវិសាលភាពនៅលើដែនសមុទ្រចិនខាងត្បូង ដែលភាគីមិនអាចវាតទីលើសពីអ្វីដែលវាបានកំណត់នៅក្នុងសន្ធិសញ្ញានោះបានឡើយ[40]។
- ការអះអាងរបស់ភាគីចិនដោយសំអាងលើប្រវត្តិសាស្រ្ត ឬសិទ្ធិលើការគ្រប់គ្រងអធិបតេយ្យផ្សេងទៀត ឬក៏យុត្តាធិការដែលទាក់ទិននឹងដែនសមុទ្រចិនខាងត្បូងដែលគ្រប់ដណ្ដប់ដោយខ្សែរបន្ទាត់ទី៩ គឺផ្ទុយទៅនឹងអ្វីដែលចែងនៅក្នុងសន្ធិសញ្ញា ហើយគ្មានតម្លៃផ្លូវច្បាប់ដែលអាចនឹងធ្វើការទាមទារ នឹងគ្មានឥទ្ធិពលនៅក្នុងទាមទារលើសពីដែនកំណត់នៃភូមិសាស្រ្ត និងសិទ្ធិដែលទទួលបានការគ្រប់គ្រងលើអធិបតេយ្យនៅលើដែនសមុទ្រ ដែលបានចែងនៅក្នុងសន្ធិសញ្ញាស្ដីពីនីតិសមុទ្រនោះទេ។ សន្ធិសញ្ញាបានធ្វើការបដិសេធយ៉ាងដាច់ខាតចំពោះសិទ្ធិជាប្រវត្តិសាស្រ្ត ឬក៏សិទ្ធិនៃការគ្រប់គ្រងដែនអធិបតេយ្យណាមួយដែលមិនបានស្របទៅនឹងអ្វីដែលបានកំណត់នៅក្នុងនេះ[41]។

➢ សេចក្ដីសម្រេចទាក់ទិននឹងស្ថានភាពដែនទឹកខាងលើ និងខាងក្រោមនៃតំបន់ជម្លោះ

- ផ្នែកខាងលើផ្ទៃទឹកមាន៖ (a) Scarborough Shoal, (b) Cuarteron Reef, (c) Fiery Cross Reef, (d) Johnson Reef, (e) McKennan Reef, and (f) Gaven Reef (North).[42]។

[37] Harvey, Adam (13 July 2016). "Philippines celebrates victory in South China Sea case, despite China's refusal to accept result". ABC News. Retrieved 13 July 2016.

[38] "Press release: The South China Sea Arbitration" (PDF). Permanent Court of Arbitration. 12 July 2016. The Award is final and binding, as set out in Article 296 of the Convention and Article 11 of Annex VII.

[39] Permanent Court of Arbitration. 12 July 2016

[40] PCA Award, Section V(F)(d)(២៧៧), p.116

[41] PCA Award, Section V(F)(d)(២៧៨), p.117

[42] PCA Award, Section VI(B)(៥)(d)(៣៨២), p.174.

- ផ្នែកខាងក្រោមបាតសមុទ្រមាន៖ Low-tide elevations: (a) Hughes Reef, (b) Gaven Reef (South), (c) Subi Reef, (d) Mischief Reef, (e) Second Thomas Shoal[43]។
- Hughes Reef ស្ថិតនៅចម្ងាយ ១២ម៉ែល៍ ពីតំបន់ផ្នែកខាងលើនៃផ្ទៃទឹក នៃ Mc Kanen Reef និងកោះ Sin Cowe ហើយនិង Gaven Reef (South) ស្ថិតនៅចម្ងាយ ១២ម៉ែល៍ ពី Gaven Reef (north) និង កោះNamyit នៅក្នុងនោះផងដែរ Subi Reef មានចម្ងាយ១២ម៉ែល៍ពី Sandy Cay ទៅកាន់ West of Thitu [44]។

➢ សេចក្តីសម្រេចទាក់ទងនឹងលក្ខណៈពិសេសនៃកោះ និង ថ្ម (សេចក្តីជូនដំណឹងលេខ ៣ ៥ និង ៧)

- Scaborough Shoal ដែលមានន័យសេចក្តីនៅក្នុងសន្ធិសញ្ញាស្តីពីដែនសមុទ្រអន្តរជាតិ ឆ្នាំ១៩៨២ ត្រង់មាត្រា ១២១(១) ដែលបានចែងថា រាល់ដីដុះទាំងឡាយណាដែលដុះឡើងហើយព័ទ្ធជុំវិញទៅដោយទឹក ដែលមានកម្ពស់ខ្ពស់ជាងនីវ៉ូទឹកសមុទ្រ ។ ទោះបីជាយ៉ាងណាក៏ដោយដោយយោងតាមមាត្រា ១២១(៣) នៃសន្ធិសញ្ញានេះដដែលបានបានចែងថា តំបន់ខាងលើនៃ Scarborough ដែលមិនអាចអោយមនុស្សរស់នៅបាន ឬក៏មិនបានបម្រើប្រយោជន៍ផ្នែកសេដ្ឋកិច្ចណាមួយមិនអាចចាត់ទុកជាតំបន់សេដ្ឋកិច្ចផ្តាច់មុខឬContinental Shelf បានឡើយ[45]។
- តំបន់ផ្នែកខាងលើនៃ Gaven Reef (north) និង McKaneen Reef មិនអាចអោយជីវិតមនុស្សរស់នៅបានឡើយ ដូច្នេះហើយក៏មិនអាចចាត់ទុកជាតំបន់សេដ្ឋកិច្ចផ្តាច់មុខឬដែនដីទ្វីបបាននោះដែរ[46] ។
- Mischief reef និង Second Thomas Shoal គឺមានកម្ពស់ទាបជាងនីវ៉ូទឹកសមុទ្រដែលអាចចាត់ទុកថាជាផ្ទៃទឹក ហើយនិងគ្មានតំបន់ណាមួយដែលមានផ្ទៃដីខ្ពស់ជាងនីវ៉ូទឹកសមុទ្រដែលអាចឲ្យជីវិតមនុស្សរស់នៅបាន និងផ្តល់ប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់ប្រជានេសាទណាមួយនោះទេ ដែលអនុលោមទៅតាមមាត្រា ១២១(៣) នៃសន្ធិសញ្ញា ដោយកត្តានេះហើយធ្វើឲ្យភាគីចិនមិនមានសិទ្ធិណាមួយដែលអាចចូលកាន់កាប់តំបន់ណាមួយ ឬក៏ទទួលបានសិទ្ធិណាមួយនៃការគ្រប់គ្រងដែនអធិបតេយ្យនៃ

[43] PCA Award, Section VI(B)(៥)(d)(៣៨៣), p.174
[44] PCA Award, Section VI(B)(5)(d)(384), p.174
[45] PCA Award, Section VI(C)(5)(f)(643), p.259
[46] PCA Award, Section VI(C)(5)(f)(645), p.259

ដែនកោះ Spratlys ហើយក៏មិនមែនហេតុផលណាមួយដែលយើងត្រូវពិចារណាលើសំណើរទី ៥ របស់ហ្វីលីពីនទៀតឡើយ[47]។

- Both Mischief Reef និង Second Thomas Shaol មានទីតាំងស្ថិតនៅចម្ងាយ ២០០ ម៉ែល៍ ពីឆ្នេរសមុទ្រហ្វីលីពីន ដែលស្ថិតនៅលើកោះ ប៉ាឡាវ៉ាន់ (Palawan) ដែលជាតំបន់ដែលមិនត្រូវបានត្រួតត្រា និងទាមទារសិទ្ធិអធិបតេយ្យដោយភាគីចិន។ ហេតុដូចនេះហើយ Both Mischief Reef និង Second Thomas Shoal គឺជាផ្នែកមួយនៃតំបន់សេដ្ឋកិច្ច និងដែនដីទ្វីបរបស់ប្រទេសហ្វីលីពីន[48] ។

➢ សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកសិទ្ធិអធិបតេយ្យរបស់ហ្វីលីពីន នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិង ខ្ពង់រាបបាតសមុទ្រ (សំណើរលេខ ៨)

- ការចល័តកងនាវាស៊ើបការរបស់ចិន កាលពីថ្ងៃទី ០១ ដល់ ថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១១ បានបំពានទៅនឹងនីតិសមុទ្រត្រង់មាត្រា ៧៧ ដែលទង្វើនេះជាទង្វើដែលគ្មានការគោរពទៅដល់ភាគីហ្វីលីពីន ដែលមានសិទ្ធិលើអធិបតេយ្យនៃការគ្រប់គ្រងតំបន់ដែលគ្មានធនធានមានជីវិត នៃខ្ពង់រាបបាតសមុទ្រនៃតំបន់ Reed Bank ដែលប្រទេសចិន បានប្រកាសកាលពីឆ្នាំ២០១២ ស្តីពីការហាមប្រាមការនេសាទនៅក្នុងដែនសមុទ្រចិនខាងត្បូង ដោយគ្មានករណីលើកលែងរួមទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខផងដែរនោះ ជាមួយនឹងការជ្រៀតជ្រែកចូលនៃនាវាស៊ើបការណ៍ របស់ប្រទេសចិន ដោយគ្មានដែនកំណត់ដែលអំពើនេះបានបំពានលើមាត្រា ៥៦ នៃសន្ធិសញ្ញាស្តីពីនីតិសមុទ្រអន្តរជាតិដោយគោរពទៅលើដែនអធិបតេយ្យរបស់ហ្វីលីពីន ដែលគ្របដណ្តប់ទៅលើតំបន់ដែលមានធនធានមានជីវិត និងរួមបញ្ចូលទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខផងដែរ[49]។

➢ សេចក្តីសម្រេចដែលស្តីពីការចោទប្រកាន់ការការពារជនជាតិចិន ពីការកេងប្រវ័ញ្ចធនធានរបស់ហ្វីលីពីន (សំណើរលេខ ៩)

- ភាគីចិនបានបានធ្វើដំណើរតាមនាវាស៊ើបការណ៍ ដើម្បីការពារនេសាទរបស់ចិននៅតំបន់ Mischief Reef និង Second Thomas Shoal កាលពីខែឧសភា ឆ្នាំ២០១៣ ដោយមិនបានបង្ហាញការគោរពចំពោះអធិបតេយ្យរបស់ហ្វីលីពីនដែលទង្វើនេះគឺបានបំពាននីតិសមុទ្រឆ្នាំ១៩៨២ ត្រង់មាត្រា ៥៨(៣)[50]។

---

[47] PCA Award, Section VI(C)(5)(f)(646), p.259-260
[48] PCA Award, Section VI(C)(5)(f)(647), p.260
[49] PCA Award, Section VII(A)(5)(c)(716), p.286.
[50] PCA Award, Section VII(B)(5)(d)(757), p.297

- សេចក្តីសម្រេចទាក់ទិននឹងសកម្មភាពនេសាទរបស់ចិននៅក្នុងដែនកោះ Scarborough Shoal (សំណើរលេខ ១០)
  - ប្រទេសចិនបានធ្វើប្រតិបត្តិការដោយនាវារបស់ខ្លួនចាប់តាំងពីឆ្នាំ ២០១២ ដែលធ្វើការការពារការចូលនេសាទជាលក្ខណៈប្រពៃណីរបស់ប្រជានេសាទហ្វីលីពីននៅតំបន់ Scarborough Shoal[51]។
- សេចក្តីសម្រេចទាក់ទិននឹងការបរាជ័យក្នុងការការពារ និងអភិរក្សបរិស្ថានសមុទ្រ (សំណើរលេខ ១១ និង ១២"ខ")
  - ប្រទេសចិនបានប្រតិបត្តិការដោយហួសពីការអធ្យាស្រ័យ និងការការពាររបស់ខ្លួន ហើយក៏បរាជ័យក្នុងការទប់ស្កាត់ ការនេសាទធនធានកម្ររបស់នាវានេសាទចិន នៅតំបន់ Scarborough Shoal Second Thomas Shoal និងតំបន់ដទៃទៀតនៅកោះ Spratlys បានបំពានទៅលើមាត្រា ១៩២ និង ១៩៤(៥) នៃសន្ធិសញ្ញានេះ[52]។
  - ប្រទេសចិនបានប្រតិបត្តិការសាងសង់សំណង់នៅលើតំបន់ Cuateron Reef Fiery Cross Reef Gaven Reef (north) Johnson Reef Hughes Reef Subi Reef និង Mischief Reef ដែលបានបំពានទៅលើមាត្រា ១៩២ ១៩៤(១) ១៩៤(៥) ១៩៧ ១២៣ និង២០៦ នៃសន្ធិសញ្ញាមួយនេះ[53]។
- សេចក្តីសម្រេចទាក់ទិននិងការកាន់កាប់ និងសកម្មភាពសំណង់នៅលើថ្មប៉ប្រះទឹក (សំណើរ ទី ១២)
  - ប្រទេសចិនបានប្រតិបត្តិការសាងសង់ កោះសិប្បនិម្មិត នៅតំបន់ Mischief Reef ដោយគ្មានការអនុញ្ញាតណាមួយរបស់ប្រទេសហ្វីលីពីនឡើយ ដែលបានបំពានទៅលើមាត្រា ៦០ និង ៨០នៃសន្ធិសញ្ញានេះ ដោយគោរពទៅលើសិទ្ធិអធិបតេយ្យរបស់ហ្វីលីពីន ដែលរួមបញ្ចូលទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងខ្ពង់រាបបាតសមុទ្រដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើការផ្លាស់ប្តូរនៅឡើយ[54]។
- សេចក្តីសម្រេចទាក់ទងទៅនឹងការចល័តនាវាដែលអាចបង្កអោយមានគ្រោះថ្នាក់ (សំណើរលេខ ១៣)
  - ប្រទេសចិនបានធ្វើអោយមានសកម្មភាពប្រកបទៅ ដោយគ្រោះថ្នាក់នៃការអនុវត្តច្បាប់របស់ចិននៅតំបន់ឈូងសមុទ្រ Scarborough Shoal ដែលអាចបង្កគ្រោះថ្នាក់

[51] PCA Award, Section VII(C)(5)(c)(814), p.318
[52] PCA Award, Section VII(D)(5)(e)(992), p.397
[53] PCA Award, Section VII(D)(5)(e)(993), p.397
[54] PCA Award, Section VII(E)(5)(c)(1043), p.415

និងការប៉ះទង្គិចគ្នា យ៉ាងធ្ងន់ធ្ងរជាមួយនិងនាវាហ្វីលីពីន និងនាវិកដែលបម្រើការនៅលើនាវានោះ។ តុលាការបានរកឃើញថាចិនបានរំលោភទៅលើច្បាប់ត្រង់មាត្រា ២ ៦ ៨ ១៥ និង ១៦ នៃ COLREGS និងមាត្រា ៩៤នៃសន្ធិសញ្ញាមួយនេះ[55]។

➢ សេចក្ដីសម្រេចទាក់ទិននិងការកើនកម្ដៅ ឬការអូសបន្លាយជម្លោះរវាងភាគី (សំណើរលេខ ១៤)
  - ប្រទេសចិននៅក្នុងដំណើរការនៃការផ្សះផ្សារនេះបានធ្វើអោយភាគីជម្លោះទាំងអស់កាន់តែមានភាពតានតឹងឡើងដោយសកម្មភាពមួយចំនួនដូចជា ការបូមខ្សាច់ សាងសង់កោះសិប្បនិម្មិត និងសកម្មភាពសំណង់នានា ដូចដែលមានចែងនៅក្នុងសេចក្ដីសម្រេច[56]។

➢ សេចក្ដីសម្រេចទាក់ទិននិងសកម្មភាពនាពេលអនាគតរបស់ភាគី (សំណើរលេខ ១៥)
  - ភាគីទីបីមានកាតព្វកិច្ចគោរព និងអនុលោមទៅតាមសន្ធិសញ្ញានេះ ដែលរាប់បញ្ចូលទាំងនិងការដោះស្រាយវិវាទ និងគោរពសិទ្ធិ សេរីភាព រដ្ឋដទៃទៀតដែលជាហត្ថលេខីនៃសន្ធិសញ្ញាមួយនេះ[57]។

*បញ្ជាក់សូមមើលសេចក្ដីសម្រេចពេញសេចក្ដីនៅក្នុងឧបសម្ព័ន្ធទី

តារាងនៃការចេញសេចក្ដីសម្រេចផ្សេងៗរវាងគូភាគី និងតុលាការ

| ថ្ងៃ ខែ ឆ្នាំ | ខ្លឹមសារ និង កម្មវត្ថុ |
|---|---|
| ២២ មករា ២០១៣ | ហ្វីលីពីនបានជូនដំណឹងដល់ភាគីចិនអំពីការទាមទាររបស់ខ្លួន[58] |
| ១៩ កុម្ភះ ២០១៣ | ចិនបដិសេធការជូនដំណឹងរបស់ហ្វីលីពីន |
| ១១ កក្កដា ២០១៣ | ការជួបប្រជុំជាលើកដំបូងនៅតុលាការទីក្រុង ឡាអេ |
| ៣១ កក្កដា ២០១៣ | ហ្វីលីពីនបានផ្ដល់យោបល់ទៅលើនីតិវិធីរបស់តុលាការ |
| ១ សីហា ២០១៣ | ប្រទេសចិន មិនយល់ព្រមចូលក្នុងតុលាការដែលបានផ្ដួចផ្ដើមឡើងដោយហ្វីលីពីន |
| ២៧ សីហា ២០១៣ | នីតិវិធីលេខ០១ បានប្រកាសដោយ PCA ដែលតំណាងអោយសាលាក្ដីអាជ្ញាកណ្ដាល[59] |

[55] PCA Award, Section VII(F)(5)(d)(1106), p.435
[56] PCA Award, Section VIII(E)(4)(1181), p.464
[57] PCA Award, Section IX(D)(1201), p.469
[58] Rothwell, Donald R. (30 January 2015). "The Arbitration between the People's Republic of China and the Philippines Over the Dispute in the South China Sea". ANU College of Law Research Paper (14-48). SSRN ១255787
[59] "Arbitration between the Republic of the Philippines and the People's Republic of China: Arbitral Tribunal Establishes Rules of Procedure and Initial Timetable" (PDF). Permanent Court of Arbitration. 27 August 2013

| | |
|---|---|
| ៣០ មីនា ២០១៤ | ការដាក់ពាក្យស្នើរសុំរបស់ហ្វីលីពីន |
| ១៤ ១៥ ឧសភា ២០១៤ | ការប្រជុំលើកទី ២ នៅសាលាក្តីអាជ្ញាកណ្តាល |
| ២១ ឧសភា ២០១៤ | ប្រទេសចិនបានធ្វើសេចក្តីថ្លែងការណ៍ទៅលើនីតិវិធីទី២ ដែលមិនយល់ស្របនៅក្នុងការចូលរួមទៅកាន់PCAដែលផ្តួចផ្តើមឡើងដោយហ្វីលីពីន |
| ២៩ ឧសភា ២០១៤ | ហ្វីលីពីនបានធ្វើសេចក្តីថ្លែងការណ៍ទៅលើនីតិវិធីទី២ |
| ៣ មិថុនា ២០១៤ | នីតិវិធីលេខ០២ បានប្រកាសដោយ PCA ដែលតំណាងអោយសាលាក្តីអាជ្ញាកណ្តាល[60] |
| ១៥ ធ្នូ ២០១៤ | ប្រទេសចិនមិនបានដាក់ Counter Memorial នោះទេ[61] |
| ១៧ ធ្នូ ២០១៤ | នីតិវិធីលេខ០៣ បានប្រកាសដោយ PCA ដែលតំណាងអោយសាលាក្តីអាជ្ញាកណ្តាល[62] |
| ១៦ មីនា ២០១៥ | ប្រទេសហ្វីលីពីនបានធ្វើសំណើជាលាយលក្ខណ៍អក្សរទៅកាន់តុលាការ[63] |
| ២០ ២១ មេសា ២០១៥ | កិច្ចប្រជុំលើកទី៣ នៅតុលាការក្រុងឡាអេ[64] |
| ២២ មេសា ២០១៥ | នីតិវិធីលេខ០៤ បានប្រកាសដោយ PCA ដែលតំណាងអោយសាលាក្តីអាជ្ញាកណ្តាល[65] |
| ៧ ១៣ កក្កដា ២០១៥ | បើកសវនាការនៃតុលាការក្រុងឡាអេ[66] [67] |
| ២៩ តុលា ២០១៥ | PCA បានចេញសេចក្តីសម្រេច[68] |
| ១២ កក្កដា ២០១៦ | PCA បានចេញសេចក្តីសម្រេចថាប្រទេសចិនមិនមានមូលដ្ឋានច្បាប់ និង |

60 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 3 June 2014.
61 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 17 December 2014
62 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 17 December 2014
63 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 22 April 2014
64 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 22 April 2015.
65 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 22 April 2015.
66 name=PCA20150707>"Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 7 July 2015.
67 "Arbitration between the Republic of the Philippines and the People’s Republic of China" (PDF). Permanent Court of Arbitration. 13 July 2015.
68 "Award on Jurisdiction and Admissibility 29102015". Permanent Court of Arbitration. 29 October 2015. pp. 54–57.

| | |
|---|---|
| | ប្រវត្តិសាស្ត្រក្នុងការទាមទារ តំបន់ជាប់ខ្សែបន្ទាត់ទី៩ នោះទេ។ ចិនបានបដិសេធមិនទទួលស្គាល់សេចក្តីសម្រេច។ |

## ផ្នែកទី៣៖ ការបញ្ចប់ និងភាពស្ងប់ស្ងាត់លើសមុទ្រចិនខាងត្បូង

### ១. ការចរចារ និងការឯកភាព

ជាការពិតណាស់ ត្បិតតែមានភាគីជម្លោះចង់បាននូវអ្វីដែលខ្លួនទាមទាររៀងៗខ្លួន ក៏ប៉ុន្តែគ្មានភាគីណាមួយចង់អោយមានវិនាសកម្មដែលបង្កឡើងពីសង្គ្រាមកើតឡើងនោះទេ បើទោះបីជាចង់ឬក៏មិនចង់ក៏ត្រូវតែធ្វើការចរចារ និងឯកភាពលើចំណុចមួយចំនួនដើម្បីបន្ថយកម្តៅដូចដែលមាននៅក្នុង DOC ជាដើម។

### ២. ការផ្លាស់ប្តូរគោលនយោបាយរបស់ហ្វីលីពីន

#### ២.១ ទំនាក់ទំនងរវាង អតីតប្រធានាធិបតីហ្វីលីពីន និងអតីតប្រធានាធិបតីនៃសហរដ្ឋអាមេរិក Barack Obama

កាលពីសម័យអតីតប្រធានាធិបតី Barack Obama និង អតីតប្រធានាធិបតីហ្វីលីពីន Benigno Aquino III ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរមានភាពស្អិតរមួតនិងគ្នាយ៉ាងក្រៃលែងស្ទើរគ្រប់វិស័យជាពិសេសគឺផ្នែក ការទូត និងយោធា ដូចដែលឃើញស្រាប់ហើយថាប្រទេសហ្វីលីពីន ជាកន្លែងប្រមូលផ្តុំយោធារបស់សហរដ្ឋអាមេរិកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ យ៉ាងណាមិញការដែលមានសហរដ្ឋអាមេរិកជាសម្ព័ន្ធមិត្តយ៉ាងស្អិតរមួតជាមួយហ្វីលីពីន ធ្វើអោយឥទ្ធិពលរបស់ហ្វីលីពីនលើជម្លោះនៅក្នុងសមុទ្រចិនខាងត្បូងហាក់មានភាពលេចធ្លោជាជាងភាគីដទៃទៀត នឹងហាក់ស្មើមុខស្មើមាត់គ្នានឹងមហាអំណាចសេដ្ឋកិច្ចនិងយោធាចិនទៀតផង។ ត្បិតតែសហរដ្ឋអាមេរិកមិនមានជាភាគីផ្ទាល់នៃជម្លោះនេះយ៉ាងណាក្តីប៉ុន្តែប្រទេសមហាអំណាចសេដ្ឋកិច្ច និងយោធាលំដាប់ទី១ លើលោកនេះតែងតែលូកដៃជាប្រយោលនៅក្នុងបញ្ហាវិវាទមួយនេះជានិច្ច ដើម្បីជាប្រយោជន៍ដល់សម្ព័ន្ធមិត្តរបស់ខ្លួននៅក្នុងក្តីមួយនេះ និងអាចកាត់បន្ថយឥទ្ធិពលរបស់គូ បដិបក្សដែលជាដៃគូប្រកួតប្រជែងលើគ្រប់វិស័យហើយកាន់តែពិសេសប៉ុន្មានឆ្នាំចុងក្រោយនេះគឺមាន ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងយោធាខ្លាំងក្លាតែម្តង។ យើងក្រឡេកមកមើលពីទំនាក់ទំនងរបស់ប្រទេសទាំងពីរនេះវិញយើងឃើញថានៅក្នុងសម័យកាលដឹកនាំរបស់អតីតប្រធានាធិបតីហ្វីលីពីនលោកBenigno Aquino III ទំនាក់ទំនងរវាងប្រទេសទាំងពីរគឺមានភាពល្អជាមួយខ្លាំងណាស់ស្ទើរតែគ្រប់វិស័យជាពិសេសគឺផ្នែកយោធាតែម្តង ដោយមានការដាក់ជាមូលដ្ឋានទ័ពរបស់សហរដ្ឋអាមេរិកនៅក្នុងទឹកដីប្រទេសហ្វីលីពីនយ៉ាងសំបើម រួមទាំងការធ្វើសមយុទ្ធជាមួយគ្នាយ៉ាងគគ្រឹកគគ្រេងផងដែរមិនតែប៉ុណ្ណោះ សហរដ្ឋអាមេរិកតែងតែធ្វើ ការគាំទ្រលើយុទ្ធសាស្ត្រដែលហ្វីលីពីនបានដាក់ចេញនៅក្នុង

គោលបំណងការពារដែនសមុទ្រដែលខ្លួនបានទាមទារនៅលើដែនជម្លោះផងដែរ។ សហរដ្ឋអាមេរិកក៏ធ្លាប់បានធ្វើការព្រមានយ៉ាងធ្ងន់ធ្ងរផងដែរទៅលើ ភាគីណាដែលមានបំណងចង់ប្រើកម្លាំងបាយដើម្បីបង្កើនឥទ្ធិពលរបស់ខ្លួនក្នុងដែនជម្លោះ រួមទាំងមហាយក្សចិនផងដែរ។ នៅក្នុងនោះអតីតប្រធានាធិបតីសហរដ្ឋអាមេរិកលោកBarack Obama បានលើកឡើងដដែលជាដដែលពាក់ព័ន្ធ និងបញ្ហានេះជាពិសេសគឺការប្រជុំ G២០ ក៏លោកបានលើកឡើងទាក់ទិននិងបញ្ហានេះដែរ ពេលនៅក្នុងន័យសេចក្តីរបស់លោកគឺ "ប្រសិនបើអ្នកបានចុះហត្ថលេខាទៅលើសន្ធិសញ្ញាពាក់ព័ន្ធនិងPCA ហើយជាការពិតអ្នកគឺធំជាងហ្វីលីពីនឬក៏វៀតណាម ឬក៏ភាគីដទៃទៀត ហើយគ្មានហេតុផលណាមួយដែលអ្នកត្រូវបង្ហាញឥទ្ធិពលរបស់អ្នកនៅក្នុងដែនជម្លោះនោះទេ អ្នកគឺបានប្រព្រឹត្តល្មើសទៅនឹងច្បាប់អន្តរជាតិហើយ"[69]។ លោកបានបន្តទៀតថាប្រទេសចិនត្រូវតែមានទំនួលខុសត្រូវទៅលើបញ្ហាមួយចំនួនយ៉ាងចំបាច់ ជាពិសេសគឺការបង្ហាញពីឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់ ហើយនឹងជៀសវាងការបង្ហាញឥទ្ធិពលណាមួយដែលគំរាមកំហែងទៅលើប្រទេសតូចៗដែលជាភាគីវិវាទនៅក្នុងតំបន់ជម្លោះដែនសមុទ្រចិនខាងត្បូងផងដែរ។

### ២.២ ទំនាក់ទំនងរវាងហ្វីលីពីន និងសហរដ្ឋអាមេរិកក្នុងអាណត្តិលោកRodrigo Duterte អំពីបញ្ហាសមុទ្រចិនខាងត្បូង

ការផ្លាស់ប្តូរគោលនយោបាយរបស់ហ្វីលីពីនក្រោមការដឹកនាំរបស់ប្រធានាធិបតីថ្មី លោក Rodrigo Durterte ប្រទេសហ្វីលីពីនជាប្រទេសដែលប្រកាន់យករបប នយោបាយសាធារណរដ្ឋប្រជា ធិបតេយ្យសេរី ហើយពួកគេបានយកគោលការណ៍ "បោះឆ្នោត" ដើម្បីផ្លាស់ប្តូរប្រទេសក៏ដូចជាថ្នាក់ដឹកនាំ នៅក្នុងនេះផងដែរយើងឃើញថាលោក Rodrigo Durterte បានជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជាសកលក្លាយជាប្រធានាធិបតីទី១៦ របស់ប្រទេសហ្វីលីពីនដែលបានឡើងកាន់តំណែងជាផ្លូវការនៅនៅថ្ងៃទី៣០ខែមិថុនាឆ្នាំ២០១៦ ហើយអ្វីដែលពិសេសនៅក្នុងសម័យកាលរបស់លោកជាអ្នកគ្រប់គ្រងប្រទេសហ្វីលីពីនគឺគោលនយោបាយរបស់លោកមួយចំនួនដូចជា ការបង្ក្រាបគ្រឿងញៀនជាលក្ខណៈទ្រង់ទ្រាយធំក្នុងប្រវត្តិសាស្ត្ររបស់ហ្វីលីពីន និងអ្វីដែលកាន់តែគួរអោយចាប់អារម្មណ៍ទៀតនោះគឺការងាករេ របស់ហ្វីលីពីនពីសម្ព័ន្ធមិត្តចាស់វស្សាពោលគឺសហរដ្ឋអាមេរិកតែម្តងហើយងាកមកផ្សះផ្សារចំណងសម្ព័ន្ធភាព ជាមួយមហាយក្សចិនវិញដែលជាគូបដិបក្សនៅក្នុងជម្លោះដែនសមុទ្រចិនខាងត្បូង។ ជាការពិតណាស់ដូចហេតុការណ៍ដែលបានកើតឡើងកន្លងមកយ៉ាងដូច្នោះដែរគឺថាប្រធានាធិបតីហ្វីលីពីនលោកRodrigo Duterte បានលុបចោលការជួបប្រជុំគ្នាជាផ្លូវ

[69] http://www.reuters.com/article/us-china-obama-relations-idUSKCN1182KX

ការជាមួយនិងប្រធានាធិបតីសហរដ្ឋអាមេរិក លោក Barack Obama ហើយបានហោះហើរទៅជួបប្រជុំជាមួយរដ្ឋាភិបាលក្រុងBeijing ដើម្បីជួបប្រជុំជាលក្ខណៈទ្វេរភាគីជាមួយជួបជាមួយលោកប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិនលោក Xi Jinping ដើម្បីពិភាក្សាពីបញ្ហាជាលក្ខណៈទ្វេរភាគីរវាងប្រទេសទាំងពីរបន្ទាប់ពីបញ្ចប់កិច្ចប្រជុំជាលក្ខណៈទ្វេរភាគី ជាមួយរដ្ឋាភិបាលទីក្រុង Beijing រួចហើយលោកក៏បន្តទៅជួបជាមួយរដ្ឋាភិបាលក្រុង Moscowបន្តទៀតពោលគឺ លោកប្រធានាធិបតីរុស្ស៊ីលោក Vladimir Putin ដើម្បីពិភាក្សាពីការងារមួយចំនួនបន្ថែមទៀត។ ដោយសារតែបញ្ហានេះធ្វើអោយអ្នកវិភាគនយោបាយជាច្រើនគិតថាស្ថានភាពរវាងសហរដ្ឋអាមេរិក និងហ្វីលីពីនឈានដល់គំនូសក្រហមហើយបន្ទាប់ពី ប្រធានាធិបតីហ្វីលីពីនបង្ហាញពីអាកប្បកិរិយាដែលនឹកស្មានមិនដល់ទៅកាន់ លោកប្រធានាធិបតីសហរដ្ឋអាមេរិកលោក Barack Obama ។ ជាការនឹកស្មានមិនដល់មួយឬក៏ជានយោបាយការទូតរបស់លោកប្រធានាធិបតីហ្វីលីពីន លោក Rodrigo Duterte ដែលបានបង្ហាញលទ្ធផលភ្លាមៗផងដែរដែលភាគីចិនបានធ្វើការដកនាវាសឹកចេញពីប្រជុំកោះ Scarborough ដែលការដកនូវកម្លាំងចេញពីដែនកោះដែលចិនបានកាន់កាប់តាំងពីឆ្នាំ២០១២ នេះបានធ្វើអោយមានផលចំណេញទៅដល់ប្រជានេសាទរបស់ប្រទេសហ្វីលីពីន ពីព្រោះទីតាំងនោះជាតំបន់នេសាទដែលប្រជានេសាទហ្វីលីពីនធ្លាប់ធ្វើនេសាទកាលពីមុនឆ្នាំ២០១២ ពោលគឺមុនពេលដែលចិនដាក់កម្លាំងទ័ពហើយឈានទៅដល់ភាពតានតឹងយ៉ាងខ្លាំងក្លានោះ។ ប៉ុន្តែនៅក្នុងនោះផងដែរមិនមានន័យថាភាគីចិននឹងដកកម្លាំងចេញឈប់ល្បាតនៅតំបន់នោះទាំងស្រុងនោះទេ តែមានការអនុញ្ញាតអោយប្រជានេសាទហ្វីលីពីនអាចចូលនេសាទបាន នៅក្នុងតំបន់ត្រីកោណដែលមានផ្ទៃក្រឡាប្រមាណ ១២០គីឡូម៉ែត្រការ៉េនោះដែលគេមិនឃើញមានកងនាវាចិនមកប្រចាំការនិងចុះល្បាតទៀតនោះទេ[70] ហើយក៏ជាលើកទី១ផងដែរនៅក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ។ នៅក្នុងនោះរដ្ឋលេខាធិការការពារជាតិរបស់ប្រទេសហ្វីលីពីនលោក Delfin Lorenzana ក៏បានថ្លែងប្រាប់អ្នករាយការណ៍ដែរថា " ប្រសិនបើកងនាវាចិនចាកចេញនោះក៏វាមានន័យថាប្រជានេសាទរបស់យើង ក៏អាចបន្តការនេសាទនៅតំបន់នោះបន្តទៀតបានផងដែរ គួរបញ្ជាក់ផងដែរថាចាប់តាំងពីរចិនបានដាក់ការគ្រប់គ្រងនៅលើតំបន់នេះចាប់តាំងពីឆ្នាំ២០១២ នោះមកគឺយើងឃើញថាពួកគេបានជម្លៀសប្រជានេសាទហ្វីលីពីនអោយចេញពីតំបន់នោះពោលគឺ មានតែប្រជានេសាទចិនតែប៉ុណ្ណោះដែលមានវត្តមាននៅតំបន់នោះបាន។ គួរបញ្ជាក់ផងដែរថាបន្ទាប់ពីការគ្រប់គ្រងកោះនេះបានមួយឆ្នាំ អតីតប្រធានាធិបតីហ្វីលីពីនលោកBenigno Aquino III ក៏បានដាក់ពាក្យបណ្តឹងទៅកាន់

[70] http://thediplomat.com/2016/11/has-duterte-won-a-south-china-sea-concession-from-china/ line 10

PCA អោយជួយរកយុត្តិធម៌ផងដែរ។ នៅខែកក្កដា PCA ក៏បានចេញ សេចក្តីសម្រេចមួយដែលប្រកាន់ដែនជម្លោះនោះអោយទៅហ្វីលីពីនជាអ្នកកាន់កាប់វិញ ដោយមើលឃើញថាតំបន់នោះហ្វីលីពីនធ្លាប់បានធ្វើនេសាទអស់ពេលជាយូរលង់ណាស់មកហើយ ប៉ុន្តែនោះតែមិនបានលទ្ធផលអ្វីជាដុំកំភួនសោះឡើយដោយសារភាគីចិន បានប្រកាសជាសាធារណៈថាខ្លួនមិនទទួលស្គាល់ សេចក្តីសម្រេចនោះឡើយដោយខ្លួនយល់ឃើញថា ការសម្រេចនោះមិនបានផ្អែកទៅលើមូលដ្ឋានច្បាប់នោះឡើយ ប៉ុន្តែជាការសម្រេចដោយផ្អែកទៅលើមូលដ្ឋាននៃប្រវត្តិសាស្ត្រខ្លះៗទៅវិញ ដោយយោងទៅលើមូលហេតុមួយនេះតម្រួតចិននៅតែបន្តហាមឃាត់ ប្រជានេសាទហ្វីលីពីនមិនអោយចូលទៅកាន់តំបន់នោះដដែលថ្វីបើតុលាការសម្រេចយ៉ាងណាក៏ដោយ។

បញ្ហាកម្តៅដែលចេះតែកើនឡើងនៅលើដែនកោះ Scarborough Shoal គឺជាបញ្ហាដែលកំពុងធ្វើអោយមានការព្រួយបារម្ភយ៉ាងខ្លាំងក្លាពីសំណាក់ប្រទេសដែលជាសមាជិកអាស៊ាន ក៏ដូចជាពិភពលោកទាំងមូលផងដែរ ប៉ុន្តែអ្វីដែលចោទជាសំណួរនៅពេលនេះគឺថា ហេតុអ្វីបានជាមានបញ្ហានៅលើដែនកោះ Scarborough? វាជាសំណួរដែលហាក់ដូចជាពិបាកឆ្លើយ ប៉ុន្តែប្រសិនបើយើងងាកទៅមើលពីបញ្ហាជាក់ស្តែងយើងប្រាកដជាបានយល់ ទាក់ទិននឹងបញ្ហានេះផងដែរយើងឃើញថាភាគីចិនបានបំពានទាំងសេចក្តីសម្រេចរបស់PCA មិនតែប៉ុណ្ណោះភាគីចិនក៏បានបំពារបំពានទៅលើ DOC ដែលខ្លួនជារដ្ឋហត្ថលេខីហើយជាអ្នកផ្តល់សច្ចាប័នផ្ទាល់ទៀតផង ដោយសារតែចិនបានធ្វើការសាងសង់ជាលក្ខណៈ ទ្រង់ទ្រាយធំដោយមិនបានទទួលការឯកភាពពីភាគីណាមួយឡើយ ពោលគឺធ្វើតាមទំនើងចិត្តដែលអាងថាខ្លួនជាប្រទេសមហាអំណាច ដែលការដែលចិនធ្វើនេះគឺវាបំពាបំពានទៅលើសេចក្តីដូចដែលមានចែងនៅក្នុង DOC ដែលបានចែងថាត្រូវតែអនុវត្តអោយបានមុតមាំទៅលើសកម្មភាពណាមួយដែលធ្វើ អោយកាន់តែមានភាពស្មុគ្រស្មាញ ដែលអាចបំផ្លាញនូវសុខសន្តិភាព និងស្ថេរភាព។ ដូច្នេះការដែលចិនធ្វើសកម្មភាពបែបនេះគឺបានស្តែងយ៉ាងច្បាស់ថា ចិនកំពុងតែធ្វើអោយប្រទេសដែលជាភាគីជម្លោះដទៃទៀតកើតទុក្ខមិនសុខចិត្ត និងឈានទៅដល់ការផ្ទុះអាវុធនៅក្នុងរូបភាពណាមួយក៏អាចថាបាន នេះជាហេតុផលមួយដែលធ្វើអោយជម្លោះនៅតំបន់នោះកាន់តែក្តៅគគុក និងឈានទៅដល់ការប្រឈមមុខគ្នាដោយអាវុធណាមួយ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមទឡ្ហីករណ៍ខាងលើ យើងអាចសន្និដ្ឋានបានថាវិវាទសមុទ្រចិនខាងត្បូងគឺជាជម្លោះមួយដែលពិបាកក្នុងការដោះស្រាយបំផុតក្នុងបរិប័ទថ្មីនៃសតវត្សទី២១ ដោយសារតែក្នុងជម្លោះនេះគឺ មានភាគីជម្លោះចូលរួមច្រើនជាងវិវាទផ្សេងៗជាក់ស្តែងភាគីចូលរួមមានដូចជា ចិន ហ្វីលីពីន ម៉ាឡេស៊ី វៀតណាម ប្រ៊ុយណេ និង តៃវ៉ាន់។ ភាគីនីមួយៗតែងតែបង្ហាញសកម្មភាពផ្សេងៗដើម្បីបន្ថែមភាពតាន តឹងពោលគឺធ្វើឲ្យជម្លោះកាន់តែពិបាក្នុងការរកដំណោះស្រាយ។ អាស្រ័យហេតុនេះទើបមានមតិជា ច្រើនលើកជាសំនួរថាហេតុអ្វីបានជាភាគីជម្លោះមិនព្រមសម្របសម្រួលគ្នាដើម្បីដោះស្រាយវិបត្តិនេះ។ ចម្លើយនោះគឺមកពីភាគីវិវាទនីមួយៗមិនចង់បាត់បង់ផលប្រយោជន៍របស់ក្នុងដែនដីជម្លោះ។ ភាគីនីមួយៗព្យាយាមទទូចទាមទារនូវតំបន់កាន់កាប់ក៏ព្រោះតែក្នុងដែនសមុទ្រមានជម្លោះនោះគឺពោរពេញដោយសម្បត្តិមហាសាលដែលជាអត្ថប្រយោជន៍យ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ជាតិមាតុភូមិរបស់ខ្លួន។ សម្បត្តិមហាសាលដែលមានដូចជា រ៉ែប្រេងកាត ឧស្ម័នធម្មជាតិធនធានក្នុងទឹក និង អត្ថិភាពក្នុងការចល័តនាវាដោយសេរីលើដែនសមុទ្រសុទ្ធតែមូលហេតុចំបងដែលធ្វើឲ្យភាគីមិនអាចមិនពិចារណាគិតគូបាន។ ម្យ៉ាងវិញទៀតប្រសិនបើភាគីទទួលបានសម្បត្តិមហាសាលទាំងនោះភាគីនី មួយៗអាចអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនឲ្យមានឥទ្ធិពលក្នុងតំបន់ទៀតផង។ ជាក់ស្តែង រដ្ឋដែលជាម្ចាស់ តំបន់ជម្លោះអាចធ្វើការបូមយករ៉ែនិងឧស្ម័នផ្សេងៗដើម្បីលក់ដោយប្តូរមកវិញនូវប្រាក់កំរៃឬអាចទុកផ្គត់ផ្គង់ក្នុងប្រទេសក្នុងកាលៈទេសៈចាំបាច់។ មួយវិញទៀតភាគីជម្លោះអាចលើកស្ទួយជីវភាពរស់នៅ របស់ប្រជាជនខ្លួនតាមរយៈការនេសាទក្នុងតំបន់នោះបានហើយអាចផ្តល់ជាអត្ថប្រយោជន៍ចូលក្នុងរដ្ឋទៀតផង ជាឧទាហរណ៍នោះគឺការផ្គត់ផ្គង់ត្រីនិងគ្រឿងសមុទ្រ ២៥ភាគរយ ក្នុងពិភពលោកគឺមានប្រភព មកពីតំបន់សមុទ្រចិនខាងត្បូង។ លើសពីនេះទៅទៀតអត្ថិភាពនៃការចល័តនាវាដោយសេរីក៏ជា សញ្ញាណដ៏សំខាន់ផងដែរសំរាប់សន្តិសុខជាតិជាក់ស្តែងមុនសង្គ្រាមលោកលើកទី១ ចក្រភពអង់គ្លេសក្លាយជាមហាអំណាចក្នុងតំបន់និងអាចដាក់និទ្ទាការត្រួតត្រាលើប្រទេសដទៃបានក៏ដោយចក្រភពអង់គ្លេសមានអត្ថិភាពនិងអានុភាពគ្រប់គ្រាន់ក្នុងការចល័តនាវារបស់ខ្លួនដើម្បីការពារនិងពង្រឹងសន្តិសុខផ្លូវទឹក។ ក្រឡេកមើលមហាអំណាចចិនដែលជាភាគីជម្លោះវិញម្តងក៏ព្យាយាមពង្រឹង អានុភាពលើផ្ទៃទឹកផងដែរដើម្បីការពារសន្តិសុខក្នុងតំបន់ ដូចនេះទើបចិនព្យាយាមទទូចទាមទារតំបន់ ផ្សេងៗក្នុងសមុទ្រចិនខាងត្បូង។ យើងសង្កេតឃើញថាចាប់តាំងពីឆ្នាំ២០១២មក ជម្លោះនៅដែនសមុទ្រចិនខាងត្បូងកាន់តែមានភាពតានតឹងឡើងៗជាពិសេសក្នុងតំបន់នៃប្រជុំកោះ Scarborough Shoal និង Spratlyss Islands ដែលជាតំបន់

ជម្លោះដែលប្រកបដោយភាពតានតឹងរវាង ភាគីចិន និង ហ្វីលីពីន។ ភាគីចិនតែងតែបង្ហាញសកម្មភាពរបស់ខ្លួនដោយធ្វើការគាបសង្កត់មកលើ ភាគីហ្វីលីពីនដែលជាប្រទេសតូចជាងខ្លួន។ ដោយឡែកថ្វីបើហ្វីលីពីនជាប្រទេសតូចជាងចិនក៏ពិត មែនប៉ុន្តែប្រទេសនេះព្យាយាមរកគ្រប់មធ្យោបាយដើម្បីការពារបូរណៈភាពទឹកដីរបស់ខ្លួនដោយធ្វើការតតាំងជាមួយមហាអំណាចចិនតាមរយៈយុទ្ធសាស្ត្រនិងគោលនយោបាយផ្សេងៗ។ ដំបូងនៅក្នុងអាណត្តិរបស់អតីតប្រធានាធិបតី Aquino III នៃសាធារណៈរដ្ឋហ្វីលីពីនលោកបានធ្វើការ សហការជាមួយភាគីជម្លោះផ្សេងៗដែលជាប្រទេសតូចដូចគ្នា ដោយរួមដៃគ្នាតតាំងជាមួយចិនមិន រាថយ។ លើសពីនេះទៅទៀតដោយសារមានការជួយជ្រោមជ្រែងពីសម្ព័ន្ធមិត្តរបស់ខ្លួនគឺសហរដ្ឋ អាមេរិកភាគីហ្វីលីពីនកាន់តែហ៊ានបង្ហាញសកម្មភាពតទល់ជាមួយចិនដូចជា ការដាក់ពាក្យបណ្តឹងទៅកាន់ PCA ជាដើម។ រីឯចូលមកដល់អាណត្តិនៃអ្នកដឹកនាំថ្មីនៃសាធារណៈរដ្ឋហ្វីលីពីនគឺលោក Duterte វិញក៏មានយុទ្ធសាស្ត្រនិងគោលនយោបាយមួយចំនួនដើម្បីការពារផលប្រយោជន៍នៃតំបន់ ជម្លោះផងដែរដូចជា ការពង្រឹងទំនាក់ទំនងជាមួយភាគីចិនដោយបង្កើតកិច្ចសហប្រតិបត្តិការដើម្បី ទាញយកផលប្រយោជន៍រួមគ្នាពីតំបន់ជម្លោះ។ ថ្វីត្បិតតែភាគីជម្លោះបង្កភាពតានតឹងទៅវិញទៅមកក៏ ពិតមែន ប៉ុន្តែភាគីជម្លោះក៏ព្យាយាមរកដំណោះស្រាយផងដែរ ជាក់ស្តែងការសម្របសម្រួលគ្នាតាម រយៈសមាគមន៍អាស៊ានដោយបង្កើតDOC។ បើទោះជាភាគីជម្លោះមានព្យាយាមរកដំណោះស្រាយ តាមរយៈការចូលរួមក្នុងកិច្ចសហប្រតិបត្តិការផ្សេងៗក៏ពិតមែនតែបញ្ហាជម្លោះនៅតែបន្តភាពតានតឹងរហូតមកដល់ពេលបច្ចុប្បន្ន។

## ការផ្ដល់អនុសាសន៍

បញ្ហាជាច្រើនដែលធ្វើឲ្យវិវាទសមុទ្រចិនខាងត្បូងនៅតែបន្តគឺដោយសារតែភាគីជម្លោះនីមួយៗចេះតែបង្កើតភាពតានតឹងហើយមិនព្យាយាមរកដំណោះស្រាយដើម្បីបញ្ចប់បញ្ហា។ ជាក់ស្ដែងភាគី ចិនដែលជាមហាអំណាចចេះតែបង្កើតបញ្ហានៅដែនសមុទ្រមានជម្លោះមិនឈប់មិនឈរដូចជា ការ សាងសង់កោះសប្បិនិម្មិត ការបញ្ជូននាវាទៅដែនសមុទ្រមានជម្លោះ ការដាក់មូលដ្ឋានទ័ព រួមទាំងសកម្មភាពផ្សេងៗទៀតជាអាទិ៍ ដែលបង្កឲ្យមានភាពតានតឹងជាមួយភាគីជម្លោះផ្សេងទៀត។ ហេតុដូចនេះជាអនុសាសន៍ដើម្បីធ្វើឲ្យដែនវិវាទសមុទ្រចិនខាងត្បូងមានភាពធូរស្រាល និងឈានទៅរកដំណោះក្នុងការបញ្ចប់ជម្លោះនោះ ដំបូងភាគីគួរតែកាត់បន្ថយភាពតានតឹង បន្ទាប់មកព្យាយាមស្វែងរកដំណោះស្រាយហើយប្រតិបត្តិតាមការគោលការណ៍ដែលបានកំណត់។

- ការបន្ថយភាពតានតឹង

ដើម្បីកាត់បន្ថយភាពតានតឹង ភាគីជម្លោះទាំងអស់គួរតែបញ្ឈប់រាល់សកម្មភាពទាំងឡាយដែលប្រព្រឹត្ត នៅលើដែនកោះមានជម្លោះដែលអាចបង្កជាភាពតានតឹង ពោលគឺភាគីគួរតែគោរពដែនអធិបតេយ្យ។ មួយវិញទៀតភាគីពុំចាំបាច់បន្តការសាងសង់កោះសិប្បនិម្មិតនៅដែនសមុទ្រមានជម្លោះទៀតឡើយ ជាក់ស្ដែង ប្រទេសចិនដើមឡើយសាងសង់កោះសិប្បនិម្មិតនៅប្រជុំកោះ Spratlysព្រោះសង្ឃឹមថានឹង ទទួលបានអត្ថប្រយោជន៍ចំពោះការទាមទារនៅជុំវិញតំបន់នោះ។ ប៉ុន្តែដោយយោងតាមអនុសញ្ញា អង្គការសហប្រជាជាតិស្ដីពីច្បាប់សមុទ្រ(UNCLOS)ចែងថាកោះសិប្បនិម្មិតមិនមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ជា 'កោះ' នៅក្រោមអនុសញ្ញានេះទេព្រោះវាមិនត្រូវបានបង្កើតឡើងដោយធម្មជាតិនៃ ដីដែលហ៊ុំព័ទ្ធដោយទឹកតាមលក្ខណៈធម្មជាតិនោះទេ។ដូចនេះកោះសិប្បនិម្មិតមិនមានសិទ្ធិទទួលបានតំបន់សមុទ្រណាមួយទេ។ អាស្រ័យតាមការបញ្ជាក់ដូចនេះភាគីជម្លោះមិនគួរបង្កើតគម្រោងដើម្បី សាងសង់កោះសិប្បនិម្មតទៀតទេព្រោះវាមិនបានផ្ដល់ជាជំនួយក្នុងការទាមទារដែនអធិបតេយ្យនោះទេ ផ្ទុយទៅវិញទង្វើនេះបានត្រឹមតែបង្កភាពតានតឹងរវាងភាគីជម្លោះកាន់តែខ្លាំងប៉ុណ្ណោះ។ លើសពីនេះទៅទៀត មុនពេលទទួលបានដំណោះស្រាយសមស្របណាមួយ ភាគីជម្លោះគួររក្សាភាពស្ងប់ស្ងៀមដោយគោរពតាមតួនាទីរបស់ខ្លួននិងដែនអធិបតេយ្យរបស់គូរភាគីដោយមិនបង្កបញ្ហាតទៅទៀត។

ខាងក្រោមនេះជាអនុសាសន៍សម្រាប់ការស្វែងរកដំណោះស្រាយចំពោះគូភាគី៖

- ដំណោះស្រាយ

ភាគីនីមួយៗគួរតែបញ្ជាក់អំពីអំណះអំណាងចំពោះការទាមទាររបស់ខ្លួនឲ្យបានច្បាស់លាស់។ ជាក់ស្ដែង ភាគីចិនអះអាងថាតំបន់ជម្លោះដែលខ្លួនទាមទារនោះគឺបានកាន់កាប់តាំងពី២០០០ឆ្នាំមុន

នៃ ប្រវិត្តសាស្ត្រមកម្ល៉េះ ប៉ុន្តែចិនពុំបានបង្ហាញពីភស្តុតាងកាលពី២០០០ឆ្នាំមុននៃប្រវិត្តសាស្ត្រនោះទេ ចិនបានត្រឹមតែបង្ហាញពីផែនទីតាមរយៈខ្សែបន្ទាត់ទី៩ដែលខ្លួនបានគូរកាលពីឆ្នាំ១៩៤៧ ប៉ុណ្ណោះ។ ដូចនេះ អំណះអំណាងចិនមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ជាក់ជាមួយភាគីហ្វីលីពីននោះទេ។ មួយវិញទៀត ដើម្បីអាចទទួលបានការបញ្ជាក់ឲ្យកាន់ច្បាស់តែពីភាគីចិន សហរដ្ឋអាមេរិក និង ប្រទេសដទៃទៀតគួរតែលើកទឹកចិត្តកោះតៃវ៉ាន់ឲ្យបកស្រាយអត្ថន័យនៃផែនទីដើមឆ្នាំ ១៩៤៧របស់ខ្លួនព្រោះដោយសារតែការទាមទារតាមរយៈខ្សែបន្ទាត់ទី៩របស់ចិនគឺផ្អែកលើការអះអាងដូចគ្នានឹងកោះតៃវ៉ាន់។ ដូចនេះការសម្រេចចិត្តរបស់តៃវ៉ាន់ដើម្បីបញ្ជាក់ពីការអះអាងរបស់ខ្លួននឹងដាក់សម្ពាធលើ ទីក្រុងប៉េកាំងឲ្យធ្វើដូចគ្នា។

ម៉្យាងវិញទៀតចុងបញ្ចប់នៃជម្លោះដែនអធិបតេយ្យលើលក្ខណៈដែនដីនៅក្នុងសមុទ្រចិនខាងត្បូងគួរតែត្រូវបាននាំយកទៅតុលាការយុត្តិធម៌អន្តរជាតិប៉ុន្តែចំណុចនេះទំនងជាមិនអាចកើតឡើងទេ ដោយសារការមិនឯកភាពរបស់ភាគី។ ហេតុដូច្នេះវិធីសាស្ត្រសមហេតុផលមួយសម្រាប់ភាគីទាមទារ ក្នុងតំបន់មានជម្លោះនោះគឺការចរចារគ្នា។ ភាគីអាចធ្វើការចរចារគ្នាតាមលក្ខណៈទ្វេភាគី ឬពហុភាគីដើម្បីស្វែងរកផលប្រយោជន៍ហើយបញ្ចប់ជម្លោះ។ ទន្ទឹមនឹងនេះភាគីគួរតែគោរពតាមគោលការណ៍នៃនីតិអន្តរជាតិដើម្បីដោះស្រាយបញ្ហាពីព្រោះនីតិអន្តរជាតិជាគោលការណ៍ដែលមានលក្ខណៈសកលដូចនេះរដ្ឋទាំងអស់គួរប្រតិបត្តិ។ ជាអនុសាសន៍ចុងក្រោយសម្រាប់ភាគីហ្វីលីពីននិង ចិននោះគឺភាគីទាំងអស់គួរតែគោរពតាមគោលការណ៍DOCដែលខ្លួនបានផ្តល់សច្ចាប័នព្រោះភាគីទាំងពីរជារដ្ឋហត្ថលេខីដូចនេះត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដោយមិនត្រូវមានចេតនាបង្កជាបញ្ហាផ្សេងទៀតនោះទេហើយភាគីទាំងពីរត្រូវតែប្រតិបត្តិតាមគោលការណ៍ដែលបានកំណត់ទើបវិវាទនេះអាចឈានទៅរកដំណោះស្រាយក្នុងការបញ្ចប់បាន។

# ឯកសារយោង


- *"The Republic of the Philippines v. The People's Republic of China". Permanent Court of Arbitration.*
- Chinese Society of International Law. The Tribunal's Award in the "South China Sea Arbitration" Initiated by the Philippines Is Null and Void (Report).
- Ministry of Foreign Affairs of the People's Republic of China. Position Paper of the Government of the People's Republic of China on the Matter of Jurisdiction in the South China Sea Arbitration Initiated by the Republic of the Philippines (Report).
- Valencia, Mark J.; Van Dyke, Jon M.; Ludwig, Noel A. (1999). *Sharing the Resources of the South China Sea*. University of Hawaii Press. pp. 36–38. ISBN 9780824818814.
- *"Declarations or Statements upon UNCLOS ratification*
- Del Cappar, Michaela (25 April 2013). "ITLOS completes five-man tribunal that will hear PHL case vs. China". *GMA News One*. Retrieved 24 October 2013.
- Torode, Greg (27 September 2013). "Philippines South China Sea legal case against China gathers pace". Reuters. Retrieved 24 October 2013.
- Harvey, Adam (13 July 2016). "Philippines celebrates victory in South China Sea case, despite China's refusal to accept result". *ABC News*. Retrieved 13 July 2016.
- *"Tribunal schedules hearing on merits of PH arbitration case against China". Update.PH. 10 November 2015.*
- *"Evian summit – Questions about the G8"*. Ministère des Affaires étrangères, Paris.
- Harvey, Adam (13 July 2016). "Philippines celebrates victory in South China Sea case, despite China's refusal to accept result". ABC News. Retrieved 13 July 2016.
- "Press release: The South China Sea Arbitration" (PDF). Permanent Court of Arbitration. 12 July 2016. The Award is final and binding, as set out in Article 296 of the Convention and Article 11 of Annex VII.
- Permanent Court of Arbitration. 12 July 2016
- *Calonzo, Andreo (26 February 2015). "PHL, France to share intel, best practices vs. terrorism". GMA News. Retrieved 29 May 2016. France also expressed support for the Philippines' efforts to settle through international arbitration its territorial dispute with China over parts of the South China Sea, which Manila calls the West Philippine Sea.*

- *"International Court of Justice". Retrieved 24 July 2016. The International Court of Justice (ICJ) wishes to draw the attention of the media and the public to the fact that the Award in the South China Sea Arbitration (The Republic of the Philippines v. The People's Republic of China) was issued by an Arbitral Tribunal acting with the secretarial assistance of the Permanent Court of Arbitration (PCA). The relevant information can be found on the PCA's website (www.pca-cpa.org). The ICJ, which is a totally distinct institution, has had no involvement in the above mentioned case.*
- *"Joint Statement of the Foreign Ministers of ASEAN Member States on the Maintenance of Peace, Security, and Stability in the Region". 25 July 2016. Retrieved 14 August 2016.*
- *"Arbitral court not a UN agency". Retrieved 24 July 2016. The United Nations said on Wednesday it has nothing to do with the Permanent Court of Arbitration (PCA), which set up a tribunal that handled the South China Sea arbitration case the Philippines filed unilaterally in 2013.*
- *Barack Obama (16 February 2016). Remarks by President Obama at U.S.-ASEAN Press Conference (Speech). California, United States. Retrieved 28 June 2016. And we discussed how any disputes between claimants in the region must be resolved peacefully, through legal means, such as the upcoming arbitration ruling under the U.N. Convention of the Law of the Seas, which the parties are obligated to respect and abide by.*
- Tiezzi, Shannon. "In China, Germany's Merkel Talks Trade, Syria, and South China Sea". The Diplomat. Retrieved 30 May 2016. She [German Chancellor, Angela Merkel] called the disputes "a serious conflict" and gently offered her support for a legal solution: "I am always a bit surprised why in this case multinational courts should not be an option for a solution." Merkel also emphasized Germany's "wish that the sea trade routes stay free and safe, because they are important for all."
- *Ministry of Foreign Affairs of the People's Republic of China. Position Paper of the Government of the People's Republic of China on the Matter of Jurisdiction in the South China Sea Arbitration Initiated by the Republic of the Philippines (Report).*
- Chinese Society of International Law. The Tribunal's Award in the "South China Sea Arbitration" Initiated by the Philippines Is Null and Void (Report).
- *"World tribunal to hear South China Sea case". Bangkok Post. 30 October 2015.*
- https://energy.usgs.gov/OilGas/AssessmentsData/WorldPetroleumAssessment.aspx
- https://www.eia.gov/todayinenergy/detail.php?id=4650

- https://www.eia.gov/todayinenergy/detail.php?id=17631
- http://www.myanmarinsider.com/
- http://www.myanmarinsider.com/south-china-sea-conflict-threatens-aseans-growth-and-stability/
- https://pca-cpa.org/wp-content/uploads/sites/175/2016/07/PH-CN-20160712-Press-Release-No-11-English.pdf
- http://www.ide.go.jp/English/Research/Region/Asia/201209_suzuki.html
- https://obamawhitehouse.archives.gov/the-p
- https://www.reuters.com/article/southchinasea-china-usa-idUSL3N1043AM20150724
- http://focustaiwan.tw/news/aipl/201605170030.aspx
- https://www.state.gov/r/pa/ei/bgn/2814.htm
- https://fas.org/sgp/crs/row/RL32593.pdf
- *http://www.rappler.com/nation/69293-philippines-aquino-eu-barroso-unclos*
- *https://www.reuters.com/article/us-southchinasea-usa-eu-idUSKCN0 S022G20151031*
- *https://www.theguardian.com/world/2016/apr/19/south-china-sea-britain-court-arbitration-ruling-binding*

# ឧបសម្ព័ន្ធ

# ឯកសារយោង


- *"The Republic of the Philippines v. The People's Republic of China". Permanent Court of Arbitration.*
- Chinese Society of International Law. The Tribunal's Award in the "South China Sea Arbitration" Initiated by the Philippines Is Null and Void (Report).
- Ministry of Foreign Affairs of the People's Republic of China. Position Paper of the Government of the People's Republic of China on the Matter of Jurisdiction in the South China Sea Arbitration Initiated by the Republic of the Philippines (Report).
- Valencia, Mark J.; Van Dyke, Jon M.; Ludwig, Noel A. (1999). *Sharing the Resources of the South China Sea*. University of Hawaii Press. pp. 36–38. ISBN 9780824818814.
- *"Declarations or Statements upon UNCLOS ratification*
- Del Cappar, Michaela (25 April 2013). "ITLOS completes five-man tribunal that will hear PHL case vs. China". *GMA News One*. Retrieved 24 October 2013.
- Torode, Greg (27 September 2013). "Philippines South China Sea legal case against China gathers pace". Reuters. Retrieved 24 October 2013.
- Harvey, Adam (13 July 2016). "Philippines celebrates victory in South China Sea case, despite China's refusal to accept result". *ABC News*. Retrieved 13 July 2016.
- *"Tribunal schedules hearing on merits of PH arbitration case against China". Update.PH. 10 November 2015.*
- *"Evian summit – Questions about the G8"*. Ministère des Affaires étrangères, Paris.
- Harvey, Adam (13 July 2016). "Philippines celebrates victory in South China Sea case, despite China's refusal to accept result". ABC News. Retrieved 13 July 2016.
- "Press release: The South China Sea Arbitration" (PDF). Permanent Court of Arbitration. 12 July 2016. The Award is final and binding, as set out in Article 296 of the Convention and Article 11 of Annex VII.
- Permanent Court of Arbitration. 12 July 2016
- *Calonzo, Andreo (26 February 2015). "PHL, France to share intel, best practices vs. terrorism". GMA News. Retrieved 29 May 2016. France also expressed support for the Philippines' efforts to settle through international arbitration its territorial dispute with China over parts of the South China Sea, which Manila calls the West Philippine Sea.*

- *"International Court of Justice". Retrieved 24 July 2016. The International Court of Justice (ICJ) wishes to draw the attention of the media and the public to the fact that the Award in the South China Sea Arbitration (The Republic of the Philippines v. The People's Republic of China) was issued by an Arbitral Tribunal acting with the secretarial assistance of the Permanent Court of Arbitration (PCA). The relevant information can be found on the PCA's website (www.pca-cpa.org). The ICJ, which is a totally distinct institution, has had no involvement in the above mentioned case.*
- *"Joint Statement of the Foreign Ministers of ASEAN Member States on the Maintenance of Peace, Security, and Stability in the Region". 25 July 2016. Retrieved 14 August 2016.*
- *"Arbitral court not a UN agency". Retrieved 24 July 2016. The United Nations said on Wednesday it has nothing to do with the Permanent Court of Arbitration (PCA), which set up a tribunal that handled the South China Sea arbitration case the Philippines filed unilaterally in 2013.*
- *Barack Obama (16 February 2016). Remarks by President Obama at U.S.-ASEAN Press Conference (Speech). California, United States. Retrieved 28 June 2016. And we discussed how any disputes between claimants in the region must be resolved peacefully, through legal means, such as the upcoming arbitration ruling under the U.N. Convention of the Law of the Seas, which the parties are obligated to respect and abide by.*
- Tiezzi, Shannon. "In China, Germany's Merkel Talks Trade, Syria, and South China Sea". The Diplomat. Retrieved 30 May 2016. She [German Chancellor, Angela Merkel] called the disputes "a serious conflict" and gently offered her support for a legal solution: "I am always a bit surprised why in this case multinational courts should not be an option for a solution." Merkel also emphasized Germany's "wish that the sea trade routes stay free and safe, because they are important for all."
- *Ministry of Foreign Affairs of the People's Republic of China. Position Paper of the Government of the People's Republic of China on the Matter of Jurisdiction in the South China Sea Arbitration Initiated by the Republic of the Philippines (Report).*
- Chinese Society of International Law. The Tribunal's Award in the "South China Sea Arbitration" Initiated by the Philippines Is Null and Void (Report).
- *"World tribunal to hear South China Sea case". Bangkok Post. 30 October 2015.*
- https://energy.usgs.gov/OilGas/AssessmentsData/WorldPetroleumAssessment.aspx
- https://www.eia.gov/todayinenergy/detail.php?id=4650

- https://www.eia.gov/todayinenergy/detail.php?id=17631
- http://www.myanmarinsider.com/
- http://www.myanmarinsider.com/south-china-sea-conflict-threatens-aseans-growth-and-stability/
- https://pca-cpa.org/wp-content/uploads/sites/175/2016/07/PH-CN-20160712-Press-Release-No-11-English.pdf
- http://www.ide.go.jp/English/Research/Region/Asia/201209_suzuki.html
- https://obamawhitehouse.archives.gov/the-p
- https://www.reuters.com/article/southchinasea-china-usa-idUSL3N1043AM20150724
- http://focustaiwan.tw/news/aipl/201605170030.aspx
- https://www.state.gov/r/pa/ei/bgn/2814.htm
- https://fas.org/sgp/crs/row/RL32593.pdf
- *http://www.rappler.com/nation/69293-philippines-aquino-eu-barroso-unclos*
- *https://www.reuters.com/article/us-southchinasea-usa-eu-idUSKCN0 S022G20151031*
- *https://www.theguardian.com/world/2016/apr/19/south-china-sea-britain-court-arbitration-ruling-binding*

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី០១



Pratas Islands ថតពីលំហអាកាស ខែមករា ឆ្នាំ១៩៨៦

ប្រភព៖ https://commons.wikimedia.org/wiki/File:Pratas_island.jpg



Scarborough Shoal ថតពីលំហអាកាសដោយអង្គការណាសា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

ប្រភព៖ http://www.oceandots.com/pacific/scarborough/scarborough2.php




Macclefield Bank ថតពីលំហអាកាសដោយអង្គការណាសា នៅថ្ងៃទី២៦ ឧសភា ឆ្នាំ២០០៧ វេលាម៉ោង ៨ និង ០០ នាទីព្រឹក។

ប្រភព៖ https://commons.wikimedia.org/wiki/File:Macclesfield.png

ឧបសម្ព័ន្ធទី០២




រូបភាពខាងលើគឺជារូបភាពដែលបង្ហាញពីការទាមទាររបស់ភាគីហ្វីលីពីនទៅលើប្រជុំកោះមានជម្លោះ

http://i2.cdn.cnn.com/cnnnext/dam/assets/160712012850-china-south-china-sea-philippines-ruling-rivers-lklv-full-169.jpg




រូបភាពនេះបង្ហាញពីការទាមទារដែនអធិបតេយ្យរបស់ចិនតាមរយៈខ្សែបន្ទាត់ទីប្រាំបួន(Nine dashline)

http://3.bp.blogspot.com/-jt81DnLephQ/VkQGpSJ50wI/AAAAAAAAaO8/pyfEpNxuzvM/s1600/main-qimg-0ae722370b5d8c13728fe1f56fd80cb4.gif




រូបភាពនេះបង្ហាញពីការដាក់ពង្រាយកងទ័ពនិងនាវារបស់ភាគីជម្លោះចិន និង ហ្វីលីពីននៅដែនសមុទ្រចិនខាងត្បូង។

http://static3.businessinsider.com/image/5790fba688e4a77c708b966e-1215/screen%20shot%202016-07-21%20at%20124210%20pm.png